**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការបែងចែកអំណាចទាំងបី អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ថេង វីរៈស័ក្ក**

លោក **ប៉ង់ ប៊ុនថាន់**

ណែនាំដោយ

**លោក ថោង ចន្ទ្រា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៧

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការបែងចែកអំណាចទាំងបី អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ថេង វីរស័ក្ក**

លោក **ប៉ែង ម៉ុនថាន់**

ណែនាំដោយ

**លោក ថោង ចន្ទ្រា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៧

ឆ្នាំចូលរៀន ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ  ថេង វីស័ក្ក និង ប៉ង់ ប៊ុនថាន់ ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២០-២០២៤។

**សូមគោរពដឹងគុណ និងថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ**

- **លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅជួយទំនុកបម្រុងដល់រូបកូនៗ ទាំងស្មារតី និងសម្ភារៈគ្រប់បែបយ៉ាង ជាពិសេសរួមទាំងការផ្តល់ដំបូន្មានល្អៗរបស់លោកដល់រូបកូន ចាប់តាំងពីពេលកូននៅជាកុមាររហូតដល់ធំដឹងក្តី និងបានទទួលបានការបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សា ហើយបានបញ្ចប់ការសិក្សាជាស្ថាពរជាមួយនឹងការទទួលបានលទ្ធផលជាទីគាប់ប្រសើរថែមទៀត។ លោកទាំងពីរបានប្រឹងអស់ទាំងកម្លាំងកាយ និងកម្លាំងចិត្តរបស់លោកទាំងពីរមិនរុញរា លោកខិតខំពុះពារទាំងថ្ងៃទាំងយប់ ធ្វើយ៉ាងណាឱ្យកូនទទួលបានលទ្ធផលល្អដូចសព្វថ្ងៃ តាមរយៈការខិតខំអស់ពីកម្លាំងកាយចិត្តរបស់លោកទាំងពីរនេះហើយ បានធ្វើឱ្យកូនមិនអាចបំភ្លេចជារៀងរហូត។
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ និងឆ្លាតវៃបំផុតប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** និងបន្តវេនដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលជាអគ្គមគ្គុទេសន៍ដ៏ឆ្នើមរួមជាមួយសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានបង្កឱ្យមានកាលានុវត្តភាពដ៏ប្រសើរ និងជំរុញឱ្យសង្គមកម្ពុជាមានការអភិវឌ្ឍគ្រប់វិស័យ។ កាលានុវត្តភាពនេះហើយ បានផ្តល់ឱ្យយើងខ្ញុំមានឱកាសទទួលបានការបណ្តុះបណ្តាល ដែលពោរពេញទៅដោយក្តីសង្ឃឹមសម្រាប់អនាគត។
- ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរសអស់លោក លោកស្រី សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពង់ខ្ពស់ និងជួយតម្រង់ទិសយើងខ្ញុំទាំងពីរនាក់ ចាប់តាំងពីឆ្នាំសិក្សាមូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយគុណភាព។
- លោកគ្រូ **ថោង ចន្ថា** ដែលជាព្រឹទ្ធបុរសរងមហាវិទ្យាល័យរដ្ឋបាលសាធារណៈ ដែលពោរពេញដោយព្រហ្មវិហារធម៌ គុណធម៌ សីលធម៌ លោកគ្រូតែងតែបានដឹកនាំបង្ហាត់បង្ហាញពីគំនិត និងវិធីសាស្ត្រល្អៗទាក់ទងនឹងប្រធានបទ រួមទាំងការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកគ្រូ ចាប់តាំងពីដើមរហូតដល់បញ្ចប់ការសិក្សាស្រាវជ្រាវនេះ។

ទន្ទឹមនឹងនេះ ខ្ញុំបាទទាំងពីរនាក់ពិតជាមិនអាចបំភ្លេចបាននូវគុណូបការៈដ៏ធំធេងនេះបានឡើយ ហើយសូមប្រសិទ្ធិពរជ័យគោរពជូនលោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមបានប្រកបដោយសុខភាពល្អបរិបូរណ៍ ជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **ការបែងចែកអំណាចទាំងបី អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣** គឺជាប្រធានបទមួយដែលត្រូវបានស្រាវជ្រាវដោយខ្ញុំបាទ ថេង វីស័ក្ក និង ប៉ង់ ប៊ុនថាន់ ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមការណែនាំចង្អុលបង្ហាញរបស់លោកគ្រូ **ថោង ចន្ទ្រា**។

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺមិនមែនជាការបកស្រាយផ្លូវការលើរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ នោះទេ ផ្ទុយទៅវិញ យើងខ្ញុំទាំងពីរមានគោលបំណងក្នុងការលើកយកនូវខ្លឹមសារសំខាន់ៗ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ជាពិសេសពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃដំណើរប្រព្រឹត្តទៅនៃស្ថាប័ននយោបាយទាំងបី គឺស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការ។ សារណានេះទៀតសោតពិតជាមានសារៈសំខាន់ណាស់សម្រាប់និស្សិតរដ្ឋបាលសាធារណៈក្នុងការសិក្សាឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅពីបទដ្ឋានគតិយុត្តកំពូលនេះ និងចងក្រងទុកជាឯកសារស្រាវជ្រាវ។ យើងខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត ពេលវេលា និងធនធានផ្ទាល់ខ្លួន ដើម្បីរៀបចំចងក្រងនូវកិច្ចការនៃសារណាមួយនេះឱ្យលេចចេញជារូបរាងឡើង ព្រោះកិច្ចការមួយនេះបានធ្វើឱ្យយើងខ្ញុំចេះធ្វើកិច្ចការស្រាវជ្រាវយ៉ាងសកម្មដែលបានបង្កើតនូវចំណេះដឹងមូលដ្ឋាន បណ្ដុះគំនិតប្រាជ្ញា និងមានការយល់ដឹងកាន់តែច្បាស់អំពីប្រធានបទមួយនេះ។

យើងខ្ញុំសង្ឃឹម និងរំពឹងទុកជាមុនថា កិច្ចការមួយនេះនឹងក្លាយទៅជាប្រយោជន៍សម្រាប់មជ្ឈដ្ឋានអ្នកស្នេហាការសិក្សាទាំងឡាយ មិត្តនិស្សិត ក៏ដូចជាសិស្សានុសិស្សជំនាន់ក្រោយ ដោយចូលរួមក្នុងការបង្កើននូវពុទ្ធិចំណេះដឹងមូលដ្ឋាន ព្រមទាំងចូលរួមចំណែកក្នុងការយល់ដឹងនូវការអនុវត្តលទ្ធិប្រជាធិបតេយ្យផងដែរសម្រាប់អ្នកគ្រប់គ្នា។

ដោយសារតែចំណេះដឹងនៅមានកម្រិត ដូច្នេះយើងខ្ញុំជឿជាក់ថាកំហុសអចេតនានៅតែកើតមានឡើងដោយជៀសពុំរួចនោះឡើយ ទាំងអត្ថន័យ ខ្លឹមសារ ពាក្យពេចន៍ ឃ្លាឃ្លោង ទាំងអក្ខរាវិរុទ្ធ និងបច្ចេកទេសនៃការចងក្រង។

អាស្រ័យហេតុដូចនេះ យើងខ្ញុំសូមការខន្តីអភ័យទោសចំពោះកំហុសខុសឆ្គងដែលនឹងអាចកើតមានឡើងដោយប្រការណាមួយ ហើយមានសេចក្ដីសោមនស្សរីករាយឥតឧបមាក្នុងការទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនា និងកែលម្អ បំពេញចន្លោះខ្វះខាតនៅក្នុងអត្ថបទសារណានេះ ដើម្បីធ្វើឱ្យខ្លឹមសារ និងអត្ថបទសារណានេះកាន់តែល្អ និងស៊ីជម្រៅថែមទៀតពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**រំលឹកទ្រឹស្តី**

**១.១. សញ្ញាណទូទៅនៃរដ្ឋធម្មនុញ្ញ** ........................................ ៤

**១.១.១. ប្រវត្តិនៃរដ្ឋធម្មនុញ្ញ** ........................................ ៤

១.១.១.១. រដ្ឋធម្មនុញ្ញសម័យបុរាណ ........................................ ៤

១.១.១.២. រដ្ឋធម្មនុញ្ញសម័យទំនើប ........................................ ៤

**១.១.២. និយមន័យ** ........................................ ៥

១.១.២.១. តាមវចនានុក្រម និងច្បាប់ ........................................ ៥

១.១.២.២. តាមន័យទម្រង់ និងសម្ភារៈ ........................................ ៦

១.១.២.៣. ស្នាដៃនិពន្ធ ........................................ ៦

**១.១.៣. ទម្រង់ និងប្រភេទនៃរដ្ឋធម្មនុញ្ញ** ........................................ ៧

១.១.៣.១. ទម្រង់នៃរដ្ឋធម្មនុញ្ញ ........................................ ៧

១.១.៣.២. ប្រភេទនៃរដ្ឋធម្មនុញ្ញ ........................................ ៨

**១.១.៤. អំណាច និងសារៈសំខាន់នៃរដ្ឋធម្មនុញ្ញ** ........................................ ៨

១.១.៤.១. អំណាចនៃរដ្ឋធម្មនុញ្ញ ........................................ ៨

១.១.៤.២. សារៈសំខាន់នៃរដ្ឋធម្មនុញ្ញ ........................................ ៩

**១.១.៥. តម្លៃនៃរដ្ឋធម្មនុញ្ញ** ........................................ ៩

១.១.៥.១. តម្លៃជានិមិត្តរូប ........................................ ៩

១.១.៥.២. តម្លៃជាទស្សនវិជ្ជា ........................................ ១០

១.១.៥.៣. តម្លៃជាច្បាប់ ........................................ ១០

**១.២. រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣** ........................................ ១០

**១.២.១. ការបង្កើតរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣** ........................................ ១០

១.២.១.១. ការបង្កើតសភាធម្មនុញ្ញ ........................................ ១១

១.២.១.២. ការរៀបចំតាក់តែងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ............ ១១

**១.២.២. រចនាសម្ព័ន្ធ** ............ ១២

១.២.២.១. បុព្វកថា ............ ១២

១.២.២.២. ខ្លឹមសារគ្រឹះ ............ ១២

១.២.២.៣. អន្តរប្បញ្ញត្តិ ............ ១៥

១.២.២.៤. ឧបសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ ............ ១៥

**១.២.៣. គោលការណ៍គ្រឹះនៃរដ្ឋធម្មនុញ្ញ** ............ ១៦

១.២.៣.១. ទ្រឹស្តីឯករាជ្យ និងអធិបតេយ្យ ............ ១៦

១.២.៣.២. ទ្រឹស្តីរាជានិយម ............ ១៦

១.២.៣.៣. ទ្រឹស្តីប្រជាធិបតេយ្យសេរីពហុបក្ស ............ ១៦

## ជំពូកទី២

## ការបែងចែកអំណាច

**២.១. ទ្រឹស្តីរបស់អ្នកប្រាជ្ញ** ............ ១៧

**២.១.១. លោក ចន ឡុក** (John Locke) ............ ១៧

**២.១.២. លោក ម៉ុង តេស្គីយើ** (Montesquieu) ............ ១៨

**២.២. ក្របខណ្ឌរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣** ............ ១៩

**២.២.១. ការអនុវត្តអំណាចនីតិបញ្ញត្តិ** ............ ១៩

២.២.១.១. ស្ថាប័នរដ្ឋសភា ............ ១៩

២.២.១.៣. ស្ថាប័នព្រឹទ្ធសភា ............ ៣០

**២.២.២. ការអនុវត្តអំណាចនីតិប្រតិបត្តិ** ............ ៣៨

២.២.២.១. រាជរដ្ឋាភិបាល ............ ៣៨

២.២.២.២. តួនាទីរបស់នាយករដ្ឋមន្ត្រី ............ ៣៩

**២.២.៣. ការអនុវត្តអំណាចតុលាការ** ............ ៤២

២.២.៣.១. រចនាសម្ព័ន្ធរបស់តុលាការ ............ ៤៣

២.២.៣.២. លក្ខណសម្បត្តិរបស់ចៅក្រម ............ ៤៨

# ជំពូកទី៣

# ការត្រួតពិនិត្យនៃការអនុវត្តអំណាច

**៣.១. ការត្រួតពិនិត្យដោយសភា**....................................................................................៥០

**៣.១.១. រដ្ឋសភា**....................................................................................៥០

៣.១.១.១. ការត្រួតពិនិត្យលើការបង្កើតច្បាប់....................................................................................៥០

៣.១.១.២. ការត្រួតពិនិត្យហិរញ្ញវត្ថុ....................................................................................៥២

៣.១.១.៣. ការត្រួតពិនិត្យរាជរដ្ឋាភិបាល....................................................................................៥៣

**៣.១.២. ព្រឹទ្ធសភា**....................................................................................៥៥

៣.១.២.១. ពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់....................................................................................៥៥

៣.១.២.២. កម្មវត្ថុនៃការត្រួតពិនិត្យ....................................................................................៥៧

៣.១.២.៣. វិធីត្រួតពិនិត្យ....................................................................................៥៧

**៣.២. ការត្រួតពិនិត្យដោយតុលាការ**....................................................................................៥៨

**៣.៣. ការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ**....................................................................................៥៩

**៣.៣.១. គោលការណ៍នៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់**....................................................................................៥៩

**៣.៣.២. ការត្រួតពិនិត្យធម្មនុញ្ញភាព**....................................................................................៦០

៣.៣.២.១. ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល....................................................................................៦០

៣.៣.២.២. ការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល....................................................................................៦៤

**៣.៣.៣. សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត**....................................................................................៦៥

**សេចក្តីសន្និដ្ឋាន**....................................................................................៦៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលមានប្រវត្តិសាស្ត្រ វប្បធម៌ និងអរិយធម៌ដ៏ចំណាស់ ទន្ទឹមនេះ កម្ពុជាក៏ធ្លាប់បានហែលឆ្លងកាត់នូវរបបដឹកនាំជាច្រើនសម័យកាល នេះបើគិតចាប់តាំងពីរបបអាណានិគម បារាំងរហូតមកទល់នឹងបច្ចុប្បន្ន។ នាពេលនោះកម្ពុជាបានទទួលរងនូវឥទ្ធិពលពីបារាំងតាមរយៈការដាក់ អាណានិគម ដោយមើលឃើញពីភាពជឿនលឿននៃលោកខាងលិច ទើបកម្ពុជាបានយកលំនាំតាមបស្ចិម ប្រទេសក្នុងការរៀបចំឱ្យមាននូវរដ្ឋធម្មនុញ្ញរបស់ខ្លួនដំបូងក្នុងប្រវត្តិសាស្ត្រនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧ ដោយប្រតិបត្តិតាមរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ តាមទម្រង់សាធារណរដ្ឋបារាំងទី៤ និងចក្រភព អង់គ្លេស។ តាមរយៈនេះ រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៤៧ បានចែងបញ្ញត្តិនូវការបែងចែកអំណាចជាបីដាច់ពី គ្នារួមមាន អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ព្រមជាមួយនឹងការកំណត់នូវសិទ្ធិ សេរីភាព និងករណីយកិច្ចរបស់ពលរដ្ឋខ្មែរគ្រប់រូប។

យ៉ាងណាមិញ រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៤៧ ពុំមានស្ថិរភាពទេ ពីព្រោះមានការរំខានដោយវិបត្តិនយោបាយ ផ្ទៃក្នុង ពោលស្ថានភាពកម្ពុជានាពេលនោះ ម្ខាងមាននិន្នាការឆ្វេងនិយម និងម្ខាងទៀតមាននិន្នាការស្តាំនិយម ដែលជាដើមចមនៃអស្ថិរភាពនយោបាយ និងធ្វើឱ្យប្រព័ន្ធពហុបក្សបានដួលរលំជាច្រើនលើក និងជំនួសវិញ ដោយចលនាសង្គមរាស្ត្រនិយមតាមបែបប្រជាធិបតេយ្យប្រមូលផ្តុំ។ យ៉ាងណាមិញ សង្គមរាស្ត្រនិយមត្រូវបាន បញ្ចប់តាមរយៈការធ្វើរដ្ឋប្រហារដោយលោកសេនាប្រមុខ លន់ នល់ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ហើយ រដ្ឋធម្មនុញ្ញទី២ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ ដោយប្តូរពីរបបរាជានិយមមកជា របបសាធារណរដ្ឋខ្មែរវិញ។ របបសាធារណរដ្ឋខ្មែរនេះទៀតសោត ត្រូវបានផ្តួលរលំដោយកងទ័ពខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជំនួសមកវិញនូវរបបផ្តាច់ការ ដែលមានឈ្មោះជាផ្លូវការថា កម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦។ រយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ របបកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ចប់ ហើយ ត្រូវបានជំនួសដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១។ ក្រោយមក ទៀត នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ កម្ពុជាបានប្តូរឈ្មោះមក រដ្ឋកម្ពុជាវិញ។

រហូតដល់ឆ្នាំ១៩៩៣ ដោយមានការសម្របសម្រួលពីអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ នៅកម្ពុជា ឬហៅកាត់ អ៊ុនតាក់ (UNTAC) បានរៀបចំឱ្យមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយ បានបង្កើតបានសភាធម្មនុញ្ញមួយ ដើម្បីរៀបចំតាក់តែង និងអនុម័តនូវរដ្ឋធម្មនុញ្ញមួយ ដែលជារដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាទី២ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលជារបត់ថ្មីមួយ នាំកម្ពុជាឆ្ពោះទៅរកមាគ៌ានៃលទ្ធិប្រជាធិបតេយ្យ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រធានបទ **ការបែងចែកអំណាចទាំងបី អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣** ពិតជាមានសារប្រយោជន៍ជាច្រើនដល់សិស្សនិស្សិតបញ្ញវន្ត និងសាធារណជនទាំងអស់ ដើម្បីធ្វើការស្វែងយល់ថាតើរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ មានការបែងចែកអំណាចយ៉ាងដូចម្តេច? ដែលបញ្ហាទាំងអស់នេះ សុទ្ធតែជាកត្តាចម្បងៗដែលគួរតែស្វែងយល់ជាមួយនឹងការស្រាវជ្រាវមួយនេះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទ **ការបែងចែកអំណាចទាំងបី អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣** ត្រូវបានជ្រើសរើសដោយយើងខ្ញុំទាំងពីររូប ព្រមទាំងមានការឯកភាពពីលោកគ្រូណែនាំ។ ចំពោះគោលបំណងចម្បងក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺដើម្បីឆ្លុះបញ្ចាំងអំពីដំណើរការប្រព្រឹត្តទៅនៃស្ថាប័នអំណាចទាំងបី ផ្អែកតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលជាសមិទ្ធផលនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ជាពិសេស ក្រោមការសម្របសម្រួលរបស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា ឬហៅកាត់ថា អ៊ុនតាក់ (UNTAC) បានធ្វើឱ្យកម្ពុជាបើកទំព័រប្រវត្តិសាស្ត្រខ្លួនក្នុងការដំណើរការកសាងលទ្ធិប្រជាធិបតេយ្យ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទ **ការបែងចែកអំណាចទាំងបី អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣** ត្រូវបានសិក្សាស្រាវជ្រាវគ្របដណ្តប់តែទៅលើក្របខណ្ឌនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ចាប់តាំងប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ រហូតមកទល់បច្ចុប្បន្ន។ បន្ថែមពីនេះ ការសិក្សាស្រាវជ្រាវនេះ ក៏មានវិសាលភាពលើច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានា និងឯកសារផ្សេងៗទៀតដែលទាក់ទងផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ជាទូទៅ ការសិក្សាស្រាវជ្រាវតែងតែមានគុណតម្លៃដល់អ្នកសិក្សាគ្រប់រូបលើប្រធានបទ ឬជំនាញដែលខ្លួនជ្រើសរើស មានន័យថា សារប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ដំបូងគឺឱ្យអ្នកស្រាវជ្រាវបានយល់ដឹង និងចងចាំបានច្បាស់ ហើយកាន់តែលម្អិតលើប្រធានបទ បន្ទាប់មកវាក៏បានផ្តល់សារប្រយោជន៍ជាច្រើនទៀតដល់អ្នកអាន និងសាធារណជនទាំងឡាយ ដែលបានអាននូវស្នាដៃកិច្ចស្រាវជ្រាវនេះ។ សារប្រយោជន៍ទាំងនេះ រួមមាន៖

### ក. ប្រយោជន៍សម្រាប់សាកលវិទ្យាល័យ

- សាកលវិទ្យាល័យទទួលបានឯកសារសម្រាប់តម្កល់ទុក
- និស្សិតបានប្រតិបត្តិតាមទិសដៅរបស់សាកលវិទ្យាល័យក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ
- និស្សិតបានស្វែងយល់កាន់តែច្បាស់ពីក្របខណ្ឌរដ្ឋធម្មនុញ្ញ ច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ

- និស្សិតបានស្វែងយល់បន្ថែមនូវទ្រឹស្តីរបស់អ្នកប្រាជ្ញមួយចំនួនពាក់ព័ន្ធរដ្ឋធម្មនុញ្ញ
- និស្សិតបានស្វែងយល់កាន់តែច្បាស់ពីរបបនយោបាយបែបប្រជាធិបតេយ្យ
- និស្សិតបានចូលរួមចំណែកដោយផ្ទាល់ក្នុងការជួយពង្រឹងលទ្ធិប្រជាធិបតេយ្យនៅក្នុងសង្គមជាតិ។

**ខ. ប្រយោជន៍សម្រាប់សង្គម និងសាធារណជន**

- ទុកជាឯកសារសម្រាប់សាធារណជនងាយស្រួលស្រាវជ្រាវកិច្ចការពាក់ព័ន្ធនឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣
- ស្វែងយល់បន្ថែមពីគោលការណ៍នៃការបែងចែកអំណាចក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣
- ស្វែងយល់បន្ថែមពីការត្រួតពិនិត្យនៃការបែងចែកអំណាចក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញកម្ពុជា១៩៩៣
- ចូលរួមពង្រឹងនីតិរដ្ឋនៅកម្ពុជាតាមរយៈការលើកកម្ពស់ការយល់ដឹង និងការអនុវត្តច្បាប់។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ប្រធានបទ **ការបែងចែកអំណាចទាំងបី អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣** ត្រូវបានសិក្សាស្រាវជ្រាវ និងចងក្រងឡើងដោយផ្អែកលើទិន្នន័យ និងព័ត៌មានសំខាន់ៗ ដូចជាលិខិតបទដ្ឋានគតិយុត្តមានដូចជា រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងប្រធានបទ។

បន្ថែមពីនេះទៅទៀត ក្រៅពីលិខិតបទដ្ឋានគតិយុត្ត ការសិក្សាស្រាវជ្រាវនេះ ក៏ផ្អែកលើឯកសារ ស្នាដៃនិពន្ធពាក់ព័ន្ធ ព្រមទាំងប្រព័ន្ធអេឡិចត្រូនិចដូចជា៖ មានប្រព័ន្ធអ៊ីនធឺណែត បណ្តាញសង្គម និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។ ជាពិសេស យើងខ្ញុំបានសុំអនុសាសន៍ និងការណែនាំពីលោកគ្រូណែនាំ ព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងអ្នកមានបទពិសោធពាក់ព័ន្ធនឹងនីតិរដ្ឋធម្មនុញ្ញ ទ្រឹស្តីរដ្ឋសាធារណៈ និងវិទ្យាសាស្ត្រនយោបាយជាដើម ដើម្បីឱ្យការស្រាវជ្រាវកាន់តែមានភាពស៊ីជម្រៅ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវក្រោមប្រធានបទ **ការបែងចែកអំណាចទាំងបី អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣** នេះត្រូវបានចងក្រងចែកចេញតាមប្លង់ដូចខាងក្រោម៖

- **ជំពូកទី១ "រំលឹកទ្រឹស្តី"**
- **ជំពូកទី២ "ការបែងចែកអំណាច"**
- **ជំពូកទី៣ "ការត្រួតពិនិត្យនៃការអនុវត្តអំណាច"**

# ជំពូកទី១

# រំលឹកត្រីស្ដី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. សញ្ញាណទូទៅនៃរដ្ឋធម្មនុញ្ញ

នៅក្នុងដំណើរការគ្រប់គ្រងរដ្ឋ ឬសង្គមឱ្យមានរបៀបរៀបរយសណ្តាប់ធ្នាប់ល្អត្រូវតែមានច្បាប់មួយជាមូលដ្ឋានគ្រឹះ ទោះបីរដ្ឋនោះប្រកាន់នូវរបបនយោបាយអ្វីក៏ដោយ ដូច្នេះបានជាអ្នកច្បាប់មួយចំនួនគេទាមទារឱ្យបង្កើតនូវរដ្ឋធម្មនុញ្ញ ពីព្រោះវាជាលក្ខន្តិកៈគតិយុត្តនៃរដ្ឋមួយ។[1]

### ១.១.១. ប្រវត្តិនៃរដ្ឋធម្មនុញ្ញ

នៅក្នុងការសិក្សាផ្នែកប្រវត្តិនៃរដ្ឋធម្មនុញ្ញនេះត្រូវបានចែកចេញជាពីរ ចំណុចសំខាន់ៗរួមមាន៖ ទីមួយ រដ្ឋធម្មនុញ្ញសម័យបុរាណ និងទីពីរ រដ្ឋធម្មនុញ្ញសម័យទំនើប។

#### ១.១.១.១. រដ្ឋធម្មនុញ្ញសម័យបុរាណ

នៅសម័យបុរាណដោយសារមនុស្សពុំទាន់យល់ច្បាស់ពីការប្រើប្រាស់អត្ថបទច្បាប់នៅឡើយ ការគ្រប់គ្រងសង្គមពុំមានអ្វីកំណត់អំពីអំណាចបានឡើយ។ ដូច្នេះវិធាននៃការគ្រប់គ្រងសង្គម និងការដំណើរការនៃស្ថាប័ននានារបស់រដ្ឋ គឺត្រូវបានពឹងផ្អែកជាសំខាន់ទៅលើទំនៀមទម្លាប់ប្រពៃណី ដែលជាខ្នាតសម្រាប់រង្វាស់រង្វាល់ និងជាឧបករណ៍កំណត់នូវរបៀបនៃការគ្រប់គ្រងរដ្ឋ។ ក្នុងន័យនេះ គេអាចនិយាយបានថា ប្រភពដើមរដ្ឋធម្មនុញ្ញ គឺកើតចេញពីប្រពៃណីទំនៀមទម្លាប់នេះឯង។

ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ អត្ថបទសរសេរត្រូវបានគេបញ្ចូលបន្តិចម្តងៗចូលទៅក្នុងរដ្ឋធម្មនុញ្ញដែលមានលក្ខណៈជាទំនៀមទម្លាប់ ដើម្បីមានភាពងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋ និងការកំណត់គោលការណ៍នៃការប្រព្រឹត្តទៅនៃអំណាចរដ្ឋ។ ដូច្នេះនាពេលនោះ សមាសធាតុនៃរដ្ឋធម្មនុញ្ញ គឺផ្អែកលើការសរសេរផង និងផ្អែកលើធាតុប្រពៃណីទំនៀមទម្លាប់ផង។

រដ្ឋធម្មនុញ្ញជាអត្ថបទដំបូងគេបំផុត គឺមានដើមកំណើតនៅប្រទេសក្រិច ក្នុងរវាងសតវត្សរ៍ទី៧ និងសតវត្សរ៍ទី៨ មុនគ្រិស្តសករាជ ហើយបន្ទាប់មកពួករ៉ូមមាំង នៅទីក្រុងរ៉ូម បានបង្កើតឡើងនូវអត្ថបទរដ្ឋធម្មនុញ្ញរបស់ខ្លួនដោយបានចែងយ៉ាងលម្អិតអំពីដំណើរការ និងការប្រព្រឹត្តទៅរបស់ស្ថាប័ននយោបាយរបស់រដ្ឋ។[2]

#### ១.១.១.២. រដ្ឋធម្មនុញ្ញសម័យទំនើប

ឆ្លងកាត់នូវរយៈពេលជាច្រើនសតវត្សរ៍កន្លងមក ទើបមានការចាប់កំណើតនូវរដ្ឋធម្មនុញ្ញទំនើបនៅចុងសតវត្សរ៍ទី១៨ នៃគ្រិស្តសករាជ។ ហើយការចាប់កំណើតរដ្ឋធម្មនុញ្ញទំនើបមុនគេបង្អស់ ត្រូវបានបង្កើតឡើង

---

[1] សុខ ចិន្តា និងសុខ យ៉ាន, *នីតិរដ្ឋធម្មនុញ្ញ* (២០២១), ៥០។

[2] ឌី ពុទ្ធារ៉ា, ទ្រឹស្តីរដ្ឋ (២០២២), ២។

ដោយសហរដ្ឋអាមេរិចនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៧៧៦ រហូតដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៧៨៧ គម្រោងរដ្ឋធម្មនុញ្ញនេះបានក្លាយជារដ្ឋធម្មនុញ្ញរបស់សហព័ន្ធ។ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៧៩១ ប្រទេសប៉ូឡូញបានប្រកាសឱ្យប្រើនូវរដ្ឋធម្មនុញ្ញរបស់ខ្លួនចំណែកឯប្រទេសបារាំងបានអនុម័តរដ្ឋធម្មនុញ្ញ និងប្រកាសប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៧៩១។ ហើយប្រទេសនានាដែលមានការរីកលូតលាស់ បានរៀបចំនូវរដ្ឋធម្មនុញ្ញរបស់ខ្លួនជាបន្តបន្ទាប់រួមមាន ប្រទេសស៊ុយអែត នៅឆ្នាំ១៨០៩ ប្រទេសវេណេស៊ុយអេឡា នៅឆ្នាំ១៨១១ និងប្រទេសអេស្ប៉ាញ នៅឆ្នាំ១៨១២ ជាដើម។

បន្តិចម្តងៗ គោលគំនិតវិធាននៃការគ្រប់គ្រងរដ្ឋ ត្រូវភ្ជាប់ទៅនឹងរដ្ឋធម្មនុញ្ញដែលមានចែង និងចារឹកទុកយ៉ាងច្បាស់លាស់សម្រាប់អនុវត្ត។ ហើយគោលការណ៍ជាមូលដ្ឋាន និងតួនាទីរបស់រដ្ឋធម្មនុញ្ញកាន់តែមានការរីកចម្រើន និងធ្វើបដិវត្តន៍កម្មឈានឡើងជាលំដាប់ចាប់ពីឆ្នាំ១៨៣០ និងឆ្នាំ១៨៤៨ និងបន្ទាប់ពីការបញ្ចប់នូវសង្គ្រាមលោកលើទី២ និងការបញ្ចប់នូវរបបអាណានិគមនិយមនៅលើពិភពលោក។ តាមរយៈនេះបណ្តារដ្ឋជាច្រើនដែលទើបតែទទួលបានឯករាជ្យ បានរៀបចំឱ្យមានយន្តការដំណើរការស្ថាប័នរបស់ខ្លួនតាមរយៈការតាក់តែងរដ្ឋធម្មនុញ្ញរបស់ខ្លួន ដែលជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់គ្រងរដ្ឋរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនេះដែរបណ្តារដ្ឋទាំងឡាយ ដែលមានរដ្ឋធម្មនុញ្ញតាមបែបបុរាណបានធ្វើទំនើបកម្មលើរដ្ឋធម្មនុញ្ញរបស់ខ្លួនដើម្បីសម្របតាមទិដ្ឋភាពថ្មីរបស់ពិភពលោកផងដែរ។[3]

### ១.១.២. និយមន័យ

ប្រសិនបើគេសង្កេតមើលជាទូទៅនៃរដ្ឋធម្មនុញ្ញ នោះគេអាចកំណត់បានថា រដ្ឋធម្មនុញ្ញជាប្រព័ន្ធមួយនៃបទដ្ឋានគតិយុត្ត ដែលមានកម្លាំងអានុភាពគតិយុត្តខ្ពស់ និងធ្វើនិយ័តកម្មទៅលើមូលដ្ឋានគ្រឹះទាំងឡាយនៃគ្រប់ទំនាក់ទំនងរបស់មនុស្ស និងសង្គម ។

#### ១.១.២.១. តាមវចនានុក្រម និងច្បាប់

បើគេពិនិត្យនៅក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត [រដ្ឋធម្មនុញ្ញ = រដ្ឋ + ធម្មនុញ្ញ] មានន័យថាជាច្បាប់គោលរបស់រដ្ឋ។[4] ក្នុងបរិបទនេះ ក៏ស្របទៅនឹងមាត្រា១៥២ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ បច្ចុប្បន្នចែងថា រដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ហើយច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។[5]

[3] ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ រោងពុម្ពដារ៉ា,២០១៦), ៣២។

[4] *វចនានុក្រមសម្តេច ជួន ណាត បោះពុម្ពឆ្នាំ១៩៣៨ នៅទំព័រទី ១០០៦។*

[5] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ១៩៩៩, មាត្រា១៥២ (ថ្មី)។

**១.១.២.២. តាមន័យទម្រង់ និងសម្ភារៈ**

រដ្ឋធម្មនុញ្ញក៏អាចត្រូវបានកំណត់នូវខ្លឹមសារ តាមអត្ថន័យចំនួនពីរ (០២) រួមមាន៖

**តាមន័យទម្រង់៖** រដ្ឋធម្មនុញ្ញ គឺជាកម្រងឯកសារគតិយុត្តមួយ ដែលនិយាយអំពីស្ថាប័ននយោបាយដែលគេបានរៀបចំតាក់តែងឡើង និងធ្វើវិសោធនកម្មគោរពតាមនីតិវិធីដែលមានលក្ខណៈខុសពីច្បាប់ធម្មតា។[6]

**តាមន័យសម្ភារៈ៖** រដ្ឋធម្មនុញ្ញ គឺជាច្បាប់គ្រឹះ និងជាច្បាប់កំពូលរបស់រដ្ឋ ដែលជាទូទៅកំណត់នូវ រចនាសម្ព័ន្ធ និងមុខងារសំខាន់ៗជាមូលដ្ឋានរបស់រដ្ឋ ព្រមទាំងកំណត់នូវសិទ្ធិ និងកាតព្វកិច្ចជាមូលដ្ឋានរបស់ពលរដ្ឋ។[7]

**១.១.២.៣. ស្នាដៃនិពន្ធ**

យោងតាមសៀវភៅសេចក្ដីផ្ដើមនីតិ ដែលរៀបរៀងដោយសាស្ត្រាចារ្យបណ្ឌិត ឈុន ណារ៉េត បានផ្ដល់អត្ថន័យថារដ្ឋធម្មនុញ្ញ ជាប្រភពដើមនៃអំណាចរដ្ឋ ដែលកើតចេញពីប្រជាពលរដ្ឋ ជាច្បាប់កំពូលដែលមានឋានៈខ្ពស់បំផុតនៅក្នុងប្រព័ន្ធច្បាប់ប្រទេស និងជាប្រភពនៃលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។[8]

យោងតាមសៀវភៅនីតិរដ្ឋធម្មនុញ្ញប្រៀបធៀប ដែលរៀបរៀងដោយសាស្ត្រាចារ្យ ម៉ុក ដារ៉ា បានផ្ដល់អត្ថន័យថា រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូល ឬច្បាប់គ្រឹះរបស់រដ្ឋ ដែលត្រូវបង្កើតតាមនីតិវិធីពិសេសមួយ ហើយច្បាប់ និងសេចក្ដីសម្រេចត្រូវស្របនឹងរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញនេះទៀតសោត បានសរសេរចំណុចសំខាន់ៗ ដែលពាក់ព័ន្ធនឹងរបបនយោបាយ ការបែងចែកអំណាចរបស់រដ្ឋ មុខងាររបស់ស្ថាប័ននីមួយៗ វិស័យនានារបស់រដ្ឋ និងចំណុចសំខាន់ៗមួយចំនួនទៀតតែប៉ុណ្ណោះ។[9]

យោងតាមសៀវភៅមូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ ដែលរៀបរៀងដោយសាស្ត្រាចារ្យបណ្ឌិត ឥន យឿន បានផ្ដល់អត្ថន័យថា រដ្ឋធម្មនុញ្ញជាច្បាប់មូលដ្ឋានរបស់ជាតិ ឬរដ្ឋ ដែលសរសេរលាយលក្ខណ៍អក្សរ ឬមិនសរសេរជាលាយលក្ខណ៍អក្សរ បង្កើតបានជាចារីក និងទស្សនៈរបស់រដ្ឋាភិបាលនៃជាតិ ឬរដ្ឋនោះដាក់ចេញនូវគោលការណ៍ជាមូលដ្ឋានដែលជីវភាពផ្ទៃក្នុងរបស់ជាតិ ឬរដ្ឋនោះត្រូវតែប្រកាន់យកតាមរយៈការរៀបចំរដ្ឋាភិបាល និងការចាត់ចែងការបែងចែក និងការកម្រិតមុខងារនៃក្រសួងផ្សេងៗរបស់រដ្ឋ ឬប្រទេសនោះ ដែលចែងជាបទប្បញ្ញត្តិស្ដីអំពីទំហំ និងរបៀបរៀបរយនៃការអនុវត្តអំណាចអធិបតេយ្យ។[10]

---

[6] សុខ ចិន្តា និងសុខ យ៉ាន, *នីតិរដ្ឋធម្មនុញ្ញ* (២០២១), ៤០។

[7] ឥន យឿន, *ទាក់ទងនឹងវិស័យច្បាប់* (ភ្នំពេញ៖ ក្រុមសៀវភៅ ISB, ២០២១), ១៨។

[8] ឈុន ណារ៉េត, *សេចក្ដីផ្ដើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ រោងពុម្ពដារ៉ា,២០១៦), ១២។

[9] ម៉ុក ដារ៉ា, *នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប* (២០២៤), ២។

[10] ឥន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨), ៩។

## ១.១.៣. ទម្រង់ និងប្រភេទនៃរដ្ឋធម្មនុញ្ញ

### ១.១.៣.១. ទម្រង់នៃរដ្ឋធម្មនុញ្ញ

ដោយផ្អែកលើការវិវត្តខាងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងរបស់បណ្តារដ្ឋទាំងអស់ រួមទាំងជាមួយនឹងតួនាទីជាសារវន្តរបស់រដ្ឋធម្មនុញ្ញរហូតមកដល់ពេលនេះ គេអាចបែងចែកទម្រង់រដ្ឋធម្មនុញ្ញចំនួនពីររួមមានៈ

**ក. រដ្ឋធម្មនុញ្ញសរសេរ**

ទម្រង់រដ្ឋធម្មនុញ្ញសរសេរ (Written Constitution-USA Model) គឺជាទម្រង់រដ្ឋធម្មនុញ្ញមួយ ដែលនៅក្នុងបណ្តាប្រទេសជាច្រើននៅលើពិភពលោកកំពុងប្រើប្រាស់ជាច្បាប់គោល ឬជាច្បាប់កំពូលរបស់ប្រទេស ដែលត្រូវបានចងក្រង ហើយនៅក្នុងបណ្តាគោលការណ៍គ្រឹះសំខាន់ៗដែលត្រូវបានតាក់តែង និងអនុម័តដោយអង្គការពិសេសណាមួយ (សភាធម្មនុញ្ញ) មុននឹងយកមកអនុវត្ត។[11] ឧទាហរណ៍ជាក់ស្តែង រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញសរសេរ ដែលតាក់តែងឡើង និងអនុម័តដោយសភាធម្មនុញ្ញ។

**ខ. រដ្ឋធម្មនុញ្ញឥតសរសេរ**

ទម្រង់រដ្ឋធម្មនុញ្ញឥតសរសេរ (Unwritten Constitution-UK Model) គឺជាទម្រង់រដ្ឋធម្មនុញ្ញមួយ ដែលចងក្រងពីទំនៀមទម្លាប់(Customary) ឬក៏ទម្លាប់ល្អទាំងឡាយណា ដែលទាក់ទងទៅនឹងការគ្រប់គ្រងរដ្ឋ។ ក្នុងនោះបណ្តាគោលការណ៍គ្រឹះសំខាន់ៗខ្លះត្រូវបានវិវត្តចេញពីភាពជាក់ស្តែង ហើយវាត្រូវបានទទួលស្គាល់ដោយតុលាការ និងខ្លះទៀតវិវត្តមកពីក្រមដែលបានអនុម័ត។ ជាឧទាហរណ៍ រដ្ឋធម្មនុញ្ញរបស់ប្រទេសអង់គ្លេសជារដ្ឋធម្មនុញ្ញឥតសរសេរ ដែលត្រូវបានចងក្រងពីទំនៀមទម្លាប់។

ជារួមមក រដ្ឋធម្មនុញ្ញសរសេរ និងរដ្ឋធម្មនុញ្ញឥតសរសេរ មានលក្ខណៈខុសគ្នាត្រង់ថា ទម្រង់រដ្ឋធម្មនុញ្ញឥតសរសេរ គឺជារដ្ឋធម្មនុញ្ញ ដែលមិនមែនបង្កើតឡើងដោយស្ថាប័ន ឬអង្គការសភាធម្មនុញ្ញ ពោលគឺ កើតឡើងដោយទំនៀមទម្លាប់ប្រពៃណីច្បាប់ដែលដូនតាគេបានបង្កើតមក។ ហើយត្រង់ចំណុចណាមួយ ដែលមិនផ្តល់ផលប្រយោជន៍សម្រាប់ជាតិទេនោះ គេគ្រាន់តែវិសោធនកម្មលុបចោលតែប៉ុណ្ណោះ។ ហើយប្រទេសដែលអនុវត្តរដ្ឋធម្មនុញ្ញប្រភេទនេះ មានដូចជាប្រទេសអង់គ្លេសជាដើម។ ចំណែកឯរដ្ឋធម្មនុញ្ញសរសេរ គឺជារដ្ឋធម្មនុញ្ញ ដែលបង្កើតឡើងដោយស្ថាប័ន ឬអង្គការសភាធម្មនុញ្ញដែលមិនកើតឡើងដោយប្រពៃណីទំនៀមទម្លាប់ឡើយ តួយ៉ាងករណីដូចកម្ពុជាក៏អនុវត្តរដ្ឋធម្មនុញ្ញសរសេរនេះដែរ។[12]

[11] ជីង ផេងស្រួយ, *នីតិរដ្ឋធម្មនុញ្ញ* (២០១១), ៣៥។

[12] ឌី ពុទ្ធារ៉ា, *ទ្រឹស្តីរដ្ឋ* (២០២២), ១៣។

**១.១.៣.២. ប្រភេទនៃរដ្ឋធម្មនុញ្ញ**

តាមគោលការណ៍នៃនីតិរដ្ឋធម្មនុញ្ញ គេបែងចែករដ្ឋធម្មនុញ្ញជាពីរប្រភេទរួមមាន៖ ទីមួយ រដ្ឋធម្មនុញ្ញរឹង ឬតឹង និងទីពីរ រដ្ឋធម្មនុញ្ញទន់ ឬធូរ។

**ក. រដ្ឋធម្មនុញ្ញរឹង ឬតឹង**

រដ្ឋធម្មនុញ្ញរឹង ឬតឹង គឺជារដ្ឋធម្មនុញ្ញដែលពិបាកកែប្រែ ឬធ្វើវិសោធនកម្មដែលមានការកំណត់លក្ខខណ្ឌតឹងរឹងដូចជា បង្កើតឱ្យមានលក្ខខណ្ឌនីតិវិធីនៃការដាក់សំណើ ដំណើរការអនុម័ត និងលក្ខខណ្ឌសម្លេងអនុម័ត ត្រូវតែខ្ពស់ដូចជា ពីរភាគបី (២/៣) ឬបីភាគបួន (៣/៤) ព្រមទាំងមានការហាមមិនឱ្យធ្វើវិសោធនកម្មនូវមាត្រាមួយចំនួនជាដើម។ ដូច្នេះហើយភាពខុសគ្នាខាងអង្គការចាត់តាំង ឬផ្នែកនីតិវិធីរវាងរដ្ឋធម្មនុញ្ញ និងច្បាប់ធម្មតាបានបង្ហាញពីឧត្តមភាពរបស់រដ្ឋធម្មនុញ្ញដែលមានទីតាំងឋានានុក្រមខ្ពស់ជាងច្បាប់ទូទៅ។[13]

**ខ. រដ្ឋធម្មនុញ្ញទន់ ឬធូរ**

រដ្ឋធម្មនុញ្ញទន់ ឬធូរ គឺជារដ្ឋធម្មនុញ្ញ ដែលមានភាពងាយស្រួលក្នុងការកែប្រែ គឺដូចទៅនឹងច្បាប់ធម្មតាទាំងនីតិវិធី និងចំនួនសម្លេងអនុម័ត ដូចជាយកហាសិបភាគរយបូកមួយ (៥0%+១) ជាដើម ដោយគ្មានការដាក់កម្រិតអំពីចំនួនសម្លេងកែប្រែដូចជា ពីរភាគបី (២/៣) ឬបីភាគបួន (៣/៤) ឬដាក់លក្ខខណ្ឌបម្រាមផ្សេងៗថែមទៀតនោះទេ។[14]

**១.១.៤. អំណាច និងសារៈសំខាន់នៃរដ្ឋធម្មនុញ្ញ**

គ្រប់រដ្ឋធម្មនុញ្ញទាំងឡាយនៅលើពិភពលោកតាំងពីរដ្ឋធម្មនុញ្ញសម័យបុរាណមកដល់រដ្ឋធម្មនុញ្ញសម័យទំនើបតែងតែរំលេចឡើងនូវអំណាចនៃឋានានុក្រមរបស់ខ្លួន និងពិសេសបំផុតនោះគឺសារៈសំខាន់នៃរដ្ឋធម្មនុញ្ញ។

**១.១.៤.១. អំណាចនៃរដ្ឋធម្មនុញ្ញ**

នៅក្នុងរដ្ឋធម្មនុញ្ញទំនើបទាំងឡាយ រដ្ឋធម្មនុញ្ញ គឺជាលិខិតដែលមានអំណាចខ្ពស់បំផុត។ នៅក្នុងន័យនេះ នីតិវិធីនានាត្រូវបានរៀបចំឡើង គឺដើម្បីគោរពទៅតាមរដ្ឋធម្មនុញ្ញ។ នៅគ្រប់រដ្ឋទាំងអស់នៅលើពិភពលោកតែងតែមានច្បាប់គ្រឹះរៀងៗខ្លួន ដើម្បីគ្រប់គ្រងប្រទេសប្រកបដោយនីតិរដ្ឋ។ ច្បាប់គ្រឹះដែលគេសំដៅនោះ គឺរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេស។ ដោយឡែក ចំពោះកម្ពុជាក៏មិនខុសពីបណ្តាប្រទេសនានានៅលើពិភពលោកប៉ុន្មានដែរ ដោយមានរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល និងជាលិខិតបទដ្ឋានត្រូវបានគេដាក់ឱ្យនៅខ្ពស់ជាងលិខិតបទដ្ឋាន ឬវិធានគតិយុត្តនានាទាំងអស់រួមទាំងសន្ធិសញ្ញាអន្តរជាតិផងដែរ ដើម្បីធានាថាលិខិតបទដ្ឋានគតិយុត្តដែលបានបង្កើតមុន និងក្រោយរដ្ឋធម្មនុញ្ញចូលជាធរមានមិនត្រូវចែងផ្ទុយ ឬមកនិរាករណ៍រដ្ឋធម្មនុញ្ញបានឡើយ។ ជាក់ស្តែងបើតាមទ្រឹស្តីរបស់លោក ហាន្ស កែលសិន (HANS KELSEN) ជនជាតិអូទ្រីស ដែលជាអ្នកបង្កើត

---

[13] តន យឿន, *ទាក់ទាងនឹងវិស័យច្បាប់* (២០២១), ២២។

[14] សេង ប៊ុនធឿន, *នីតិរដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជា* (២០១៥), ១១។

ឋានានុក្រមនៃច្បាប់ លោកបានចាត់ថ្នាក់រដ្ឋធម្មនុញ្ញ គឺជាវិធានគតិយុត្តដែលស្ថិតនៅខ្ពស់ជាងគេនៃតារាងសាជីជ្រុង នៅត្រង់ចំណុចនេះសបញ្ជាក់ឱ្យឃើញថាមានតែរដ្ឋធម្មនុញ្ញទេ ជាច្បាប់កំពូល ឬជាច្បាប់គ្រឹះ ដែលបទដ្ឋានគតិយុត្ត ទាំងឡាយត្រូវគោរពតាម។[15]

**១.១.៤.២. សារៈសំខាន់នៃរដ្ឋធម្មនុញ្ញ**

តាមរយៈអត្ថន័យខាងលើ គេអាចកំណត់បានថា រដ្ឋធម្មនុញ្ញតែមួយ មិនអាចធ្វើឱ្យការគ្រប់គ្រងរដ្ឋប្រព្រឹត្តទៅ បានដោយភាពល្អប្រសើរឡើយ ពីព្រោះថារដ្ឋធម្មនុញ្ញនេះមិនបានចែងអំពីករណីលម្អិតនៃច្បាប់នីមួយៗ គ្រប់វិស័យដោយឡែកៗពីគ្នាបានឡើយ។ ដូច្នេះដើម្បីធ្វើការគ្រប់គ្រងរដ្ឋមួយឱ្យមានសណ្ដាប់ធ្នាប់ល្អ និងមាន ប្រសិទ្ធភាព ឬការអភិវឌ្ឍឱ្យបានគ្រប់វិស័យរបស់ជាតិនោះ អ្នកច្បាប់ ឬអង្គការនីតិបញ្ញត្តិតែងតែធ្វើការត្រិះរិះ ពិចារណាលៃលកឱ្យបានគ្រប់ជ្រុងជ្រោយថា តើវិស័យណាត្រូវធ្វើច្បាប់ណា ហើយករណីណាត្រូវយកបទប្បញ្ញត្តិ ណាទៅអនុវត្តមុន។ គ្រប់ប្រទេសដែលប្រកាន់របបប្រជាធិបតេយ្យ មតិប្រជារាស្ត្រ ដែលជាម្ចាស់ឆ្នោតត្រូវបាន គេយកចិត្តទុកដាក់ជាចម្បង។ អនុលោមតាមការចាំបាច់នៃវិស័យសំខាន់ៗរបស់សង្គមជាតិ មាត្រាទាំងឡាយនៃ រដ្ឋធម្មនុញ្ញជាគោលដៅចម្បង ឬមូលដ្ឋានរបស់ច្បាប់ពិសេសណាមួយ ដើម្បីជាមូលបទ ឬជាច្បាប់យោង ដែល នឹងត្រូវចែងយ៉ាងលម្អិតអំពីវិធីណាមួយនោះ។[16]

**១.១.៥. តម្លៃនៃរដ្ឋធម្មនុញ្ញ**

តម្លៃរដ្ឋធម្មនុញ្ញមានចំនួនបីសំខាន់ៗដូចជា៖ ទីមួយ តម្លៃជានិមិត្តរូប(១.១.៥.១) ទីពីរ តម្លៃជាទស្សនវិជ្ជា (១.១.៥.២) និងទីបី តម្លៃជាច្បាប់(១.១.៥.៣)។

**១.១.៥.១. តម្លៃជានិមិត្តរូប**

រដ្ឋធម្មនុញ្ញមានតម្លៃជានិមិត្តរូប គឺមានន័យថារដ្ឋធម្មនុញ្ញជានិមិត្តរូប មុនច្បាប់ផ្សេងៗទៀតទាំងអស់ ដោយក្នុង នោះរដ្ឋធម្មនុញ្ញបានដើរតួនាទីយ៉ាងសំខាន់ណាស់ក្នុងការបង្កើតរដ្ឋ។ ភាពជានិមិត្តរូបនេះ មិនបានកំណត់ត្រឹមថា ជាការបង្កើតរដ្ឋនោះទេ វាក៏បានបង្ហាញអំពីការផ្លាស់ប្ដូរនៃរបបនយោបាយផងដែរ ឬគេអាចនិយាយបានថាជាច្បាប់ នៃការបង្កើតនូវរបបថ្មី។[17] ជាពិសេស មុននឹងក្លាយជាតម្លៃគតិយុត្ត រដ្ឋធម្មនុញ្ញមានតម្លៃជានិមិត្តរូបនៃការកកើត រដ្ឋថ្មីរួចមកហើយ ហើយវាក៏ប្រាកដណាស់ដែលថាជាការបង្ហាញពីការផ្លាស់ប្ដូរនូវរបបនយោបាយផងដែរ។ ហេតុដូច្នេះហើយ គេតែងតែឃើញរដ្ឋធម្មនុញ្ញដោយឡែកពីគ្នា នៅពេលមានការផ្លាស់ប្ដូររបបនយោបាយ។ ជាឧទាហរណ៍ ជាក់ស្ដែងនៅគ្រប់ការផ្លាស់ប្ដូររបបនយោបាយរបស់ខ្មែរពីអតីតកាលសុទ្ធតែមានលេចឡើង

[15] សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦), ១៥៦,១៥៧។

[16] សេង ប៊ុនធឿន, *នីតិរដ្ឋធម្មនុញ្ញ និងការផ្លាស់ប្ដូររបបនយោបាយប្រទេសកម្ពុជា* (២០១៥), ៨។

[17] ម៉ែន វុធ, *នីតិរដ្ឋធម្មនុញ្ញ និងស្ថាប័ននយោបាយ* (២០២០), ១៣។

នូវរដ្ឋធម្មនុញ្ញសម្រាប់តំណាងឱ្យរបបនីមួយៗ។ ទាំងអស់នេះសុទ្ធតែបានបង្ហាញពីរបបនយោបាយថ្មីមួយ ហើយគេក៏តែងតែឃើញវត្តមានរបស់រដ្ឋធម្មនុញ្ញថ្មី ត្រូវបានតាក់តែងឡើងក្នុងនោះដែរ។[18]

#### ១.១.៥.២. តម្លៃជាទស្សនវិជ្ជា

នៅក្នុងន័យនេះ គឺចង់បញ្ជាក់ថា ការផ្ដល់ឱ្យដោយរដ្ឋធម្មនុញ្ញបង្ហាញថា អំណាចមិនមែនគ្មានដែនកំណត់នោះទេ ព្រោះថាអ្នកកាន់អំណាច អ្នកដឹកនាំ អ្នកគ្រប់គ្រង និងប្រជាជនទាំងអស់ ត្រូវទទួលយកច្បាប់កំពូលរបស់រដ្ឋដើម្បីកម្រិតព្រំដែននៃអំណាចរបស់ខ្លួន។[19] នៅក្នុងទស្សនៈខ្លះគេបាននិយាយថារដ្ឋធម្មនុញ្ញ ជាឧបករណ៍សម្រាប់ធានាឱ្យមាននីតិរដ្ឋ។ ប៉ុន្តែមិនមែនបានសេចក្ដីថា គ្រប់រដ្ឋទាំងអស់សុទ្ធតែមាននីតិរដ្ឋនោះទេ ទោះបីជាគ្រប់រដ្ឋទាំងអស់នោះ មានរដ្ឋធម្មនុញ្ញរបស់ខ្លួនក៏ដោយ គឺវាអាស្រ័យដោយប្រសិទ្ធភាពនៃការអនុវត្តច្បាប់របស់ប្រទេសនោះ។

#### ១.១.៥.៣. តម្លៃជាច្បាប់

ក្នុងតម្លៃជាច្បាប់ រដ្ឋធម្មនុញ្ញ ជាប្រព័ន្ធវិធានគតិយុត្តទាំងឡាយសម្រាប់រៀបចំអំណាច និងបង្ខំឱ្យស្ថាប័នកាន់អំណាចគោរពតាម។ រដ្ឋទំនើបមួយមិនអាចអវត្តមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនេះបានទេ។[20]

## ១.២. រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

### ១.២.១. ការបង្កើតរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

អនុលោមទៅតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដើម្បីដោះស្រាយបញ្ហាកម្ពុជាតាមផ្លូវនយោបាយ និងប្រជាធិបតេយ្យ ដែលមានខ្មែរបដិបក្ខទាំងបួនក្រុមចុះហត្ថលេខានៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រៀបចំឡើងដោយអង្គការសហប្រជាជាតិ (UN) នៅទីក្រុងប៉ារីសនៃសាធារណរដ្ឋបារាំងហើយមានការចូលរួមពីបណ្ដាប្រទេសចំនួនម្ភៃរួមមាន៖ អូស្ត្រាលី ប្រ៊ុយណេដារុយសាឡឹម កម្ពុជា កាណាដា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋបារាំង សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋឥណ្ឌូណេស៊ី ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី រាជាណាចក្រថៃឡង់ដ៍ សាធារណរដ្ឋសង្គមនិយមសូវៀត ចក្រភពអង់គ្លេស អៀឡង់ខាងជើង សហរដ្ឋអាមេរិក វៀតណាម និងយូហ្គោស្លាវី។

នៅចំពោះមុខអគ្គលេខាធិការនៃអង្គការសហប្រជាជាតិក្នុងគោលបំណងថែរក្សា និងការពារអធិបតេយ្យភាព ឯករាជ្យភាព បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដីអព្យាក្រឹត្យភាព និងឯកភាពជាតិរបស់ប្រទេសកម្ពុជា ហើយក៏ដូចជាក្នុងគោលបំណងស្ដារឡើងវិញ និងថែរក្សាសន្តិភាពសម្រាប់ប្រជាជាតិកម្ពុជា ការបង្រួបបង្រួមជាតិ និងធានាឱ្យប្រទេសកម្ពុជាប្រើប្រាស់នូវសិទ្ធិស្វ័យសម្រេចតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ។[21]

---

[18] សេង ប៊ុនធឿន, *នីតិរដ្ឋធម្មនុញ្ញ និងការផ្លាស់ប្ដូររបបនយោបាយនៅកម្ពុជា* (២០១៥), ៤, ៥។

[19] ម៉ែន វុធ, *នីតិរដ្ឋធម្មនុញ្ញ និងស្ថាប័ននយោបាយ* (២០២០), ១៤។

[20] សេង ប៊ុនធឿន, *នីតិរដ្ឋធម្មនុញ្ញ និងការផ្លាស់ប្ដូររបបនយោបាយនៅកម្ពុជា* (២០១៥), ៧។

[21] កៅ មុយថង, *រដ្ឋធម្មនុញ្ញកម្ពុជា* (ភ្នំពេញ៖ បណ្ណាគារ អង្គរ, ២០០៦), ៤៥។

ដោយបានកត់សម្គាល់ថា ការបង្កើតឡើងនូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា (SNC) នៅហ្សាការតានៃប្រទេសឥណ្ឌូណេស៊ី នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩០ ជាអង្គការស្ថាប័នស្របច្បាប់ និងជាប្រភពអំណាចស្របច្បាប់នៅកម្ពុជាតែមួយគត់ ដែលនៅក្នុងដំណាក់កាលទូទាំងសម័យអន្តរកាលរបស់អង្គការសហប្រជាជាតិទាមទារឱ្យបង្កើតអាជ្ញាធរបណ្ដោះអាសន្ននៅកម្ពុជា (UNTAC) បណ្ដាលឱ្យ SNC អនុលោមទៅតាមកិច្ចព្រមព្រៀងសន្តិភាពត្រូវប្រគល់អំណាចទាំងអស់ដែលចាំបាច់ទៅឱ្យ UNTAC ដើម្បីធានាការអនុវត្តកិច្ចព្រមព្រៀងសន្តិភាព ឆ្នាំ១៩៩១ ដោយគិតទាំងអំណាច ដែលទាក់ទងនឹងការរៀបចំការបោះឆ្នោត ដោយសេរី ត្រឹមត្រូវ ស្មើភាព និងយុត្តិធម៌។[22]

### ១.២.១.១. ការបង្កើតសភាធម្មនុញ្ញ

UNTAC តំណាងឱ្យអង្គការសហប្រជាជាតិបានធ្វើអន្តរាគមន៍នៅកម្ពុជាចាប់តាំងពីខែមីនា ឆ្នាំ១៩៩២ ដើម្បីរៀបចំឱ្យមានដំណើរការរៀបចំការបោះឆ្នោត ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ ដោយមានការចូលរួមពីបណ្ដាគណបក្សនយោបាយនានាចំនួនម្ភៃ។ ការបោះឆ្នោតនេះសំដៅជ្រើសរើសសភាធម្មនុញ្ញ ដែលមានភារកិច្ចរៀបចំនូវគម្រោងរដ្ឋធម្មនុញ្ញមួយ និងអនុម័តជាផ្លូវការ និងក្រោយមកទៀតក្លាយខ្លួនជាសភាជាតិដោយស្វ័យប្រវត្តិបន្ទាប់ពីប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនេះ។ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញបានបើកសម្ពោធដាក់ឱ្យដំណើរការលើការងាររបស់ខ្លួនក្រោមអធិបតីភាពសម្ដេចព្រះនរោត្តម សីហនុ ក្នុងឋានៈជាព្រះប្រធាននៃឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ និង លោក យ៉ាយូស៊ី អាកាស៊ី ប្រមុខ UNTAC។[23]

### ១.២.១.២. ការរៀបចំតាក់តែងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញបានបើកសម័យប្រជុំពេញអង្គលើកទីមួយ ដើម្បីបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានទី១ និងទី២នៃសភាធម្មនុញ្ញ។ ជាមួយគ្នានេះ សភាធម្មនុញ្ញបានបង្កើតនូវគណៈកម្មាការអចិន្ត្រៃយ៍មួយដើម្បីធ្វើសេចក្ដីព្រាងរដ្ឋធម្មនុញ្ញដោយអនុលោមទៅតាមមាត្រា២៣ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។ គណៈកម្មការនេះមានសមាសភាពប្រធាន០១ រូប ដឹកនាំដោយប្រធានសភាធម្មនុញ្ញ ឬអនុប្រធានសភាធម្មនុញ្ញ បើប្រធានអវត្តមាន អនុប្រធាន០១ រូប សមាជិក១០ រូប សមាជិកបម្រុង០៨ រូប អ្នកជំនាញការ០៥ រូប។[24]

ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញបានអនុម័តលើគំរោងរដ្ឋធម្មនុញ្ញមួយដែលចែកចេញជា១៤ ជំពូក មាន១៣៩ មាត្រា ដោយមានសម្លេងគាំទ្រ១១៣ សម្លេង អនុប្បវាទ ០២ សម្លេង និងប្រឆាំង ០៥ សម្លេង។ ប៉ុន្តែ

[22] កៅ មុយថង, *រដ្ឋធម្មនុញ្ញកម្ពុជា* (ភ្នំពេញ៖ បណ្ណាគារ អង្គរ, ២០០៦), ៤៦។
[23] កៅ មុយថង, *រដ្ឋធម្មនុញ្ញកម្ពុជា* (ភ្នំពេញ៖ បណ្ណាគារ អង្គរ, ២០០៦), ៤៦។
[24] កៅ មុយថង, *រដ្ឋធម្មនុញ្ញកម្ពុជា* (ភ្នំពេញ៖ បណ្ណាគារ អង្គរ, ២០០៦), ៤៧។

ក្រោយពីប្រកាសឱ្យប្រើជាផ្លូវការ កម្ពុជាបានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់ខ្លួនជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន រដ្ឋធម្មនុញ្ញកម្ពុជាបានចែកចេញជា១៧ ជំពូក និង១៦០ មាត្រា។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញបានត្រូវឡាយព្រះហត្ថលេខា និងប្រកាសឱ្យប្រើជាផ្លូវការដោយសម្តេចព្រះបាទ នរោត្តម សីហនុ ក្នុងឋានៈជាព្រះប្រមុខរដ្ឋកម្ពុជា និងជាព្រះប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC)។ ចំណែកឯសភាធម្មនុញ្ញក្រោយពេលរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣បានប្រកាសឱ្យប្រើតាមរយៈព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញត្រូវបានក្លាយទៅជារដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

### ១.២.២. រចនាសម្ព័ន្ធ

រចនាសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ ឬជារចនាសម្ព័ន្ធនៃច្បាប់កំពូល ត្រូវបានតាក់តែងឡើងតាមគំរូមួយប្រភេទយ៉ាងច្បាស់លាស់ហៅថា បទដ្ឋាននិយ័តកម្ម ដែលគេច្រើនតែងតែសង្កេតឃើញថាជាទូទៅកើតមានចំពោះតែច្បាប់កំពូលតែប៉ុណ្ណោះ។ នៅក្នុងបទដ្ឋាននីយកម្មនេះ បានបែងចែកជាច្រើនប្រភេទទៀតដូចជា បុព្វកថា ខ្លឹមសារគ្រឹះ និងអន្តរប្បញ្ញត្តិ ហើយពេលខ្លះ ក៏មានឧបសម្ព័ន្ធទៀតផង។

#### ១.២.២.១. បុព្វកថា

ជាទូទៅ ត្រង់នេះគេតែងតែរំលឹកទៅដល់ទិសនៃរដ្ឋធម្មនុញ្ញ ឬច្បាប់កំពូលនោះតាមរយៈរូបភាពប្រវត្តិសាស្ត្រនៃការបង្កើតរដ្ឋធម្មនុញ្ញ ជួនកាលទៀតគេក៏រំលេចនូវសិទ្ធិ និងសេរីភាព ឬជាការផ្តើមដឹកនាំនយោបាយដូចជារដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ បានកំណត់ថា យើងជាប្រជារាស្ត្រខ្មែរ ដែលធ្លាប់មានអារ្យធម៌ឧត្តុងឧត្តម ប្រទេសជាតិស្តុកស្តម្ភ ធំទូលាយ ថ្កុំថ្កើង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ។ បានធ្លាក់ខ្លួនដ៏សែនរន្ធត់ក្នុងកំឡុងពីរទសវត្សរ៍ចុងក្រោយមកនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយ ទ្រុឌទ្រោមឱនថយមហាសោកស្តាយ។ ក្រោយមក ក៏បានភ្ញាក់ខ្លួនក្រោកឈរឡើង រួបរួមគ្នា និងឯកភាពជាតិឡើងវិញកសាងប្រទេសជាតិឆ្ពោះទៅរកកោះសន្តិភាពដោយផ្អែកលើប្រព័ន្ធសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ចំពោះវាសនាប្រទេសជាតិ។[25]

#### ១.២.២.២. ខ្លឹមសារគ្រឹះ

នៅត្រង់នេះបានន័យថា ជាចំណុចរួមក្នុងរដ្ឋធម្មនុញ្ញ ដែលបានផ្គុំឡើងដោយបទដ្ឋានជាច្រើន ទាំងនេះជាផ្នែកមួយនៃរដ្ឋធម្មនុញ្ញ ដែលនឹងលាតត្រដាងនូវបទដ្ឋានជាច្រើនអំពីសិទ្ធិ និងសេរីភាព មាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។

[25] ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ធាងពុម្ព ដារ៉ា, ២០១៦), ៤០។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ជំនឿ និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ មាត្រា ៤១ បានចែងថា ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ។[26] ក្នុងខ្លឹមសារដែលជាមូលដ្ឋានគ្រឹះនេះ គេអាចសង្កេតឃើញថា មានធាតុជាច្រើនទៀតសម្រាប់ធ្វើឱ្យទៀងទាត់នូវទំនាក់ទំនងសាធារណៈដូចជា៖

**ក. បទដ្ឋានស្តីពីប្រព័ន្ធគ្រប់គ្រងរដ្ឋ**

បទដ្ឋានស្តីពីប្រព័ន្ធគ្រប់គ្រងរដ្ឋ គឺជាបទដ្ឋានធម្មនុញ្ញ ដែលបានធ្វើនិយ័តកម្មទៅលើដែនដីគ្រប់គ្រងរដ្ឋ។ យោងតាមមាត្រា១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលមានព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ។ ដោយឡែកមាត្រា៣ ចែងថា ព្រះរាជាណាចក្រ-កម្ពុជាជារដ្ឋដែលមិនអាចបំបែកបាន។ រីឯមាត្រា៥១ ថ្មី បានចែងថា ព្រះរាជាណាចក្រកម្ពុជាអនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ហើយអំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។ អំណាចបែងចែកដាច់ពីគ្នារវាង អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

គោលបំណងនៃការបែងចែកអំណាច គឺដើម្បីធានានូវតុល្យភាពទៅវិញទៅមក ដោយជៀសវាងនូវការបំពានដោយគ្មានព្រំដែន។ មាត្រា៩៣ ថ្មី ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល១០ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល២០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែ បើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ។ ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ។ ចំណែកឯមាត្រា១៣០ ថ្មី (មាត្រា១១១ ចាស់) បានចែងថា គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការបានឡើយ។ មាត្រា១៤៥ ថ្មី (មួយ) ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង

[26] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៤១។

ស្រុក ខណ្ឌ ឃុំ សង្កាត់។ មាត្រា១៤៦ ថ្មី (មួយ) រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ។[27]

**ខ. បទដ្ឋានស្តីពីប្រព័ន្ធគ្រប់គ្រង និងឋានៈនៃអង្គការរដ្ឋ**

បទដ្ឋានស្តីពីប្រព័ន្ធគ្រប់គ្រង និងឋានៈនៃអង្គការរដ្ឋ គឺជាបទដ្ឋានធម្មនុញ្ញ ដែលបានកំណត់អង្គការរដ្ឋនានា និងទំនាក់ទំនងរបស់អង្គការទាំងនោះ។ ជាក់ស្តែង មាត្រា១៣៦ ថ្មី បានចែងថា ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និងសម្រេចលើករណីវិវាទកម្មទាក់ទងទៅលើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ចំណែកមាត្រា១១៨ ថ្មី (មួយ) បានចែងថា គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី។ មាត្រា១១៩ ថ្មី (ពីរ) បានចែងថា តាមសេចក្តីស្នើពីគណបក្ស ដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រីឱ្យបង្កើតរាជរដ្ឋាភិបាល។ សេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភានេះ ត្រូវចម្លងជូនប្រធានរដ្ឋសភា។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះត្រូវតែជាតំណាងរាស្ត្រ ដែលមានសញ្ជាតិខ្មែរតែមួយគត់ និងត្រូវជ្រើសរើសចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំងនេះនាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្តូផ្តង ឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ដើម្បីសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តនេះ ត្រូវធ្វើលើបញ្ជីសមាសភាពនៃគណៈរដ្ឋមន្ត្រីទាំងមូល។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តរួចហើយ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។ មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៦។

**គ. បទដ្ឋានស្តីពីនិមិត្តរូបរដ្ឋ**

បទដ្ឋានស្តីពីនិមិត្តរូបរដ្ឋ គឺជាបទដ្ឋានធម្មនុញ្ញដែលបានកំណត់នូវសញ្ញាណរូបភាពនានា ដែលជានិមិត្តរូបរបស់រដ្ឋនីមួយៗ។ ជាក់ស្តែង មាត្រា៤ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ ជាតិ សាសនា ព្រះមហាក្សត្រ។ បន្ថែមពីនេះ មាត្រា៥ បានចែងថា ភាសា និងអក្សរ ដែលប្រើជាផ្លូវការគឺ ភាសា និងអក្សរខ្មែរ។ ដោយឡែក មាត្រា៦ បានចែងថា ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ទង់ជាតិ ភ្លេងជាតិ និងសញ្ញាជាតិមានកំណត់នៅក្នុងឧបសម្ព័ន្ធ១,២ និង៣។

[27] ឈុន ណារ៉េត, *សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ផាងពុម្ព ដារ៉ា,២០១៦), ៤១,៤២។

**ឃ. បទដ្ឋានស្តីអំពីការគ្រប់គ្រងអំណាចមូលដ្ឋាន**

បទដ្ឋានស្តីពីអំពីការគ្រប់គ្រងអំណាចមូលដ្ឋាន គឺជាបទដ្ឋានធម្មនុញ្ញ ដែលធ្វើនិយ័តកម្មទៅលើទំនាក់ទំនងអំណាចមូលដ្ឋាន។ ជាក់ស្តែង មាត្រា១៤៥ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ បន្ថែងពីនេះ មាត្រា១៤៦ ថ្មី (មួយ) រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ។

**ង. បទដ្ឋានស្តីសណ្តាប់ធ្នាប់នៃការផ្លាស់ប្តូររដ្ឋធម្មនុញ្ញ**

បទដ្ឋានស្តីពីសណ្តាប់ធ្នាប់នៃការផ្លាស់ប្តូររដ្ឋធម្មនុញ្ញ គឺជាបទដ្ឋានទាំងឡាយនៃរដ្ឋធម្មនុញ្ញ ដែលបានធ្វើនិយ័តកម្មទៅលើបញ្ហាផ្លាស់ប្តូរនៃរដ្ឋធម្មនុញ្ញដូចជា មាត្រា១៥៣ ថ្មី (ពីរ មាត្រា១៥១ ថ្មី) បានចែងថា ការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី និងប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ហើយការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ បន្ថែមពីនេះ មាត្រា១៤៣ ថ្មី(មាត្រា១២៤ ចាស់) បានចែងថា ព្រះមហាក្សត្រទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយ ដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ។[28]

**១.២.២.៣. អន្តរប្បញ្ញត្តិ**

អន្តរប្បញ្ញត្តិ គឺជាការកំណត់ទៅលើថេរវេលាមួយនៃការចូលជាធរមានរាល់បទដ្ឋានធម្មនុញ្ញដោយឡែកដែលបទដ្ឋាននោះពុំអាចត្រូវបានធ្វើសមិទ្ធិភ្លាមៗ កំណត់នូវសណ្តាប់ធ្នាប់ និងថេរវេលានៃការផ្លាស់ប្តូរនូវគ្រឹះរដ្ឋធម្មនុញ្ញចាស់ដោយរដ្ឋធម្មនុញ្ញថ្មី ដូចជាមាត្រា១៥៦ ថ្មី (ពីរ មាត្រា១៥៤ ថ្មី) បានកំណត់ថា រដ្ឋធម្មនុញ្ញនេះក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឱ្យចូលជាធរមានដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនេះ មាត្រា១៦០ ថ្មី (ពីរ មាត្រា១៥៨ ថ្មី) បានចែងថា ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិត្រូវមានអនុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានបទដ្ឋានថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទបញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីរដ្ឋធម្មនុញ្ញនេះ។

**១.២.២.៤. ឧបសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ**

ចំពោះឧបសម្ព័ន្ធ រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានកំណត់ដូចជា ឧបសម្ព័ន្ធទី១,២,៣ លំអិតទៅលើមាត្រា៦ បានចែងថា ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ ទង់ជាតិ ភ្លេងជាតិ មានកំណត់នៅក្នុងឧបសម្ព័ន្ធ១,២,៣។

[28] ឈុន ណារ៉េត, *សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ធាងពុម្ព ដារ៉ា,២០១៦), ៤៣,៤៥។

ឧបសម្ព័ន៤ កំណត់នូវអត្ថន័យមាត្រា១៤ ឧបសម្ព័ន៥ កំណត់នូវអត្ថន័យ មាត្រា៨២ ថ្មី (មួយ) និងឧបសម្ព័ន៦ កំណត់នូវអត្ថន័យមាត្រា១១៩ ថ្មី (ពីរ)។[29]

### ១.២.៣. គោលការណ៍គ្រឹះនៃរដ្ឋធម្មនុញ្ញ

គោលការណ៍គ្រឹះ គឺជាគោលការណ៍ស្នូលនៃរដ្ឋធម្មនុញ្ញ ដែលគេអាចធ្វើការកត់សម្គាល់បានតាមរយៈរូបភាពចំនួនបី (០៣) ដូចជា៖ ទ្រឹស្តីឯករាជ្យ និងអធិបតេយ្យ (១.២.៣.១) ទ្រឹស្តីរាជានិយម (១.២.៣.២) និង ទ្រឹស្តីប្រជាធិបតេយ្យសេរីពហុបក្ស (១.២.៣.៣)។

#### ១.២.៣.១. ទ្រឹស្តីឯករាជ្យ និងអធិបតេយ្យ

ចំពោះទ្រឹស្តីឯករាជ្យ និងអធិបតេយ្យ រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានកំណត់ដូចខាងក្រោម៖

- មាត្រា១ បានចែងថា ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ
- មាត្រា២ បានចែងថា បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាមិនអាចរំលោភបានដាច់ខាត
- មាត្រា៣ បានចែងថា ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន
- មាត្រា៤ បានចែងថា បាវចនានៃព្រះរាជាណាចក្រកម្ពុជាគឺ ជាតិ សាសនា ព្រះមហាក្សត្រ
- មាត្រា៥ បានចែងថា ភាសា និងអក្សរផ្លូវការគឺ ភាសា និងអក្សរខ្មែរ។

#### ១.២.៣.២. ទ្រឹស្តីរាជានិយម

ចំពោះទ្រឹស្តីរាជានិយម រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានកំណត់ដូចខាងក្រោម៖

- មាត្រា៧ បានចែងថា ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែមិនកាន់អំណាចឡើយ ព្រះមហាក្សត្រទ្រង់ជាប្រមុខរដ្ឋអស់មួយជីវិត។ អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបានឡើយ
- មាត្រា១០ បានចែងថា របបរាជានិយមកម្ពុជា ជារបបជ្រើសតាំងព្រះមហាក្សត្រទ្រង់ឥតមានអំណាចចាត់តាំងព្រះរាជទាយាទសម្រាប់គ្រប់គ្រងរាជសម្បត្តិឡើយ។

#### ១.២.៣.៣. ទ្រឹស្តីប្រជាធិបតេយ្យសេរីពហុបក្ស

រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ក៏បានកំណត់នូវទ្រឹស្តីប្រជាធិបតេយ្យសេរីពហុបក្សដូចជា៖

- រដ្ឋាភិបាលប្រជាធិបតេយ្យ មាត្រា១១៩ ថ្មី (ពីរ)
- ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស មាត្រា៣១
- បែងចែកអំណាច មាត្រា៥១ ថ្មី
- ឯករាជ្យភាពនៃតុលាការ មាត្រា ១២៨ (ថ្មី)។

[29] ឈុន ណារ៉េត, *សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ផាងពុម្ព ដារ៉ា,២០១៦), ៤៦។

# ជំពូកទី២

# ការបែងចែកអំណាច

# ជំពូកទី២
# ការបែងចែកអំណាច

## ២.១. ទ្រឹស្តីរបស់អ្នកប្រាជ្ញ

ទស្សនៈរបស់អ្នកប្រាជ្ញ ដែលមានភាពប្រទាក់គ្នាយ៉ាងខ្លាំងទៅនឹងយន្តការនៃការបែងចែកអំណាចមានពីររួមមានៈ លោក ចន ឡុក (John Locke) និង លោក ម៉ង់ តេស្គីយើ (Montesquieu)។

### ២.១.១. លោក ចន ឡុក (John Locke)

ចំពោះគោលការណ៍នៃការបែងចែកអំណាចរបស់ លោក ឡុក (Locke) បានចែកជាបី (០៣) គឺ៖

- អំណាចនីតិបញ្ញត្តិស្ថិតក្នុងដៃសភា
- អំណាចនីតិប្រតិបត្តិក្នុងដៃរដ្ឋាភិបាល តុលាការ និងយោធា
- អំណាចសហព័ន្ធស្ថិតក្នុងដៃស្តេច និងមន្ត្រីនានា និងជាអំណាចសម្រាប់ចុះសន្ធិសញ្ញានានា ការប្រកាសសង្គ្រាម ឬសន្តិភាព។[30]

ស្តេចជាប្រមុខរដ្ឋនៃអំណាចនីតិប្រតិបត្តិ និងអំណាចសហព័ន្ធ។ អភ័យឯកសិទ្ធិរបស់រដ្ឋាភិបាលត្រូវបានកំណត់ក្នុងច្បាប់។ អំណាចនីតិបញ្ញត្តិ ជាអំណាចកំពូលក្នុងចំណោមអំណាចទាំង៣។ អំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ មិនត្រូវបានស្ថិតក្នុងដៃបុគ្គលណាមួយឡើយព្រោះបើបុគ្គលនោះយកអំណាចនោះទៅប្រើសម្រាប់ផលប្រយោជន៍បុគ្គល ពុំបានបម្រើផលប្រយោជន៍រួមធ្វើឱ្យមានរបបផ្តាច់ការ។ ដូច្នេះការបែងចែកអំណាចជាវិធីសាស្ត្រមួយជៀសវាងមិនឱ្យកើតមានឡើងនូវអំណាចតាមទំនើងចិត្តបែបអាជ្ញាព្រឹត្តិដែលជាកត្តាមិនធានាដល់សិទ្ធិសេរីភាព និងកម្មសិទ្ធិរបស់ប្រជាពលរដ្ឋឡើយ។ បន្ថែមលើការបែងចែកអំណាចនេះលោក Locke បានដាក់ចុះនូវវិធានការណ៍ផ្សេងទៀតដើម្បីឱ្យរដ្ឋស្គាល់ពីមុខងារ របស់ខ្លួននៅក្នុងសង្គម។ ជារួមមានវិធានការណ៍ពីរនោះគឺ៖

- បែងចែកសាសនាឱ្យដាច់ពីគ្នា ឬនិយាយម្យ៉ាងទៀតថា បែងចែកអំណាចសាសនាឱ្យដាច់ពីអំណាចរដ្ឋ
- ត្រូវរក្សាសិទ្ធិតស៊ូចំពោះការគាបសង្កត់ ចំណែកឯការបះបោរ បាតុកម្ម កូដកម្ម ត្រូវតែមានប្រសិនបើរដ្ឋមិនបានបំពេញករណីកិច្ចរបស់ខ្លួនទេនោះ។

លោក Locke ប្រឆាំងចំពោះរបបរាជានិយមផ្តាច់ការ ដែលយកពន្ធដារតាមទំនើងចិត្ត រឹបអូសយកកម្មសិទ្ធិរំលោភលើសេរីភាព។ល។ លើសពីនេះអំណាចផ្តាច់ការ ឬរាជានិយមផ្តាច់ការរឹតតែធ្វើឱ្យលោកកាន់តែព្រួយបារម្ភទៀត។ ដូច្នេះគំនិតរបស់លោកផ្តោតខ្លាំងទៅលើអំណាច និងកម្មសិទ្ធិឯកជន វាត្របាញ់ចូលគ្នាក្នុង

---

[30] អ៊ុន សកក្កដា, *ប្រវត្តិគំនិតនយោបាយ* (ភ្នំពេញ៖ ២០២០), ១៧៥, ១៧៦។

ទស្សនវិស័យវឌ្ឍនភាព ចំណុចទាំងពីរខាងលើនេះ ពោលគឺជាកត្តាសំខាន់ដែលត្រូវបានលើកឡើងជាបញ្ហាបច្ចុប្បន្ន។[31]

**២.១.២. លោក ម៉ង់ តេរីយើ** (Montesquieu)

តាមទស្សនៈរបស់លោក ម៉ង់ តេរីយើ (Montesquieu) ដើម្បីឱ្យមានស្ថេរភាពនៅក្នុងរបបសាធារណរដ្ឋ ក៏ដូចជានៅក្នុងរបបរាជានិយមចាំបាច់ត្រូវមានការបែងចែកអំណាចរដ្ឋព្រោះថាការបែងចែកអំណាចរដ្ឋ អាចធ្វើឱ្យសមាជិកនៃសង្គមទទួលបានសេរីភាព យុត្តិធម៌ ពិសេសគឺ ស្ថិរភាពសង្គមតែម្តង។ លោកបានចែកអំណាចចេញជាបី (០៣) ដូចខាងក្រោម៖

១. **អំណាចនីតិបញ្ញត្តិ** ជាអំណាចធ្វើច្បាប់ កែច្បាប់ និងលុបចោលច្បាប់។ អំណាចនីតិបញ្ញត្តិត្រូវប្រគល់ទៅឱ្យសភាពីរជាន់ជាអ្នកកាន់កាប់គឺ សភាអភិជន(សភាជាន់ខ្ពស់) និងសភារបស់ប្រជាជន(សភាជាន់ទាប)។ ក្រៅពីបង្កើត ឬលុបចោលច្បាប់អំណាចនេះនៅមានតួនាទីជាអ្នកតាមដានត្រួតពិនិត្យការប្រតិបត្តិរបស់ព្រះរាជា និងមាននាទីជាអ្នកកាត់ក្តីវិនិច្ឆ័យទៅលើសកម្មភាពប្រតិបត្តិទៅលើសង្គមទាំងមូល។

២. **អំណាចនីតិប្រតិបត្តិ** ជាអំណាចប្រតិបត្តិតាមឆន្ទៈរបស់អំណាចនីតិបញ្ញត្តិសម្រាប់រៀបចំដឹកនាំសង្គមទាំងផ្ទៃក្នុងប្រទេសទាំងលើឆាកអន្តរជាតិ និងជាអំណាចដែលមានសិទ្ធិប្រកាសសង្គ្រាម និងសន្តិភាព។ អំណាចនេះមានបង្កប់នូវចរិតជាអំណាចនៃច្បាប់អន្តរជាតិផងដែរ។ អំណាចនេះត្រូវបានប្រគល់ឱ្យទៅព្រះមហាក្សត្រជាអ្នកកាន់កាប់។ អំណាចនេះក្រៅពីការប្រតិបត្តិ គឺនៅមានសិទ្ធិជំទាស់ចំពោះអំណាចនីតិបញ្ញត្តិផងដែរតាមនីតិវិធីនៃការប្រើសិទ្ធិរបស់ស្តេច។

៣. **អំណាចតុលាការ** ជាអំណាចវិនិច្ឆ័យដែលត្រូវបានគេប្រើប្រាស់នៅក្នុងក្របខណ្ឌនៃអំណាចច្បាប់រដ្ឋប្បវេណី។ អំណាចនេះត្រូវប្រគល់ឱ្យសភាតាមខេត្ត ក្រុងនីមួយៗ ដែលកាន់កាប់អំណាចតុលាការ។ គោលការណ៍នៃការបែងចែកអំណាចនេះធ្វើឡើងក្នុងគោលបំណងទប់ស្កាត់មិនឱ្យអំណាច ដែលស្ថិតនៅក្នុងដៃបុគ្គលណាម្នាក់នោះអាចនាំទៅរកក្តីវិនាសដល់ប្រទេសជាតិបាន ដើម្បីឱ្យទ្រឹស្តីនៃការបែងចែកអំណាចនេះអាចទៅតាមរូបភាពជាប្រព័ន្ធ និងទប់ទម្ងន់ដើម្បីរក្សាតុល្យភាពនៃអំណាចទាំងបីរបស់រដ្ឋ។ គោលដៅនៃគោលការណ៍ការបែងចែកអំណាចធ្វើឡើងដើម្បីប្រឆាំងនឹងរបបរាជានិយមផ្តាច់ការ ហើយសម្របសម្រួលទំនាស់រវាងរបបមូលធននិយម និងជាការគ្រោងទុកជាមុនដើម្បីការពារគ្រោះថ្នាក់ជៀសវាងការដណ្តើមយកអំណាចផ្តាច់មុខ។ ព្រោះលោកយល់ថាសារជាតិរបស់មនុស្សបើកាលណាបានអំណាចនៅក្នុងដៃរបស់ខ្លួន ហើយមនុស្សនោះនឹងតស៊ូដណ្តើមអំណាចនោះលុះដល់ដំណាក់ឈាមចុងក្រោយ។

[31] អ៊ុន សកក្កដា, *ប្រវត្តិគំនិតនយោបាយ* (ភ្នំពេញ៖ ២០២០), ១៧៥, ១៧៦។

ដូច្នេះធ្វើយ៉ាងណាឱ្យអំណាចទប់អំណាច ពីព្រោះអ្នកមានអំណាចទាំងអស់តែងមានការប្រើប្រាស់ជ្រុលហួសនូវអំណាចទាំងនោះ។[32]

## ២.២. ក្របខណ្ឌរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

ផ្អែកលើក្របខណ្ឌរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ អំណាចត្រូវបានបែងចែកជាបី (០៣) ដាច់ពីគ្នារួមមាន៖ អំណាចនីតិបញ្ញត្តិ(២.២.១) អំណាចនីតិប្រតិបត្តិ(២.២.២) និងអំណាចតុលាការ(២.២.៣)។[33]

### ២.២.១. ការអនុវត្តអំណាចនីតិបញ្ញត្តិ

ជារួមអំណាចនីតិបញ្ញត្តិក្នុងក្របខណ្ឌកម្ពុជា គឺជាប្រព័ន្ធទ្វិកសភា បានន័យថាមានសភាពីរថ្នាក់ ស្ថាប័នរដ្ឋសភា និងស្ថាប័នព្រឹទ្ធសភា។ ស្ថាប័នទាំងពីរនេះជាទូទៅមានការទំនាក់ទំនងគ្នាទៅវិញទៅមក ហើយមានអំណាចរៀងៗខ្លួនដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣។

#### ២.២.១.១. ស្ថាប័នរដ្ឋសភា

ក្រោយពេលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសឱ្យប្រើជាធរមាន តាមរយៈព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញត្រូវបានក្លាយទៅជារដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។ ស្ថាប័នរដ្ឋសភានេះ គឺជាអង្គការនីតិបញ្ញត្តិដែលមានភាពសំខាន់ក្នុងការធានាឱ្យបាននូវដំណើរការ និងនិរន្តរភាពនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ការធានានោះ គឺតាមរយៈការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ។ ជាទូទៅស្ថាប័ននេះបានផ្តល់មកវិញនូវភាពជាតំណាងឱ្យប្រជាជាតិខ្មែរទាំងមូលពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។[34]

បើរាប់ចាប់ពីឆ្នាំ១៩៩៣ ក្រោយពីការបោះឆ្នោតជាសកលមកទល់នឹងបច្ចុប្បន្ន រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានដំណើរការសកម្មភាពរបស់ខ្លួនបានចំនួនប្រាំពីរ (០៧) នីតិកាលដូចខាងក្រោម៖

- នីតិកាលទី១ បើកសម័យប្រជុំលើដំបូង នៅថ្ងៃទី២៤ កញ្ញា ១៩៩៣
- នីតិកាលទី២ បើកសម័យប្រជុំលើដំបូងនៅថ្ងៃទី១២-១៣ ខែវិច្ឆកា ឆ្នាំ១៩៩៨
- នីតិកាលទី៣ បើកសម័យប្រជុំលើដំបូងនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤
- នីតិកាលទី៤ បើកសម័យប្រជុំលើដំបូងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨
- នីតិកាលទី៥ បើកសម័យប្រជុំលើដំបូងនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣
- នីតិកាលទី៦ បើកសម័យប្រជុំលើដំបូងនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨

[32] អ៊ុន សកក្កដា, *ប្រវត្តិគំនិតនយោបាយ* (ភ្នំពេញ៖ ២០២០), ២០៨, ២០៩។

[33] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ១៩៩៩, មាត្រា៥១ ថ្មី វាក្យខណ្ឌទី៤។

[34] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៧៧។

- នីតិកាលទី៧ បើកសម័យប្រជុំលើដំបូងនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣។[35]

**គ. លក្ខណសម្បត្តិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនជ្រើសតាំងតំណាងរាស្ត្រ ត្រូវតែបំពេញលក្ខខណ្ឌ ដែលមានជារួមដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុ២៥ឆ្នាំឡើងទៅ គិតមកដល់ថ្ងៃបោះឆ្នោត
- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីឈរឈ្មោះបោះឆ្នោត
- មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា
- មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត។[36]

ចំពោះលក្ខខណ្ឌសម្រាប់មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបុព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរយ៉ាងតិច០៧ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត។[37]

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានរៀបចំឡើងរៀងរាល់៥ឆ្នាំម្តងជាសកលដោយសេរី ហើយតំណាងរាស្ត្រមានសមាជិកយ៉ាងតិច១២០រូប ក្នុងករណីមានការប្រែប្រួលនៃចំនួនប្រជាពលរដ្ឋ ក៏ដូចជាភូមិសាស្ត្រ ដូច្នេះចំនួនអាសនៈនៅក្នុងរដ្ឋសភាក៏មានការប្រែប្រួលផងដែរ ជាក់ស្តែងចំនួនអាសនៈនៅក្នុងរដ្ឋសភាគិតត្រឹមនីតិកាលទី៧នេះមានការប្រែប្រួលដូចខាងក្រោម៖

- នីតិកាលទី១ មានចំនួន១២០អាសនៈ
- នីតិកាលទី២ មានចំនួន១២២អាសនៈ
- នីតិកាលទី៣ មានចំនួន១២៣អាសនៈ
- នីតិកាលទី៤ មានចំនួន១២៣អាសនៈ
- នីតិកាលទី៥ មានចំនួន១២៣អាសនៈ
- នីតិកាលទី៦ មានចំនួន១២៥អាសនៈ

[35] គន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨), ១១២។

[36] ច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រ,លេខ នស/រកម/០៣១៥/០០៣, ២៤ មីនា ឆ្នាំ២០១៥, មាត្រា២៣។

[37] ច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រ,លេខ នស/រកម/០៣១៥/០០៣, ២៤ មីនា ឆ្នាំ២០១៥, មាត្រា២៥។

– នីតិកាលទី៧ មានចំនួន១២៥អាសនៈ។[38]

តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសជាសម្ងាត់។[39] ចំពោះអត្ថន័យទាំងប្រាំ(០៥) ខាងលើនេះ មានដូចតទៅៈ

- **ការបោះឆ្នោតជាសកលៈ** បាននន័យថា ការបោះឆ្នោតត្រូវធ្វើឡើងជាទូទៅ នៅទូទាំងប្រទេសនៅម៉ោងថ្ងៃខែដែលបានកំណត់ជាក់លាក់មួយ និងមានភាពទៀងទាត់ ដោយមិនប្រកាន់ពូជសាសន៍ សាសនា ការអប់រំ ជីវភាពសង្គម ឬរបបចំណូលអ្វីឡើយ។
- **ដោយសេរីៈ** បានន័យថា ប្រជាពលរដ្ឋមានសេរីភាពយ៉ាងពេញទីក្នុងការគាំទ្រ ឬបោះឆ្នោតឱ្យ ឬមិនបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ដោយគ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង។
- **ដោយស្មើភាពៈ** បានន័យថា ប្រជាពលរដ្ឋម្នាក់បានបោះឆ្នោតតែមួយសម្លេងដូចៗគ្នា ហើយមានតម្លៃស្មើៗគ្នា គឺមួយសម្លេងដោយមិនបែងចែកឋានៈសង្គមអ្វីឡើយ។
- **ដោយចំពោះៈ** បានន័យថា ប្រជាពលរដ្ឋត្រូវទៅបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដោយផ្ទាល់ មិនអាចឱ្យអ្នកណាសម្រេចចិត្តជំនួស ឬគូសសន្លឹកឆ្នោត ឬបោះឆ្នោតជំនួសខ្លួនបានឡើយ។
- **តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ៈ** នៅពេលដែលបោះឆ្នោត គឺត្រូវគូសសន្លឹកឆ្នោតជាសម្ងាត់ ដើម្បីជ្រើសរើសគណបក្សណាមួយដែលខ្លួនពេញចិត្តដោយមិនឱ្យអ្នកណាម្នាក់ឃើញ ឬដឹងឡើយ។[40]

**ខ. តួនាទី និងភារកិច្ចរបស់រដ្ឋសភា**

ក្នុងតួនាទី និងភារកិច្ចរបស់ខ្លួន រដ្ឋសភាមានមុខងារសំខាន់ៗបី(០៣) រួមមានៈ មុខងារតំណាង(ខ.១) មុខងារបង្កើត និងទម្លាក់រាជរដ្ឋាភិបាល(ខ.២) និងមុខងារនីតិកម្ម(ខ.៣)។

**ខ.១. មុខងារតំណាង**

ពិតមែនតែតំណាងរាស្ត្របានឈរឈ្មោះនៅក្នុងមណ្ឌលរបស់ខ្លួនឱ្យប្រជាពលរដ្ឋខ្លួននៅក្នុងមណ្ឌលបោះឆ្នោតជូនក៏ពិតមែន ប៉ុន្តែតំណាងរាស្ត្រមិនមែនគ្រាន់តែជាតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងមណ្ឌលខ្លួននោះទេ តែជាតំណាងឱ្យប្រជាពលរដ្ឋទូទាំងប្រទេស។ អ្នកតំណាងរាស្ត្រជាតំណាងឆន្ទៈរបស់ប្រជាពលរដ្ឋ ដូច្នេះត្រូវធ្វើអ្វីតាមឆន្ទៈប្រជាពលរដ្ឋចង់បាន ឬត្រូវទទួលនូវសំណើ និងពាក្យបណ្តឹងតវ៉ាផ្សេងៗដែលប្រជាពលរដ្ឋផ្ញើមក ឬបានមកពីប្តឹងតវ៉ា។[41]

---

[38] សុខ ចិន្តា និងសុខ យ៉ាន, *នីតិរដ្ឋធម្មនុញ្ញ* (២០២១), ១២៣។

[39] ច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រ,លេខ នស/រកម/០៣១៥/០០៣, ២៤ មីនា ឆ្នាំ២០១៥, មាត្រា៥។

[40] គន យឿន, រៀបរៀង, *មូលដ្ឋានច្បាប់ និង ស្ថាប័នច្បាប់* (២០១៨), ១២១,១២២។

[41] ឈុន ណារ៉េត,*សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញៈធាងពុម្ព ដារ៉ា,២០១៦), ១៤៣។

**ខ.១.១. ការអនុវត្តអំណាចក្នុងនាមជាតំណាង**

តំណាងរាស្ត្រគ្រប់រូប ដែលកើតចេញពីការបោះឆ្នោតតាមមណ្ឌលនីមួយៗសុទ្ធតែបានទទួលនូវសេចក្ដីទុកចិត្ត ពីប្រជាពលរដ្ឋខ្មែរជាទូទៅ បានន័យថារាល់សម្លេងឆ្នោតនីមួយៗ គឺសុទ្ធតែជាការប្រគល់ឱ្យនូវសិទ្ធិ និង ករណីយកិច្ចយ៉ាងពេញទីទៅដល់អ្នកតំណាងរាស្ត្រ។

**ខ.១.២. អភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រ**

អ្នកតំណាងរាស្ត្រគ្រប់ៗរូបសុទ្ធតែទទួលបាននូវការធានាដោយរដ្ឋធម្មនុញ្ញ ចាប់តាំងពីការបើកសម័យប្រជុំ ពេញអង្គចូលកាន់តំណែង ត្រង់នេះបានន័យថា ទោះបីជាអ្នកតំណាងរាស្ត្ររូបនោះបានបញ្ចប់អាណត្តិក៏ដោយ រដ្ឋធម្មនុញ្ញនៅតែបន្តការពាររហូត(ការពារនូវរាល់ទង្វើរបស់គាត់ធ្វើឡើងក្នុងអំឡុងពេលបំពេញអាណត្តិ អ្នកតំណាងរាស្ត្រ មិនអនុញ្ញាតឱ្យលើកយកមក ដើម្បីធ្វើការចោទប្រកាន់ពេលក្រោយផុតពីអាណត្តិនោះទេ)[42] នេះគឺជាកត្តាសំខាន់មួយ ដែលរួមចំណែកធ្វើឱ្យលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាកាន់តែរឹងមាំ។ តំណាងរាស្ត្រ ជាទូទៅធ្វើការបញ្ចេញមតិតាមរយៈការលើកដៃ ការបោះឆ្នោតជាចំហ ឬការបោះឆ្នោតជាសម្ងាត់។[43]

ចំពោះអភ័យឯកសិទ្ធិរបស់អ្នកតំណាងរាស្ត្រត្រូវបានចែកចេញជាពីរផ្នែក[44]៖

**អភ័យឯកសិទ្ធិដាច់ខាត៖** ជាការធានាក្នុងការបញ្ចេញមតិ ឬការបញ្ចេញយោបល់ក្នុងការអនុម័តទាំងឡាយ របស់តំណាងរាស្ត្រនៅក្នុងក្របខណ្ឌនៃការបំពេញតួនាទីជាតំណាងរាស្ត្រ។

**អភ័យឯកសិទ្ធិដោយប្រៀប៖** ការធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន តំណាងរាស្ត្រណាមួយ គឺជាអភ័យឯកសិទ្ធិដោយប្រៀបរបស់តំណាងរាស្ត្រ។

អ្នកតំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពី បានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រម ពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភាវៀរលែងតែក្នុងករណី បទល្មើសព្រហ្មទណ្ឌជាក់ស្ដែង។ ក្នុងករណីខាងក្រោយនេះក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្ដីរាយការណ៍ ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច។[45] ដោយសារតំណាងត្រូវ បានការពារដោយអភ័យឯកសិទ្ធិនេះហើយ ទើបមុននឹងមានការចោទប្រកាន់តាមរូបភាពផ្សេងៗ ឬមួយក៏ត្រូវ ទទួលខុសត្រូវចំពោះមុខច្បាប់ព្រហ្មទណ្ឌ គេត្រូវធ្វើការដកហូតអភ័យឯកសិទ្ធិគាត់ជាមុនសិន។ នីតិវិធីក្នុងការ

---

[42] ឈុន ណាវ៉េត, *សេចក្ដីផ្ដើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ផាងពុម្ព ដារ៉ា,២០១៦), ១៣៨។

[43] បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា, ២៧ តុលា ឆ្នាំ១៩៩៣, ប្រការ៣៦ ថ្មី។

[44] ច្បាប់ស្ដីពីលក្ខន្តិកៈតំណាងរាស្ត្រ,លេខ នស/រកម/១០០៦/០២៥, ៣១ សីហា ឆ្នាំ២០០៦, មាត្រា៤។

[45] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៨០។

ដកអភ័យឯកសិទ្ធិនេះ តម្រូវឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាធ្វើសំណើដាក់ទៅសម័យប្រជុំពេញអង្គនៃរដ្ឋសភាធ្វើការអនុម័តតាមសម្លេងភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។ [46] ចំណែកឯតំណាងរាស្ត្ររូបណាមួយជាទណ្ឌិត ហើយត្រូវបានព្រះមហាក្សត្រលើកលែងទោសតំណាងរាស្ត្ររូបនោះនឹងបានទទួលសុពលភាពអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិឡើងវិញ។ [47] តាមរយៈនេះបញ្ជាក់ឱ្យឃើញថា រដ្ឋធម្មនុញ្ញមិនបានកំណត់នូវករណីយកិច្ច ដែលឱ្យទទួលខុសត្រូវណាមួយមកលើអ្នកតំណាងរាស្ត្រក៏ដោយ ក៏រដ្ឋសភាខ្លួនឯងបានធ្វើការគិតគូរដិតដល់សម្រាប់ការទទួលខុសត្រូវក្នុងស្ថាប័នខ្លួនដែរ គឺតាមរយៈបទបញ្ជាផ្ទៃក្នុងសភាដែលត្រូវបានអនុម័តតាំងពីឆ្នាំ១៩៩៤ មក។

**ខ.១.៣. សិទ្ធិសម្រេចរបស់អ្នកតំណាងរាស្ត្រ**

តំណាងរាស្ត្រ គឺជារូបវន្តបុគ្គលដែលទទួលបានសិទ្ធិក្នុងការបញ្ចេញមតិ ឬសម្រេចលើទៅលើកិច្ចការទាំងឡាយណា ដែលនាំប្រយោជន៍ជូនប្រជាពលរដ្ឋទូទាំងប្រទេសតាមរយៈរដ្ឋសភា ដែលជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ រាល់កិច្ចការទាំងឡាយត្រូវស្របតាមឆន្ទៈប្រជាពលរដ្ឋទូទាំងប្រទេស។ តំណាងរាស្ត្រគ្រប់រូបមានសិទ្ធិក្នុងការសម្រេចនូវកិច្ចការសំខាន់ៗមួយចំនួនដូចជា៖

- រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់គេ ការឱ្យរដ្ឋឱ្យគេខ្ចីប្រាក់ ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ
- រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល
- រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ
- រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ
- រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម។[48]

**ខ.២. មុខងារបង្កើត និងទម្លាក់រាជរដ្ឋាភិបាល**

**ខ.២.១. មុខងារបង្កើតរាជរដ្ឋាភិបាល**

រដ្ឋសភា ជាអ្នកផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាល (ការបង្កើតរាជរដ្ឋាភិបាល) តាមរយៈមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល នេះបើយោងទៅតាមមាត្រា៩០ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ។[49] ក្នុងករណីចាំបាច់ ដែលមានភាពជាប់គាំងនយោបាយមិនអាចបង្កើតរាជរដ្ឋាភិបាលបាន រដ្ឋសភាមានសិទ្ធិប្រើប្រាស់ច្បាប់ធម្មនុញ្ញបន្ថែមដើម្បីដោះស្រាយភាពជាប់គាំងនយោបាយតាមរយៈមាត្រា៣ ថ្មី(មួយ),៤ ថ្មី(មួយ),៥ និងមាត្រា៦

[46] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៨០, វាក្យខណ្ឌទី៥។

[47] ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ,លេខ នស/រកម/១០០៦/០២៥, ៣១ សីហា ឆ្នាំ២០០៦, មាត្រា១៥។

[48] យូ តូនី, មេរៀននីតិរដ្ឋធម្មនុញ្ញ (២០១៨), ៨១។

[49] ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ធាងពុម្ព ដារ៉ា,២០១៦), ១៤៣។

នៃច្បាប់ធម្មនុញ្ញបន្ថែម។ បើរាប់ចាប់តាំងពីការបង្កើតរាជរដ្ឋាភិបាលអាណត្តិទី១ មកទល់នឹងបច្ចុប្បន្នរដ្ឋសភាអាចបង្កើតរាជរដ្ឋាភិបាលបានតាមរូបភាពពីរ (០២) ដែលរូបភាពទី១ ហៅថា (រដ្ឋសភាកើតមុនរាជរដ្ឋាភិបាល) និងរូបភាពទី២ (រដ្ឋសភា និងរាជរដ្ឋាភិបាលកើតដំណាលគ្នា)។

### ខ.២.១.១.រដ្ឋសភាកើតមុនរាជរដ្ឋាភិបាល

**តាមរូបភាពទី១** មុនមាត្រា១១៩ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម បានចែងថា នៅពេលដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្ររួចហើយ រដ្ឋសភាផ្តើមបើកសម័យប្រជុំដំបូង ៦០ (ហុកសិប) ថ្ងៃយ៉ាងយូរ តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការទាំងមូល។ ហើយប្រធានរដ្ឋសភា ត្រូវបោះឆ្នោតជ្រើសរើសចេញពីសមាជិករដ្ឋសភាដែលមានសញ្ជាតិខ្មែរតែមួយគត់។[50]

បន្ទាប់មកតាមរយៈសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភាបន្ទាប់មក ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្ស ដែលឈ្នះឆ្នោតក្នុងរដ្ឋសភា ឱ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ដើម្បីផ្តួងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល បន្ទាប់មកស្នើសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ ហើយបើរដ្ឋសភាបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តតាមមតិភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិករដ្ឋសភាទាំងមូលរួចហើយ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។ មុនចូលកាន់តំណែង សមាជិកគណៈរដ្ឋមន្ត្រីទាំងអស់ត្រូវធ្វើសច្ចាប្រណិធានចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រ ដូចមានចែងក្នុងខ្លឹមសារនៃឧបសម្ព័ន្ធទី៦។[51]

ក្រោយមាត្រា១១៩ ថ្មី (មួយ) ត្រូវបានធ្វើវិសោធនកម្មក្លាយជាមាត្រា១១៩ ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ដែលត្រូវប្រកាសឱ្យប្រើនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ កន្លងទៅបានចែងថា៖ តាមសេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបជានាយករដ្ឋមន្ត្រីឱ្យបង្កើតរាជរដ្ឋាភិបាល។ សេចក្តីស្នើពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភានេះ ត្រូវចម្លងជូនប្រធានរដ្ឋសភា។ វរជនដែលនឹងត្រូវទទួលបានការចាត់តាំងជានាយករដ្ឋមន្ត្រីនេះត្រូវតែជាតំណាងរាស្ត្រដែលមានសញ្ជាតិខ្មែរតែមួយគត់ និងត្រូវជ្រើសរើសចេញពីគណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្ស

[50] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៨២ ថ្មី(មួយ)។

[51] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ១៩៩៩, មាត្រា១១៩ ថ្មី(មាត្រា១០០ ចាស់)។

តំណាងនៅក្នុងរដ្ឋសភាដែលផ្គូផ្គងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ដើម្បីសុំសេចក្ដីទុកចិត្តពីរដ្ឋសភា។ ការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តនេះ ត្រូវធ្វើលើបញ្ជីសមាសភាពនៃគណៈរដ្ឋមន្ត្រីទាំងមូល។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តរួចហើយ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។ មុនចូលកាន់តំណែង គណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធានដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៦។

នៅពេលផុតនីតិកាលនីមួយៗរបស់រដ្ឋសភា រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។[52]

**ខ.២.១.២.រដ្ឋសភា និងរាជរដ្ឋាភិបាលកើតក្នុងពេលតែមួយ**

**តាមរូបភាពទី២** ក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញបន្ថែម គេចង់សំដៅទៅលើការបង្កើតរដ្ឋសភា និងរាជរដ្ឋាភិបាលក្នុងពេលតែមួយ ត្រង់នេះបានន័យថា គឺជាការធានាឱ្យបាននូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលស្ថិតក្នុងស្ថានភាពតានតឹងមួយមិនអាចកំណត់បានឱ្យល្អប្រសើរ នេះជាសេនារីយ៉ូពិសេសមួយដើម្បីគាំពារនូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិក្នុងការធានាឱ្យប្រជាជាតិកាន់តែរឹងមាំ។ ក្នុងរូបភាពទីពីរនេះ គឺអាចអនុញ្ញាតឱ្យមានការបង្កើតរដ្ឋសភា និងរាជរដ្ឋាភិបាលនៅពេលតែមួយបាន តាមរយៈការបោះឆ្នោតជាកញ្ចប់។[53]

យោងតាមប្រសាសន៍របស់**ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** តាមរយៈសន្និសីទសារព័ត៌មានកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ បានបញ្ជាក់ថា មាត្រា៣ ថ្មី(មួយ), ៤ ថ្មី(មួយ) នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅដល់ការធានាបាននូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិទាក់ទងនឹងការបោះឆ្នោតជាកញ្ចប់ក្នុងការបង្កើតរាជរដ្ឋាភិបាល និងការរៀបចំក្បាលម៉ាស៊ីនរដ្ឋសភាក្នុងពេលតែមួយនៅដើមនីតិកាលនៃរដ្ឋសភា។[54] រីឯមាត្រា៥ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែម គឺជាការធានានៅក្នុងពេលដំណើរការនៃការបោះឆ្នោតឱ្យប្រាកដថា គ្មានការពន្យល់អំពីការបោះឆ្នោតនេះ ក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោតជាកញ្ចប់ហើយត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងអស់។[55]

**ខ.២.២. មុខងារទម្លាក់រាជរដ្ឋាភិបាល**

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញត្តិបន្ទោសតាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិកទាំងមូល នេះបើយោងតាមមាត្រា៩៨ ថ្មី(មួយ)។ តាមខ្លឹមសារនៃមាត្រាខាងលើនេះបានបញ្ជាក់ថា ក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីមុខតំណែងដោយរដ្ឋសភា

---

52 រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ២០២២, មាត្រា១១៩ ថ្មី(ពីរ)។

53 គន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨), ២៤៧។

54 ទូរទស្សន៍ជាតិកម្ពុជា ទទក, *សន្និសីទសារព័ត៌មាន ស្ដីពីសេចក្ដីព្រាងច្បាប់ធម្មនុញ្ញ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ*, (ភ្នំពេញ, ១៤ កក្កដា ២០២២), https://www.youtube.com/watch?v=ChHuvw5oer0, ទស្សនាចុងក្រោយនៅថ្ងៃទី១០ខែ៦ឆ្នាំ២០២៤។

55 ច្បាប់ធម្មនុញ្ញបន្ថែមកម្ពុជា ឆ្នាំ២០០៤, មាត្រា៥, និងមាត្រា៦ ថ្មី។

រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែងនេះ មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មាន រាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។[56]

**សម្គាល់៖** បើរដ្ឋសភាទម្លាក់គណៈរដ្ឋមន្ត្រី ឬទម្លាក់នាយករដ្ឋមន្ត្រីបានន័យថា គឺជាការទម្លាក់រាជរដ្ឋាភិបាល ទាំងមូលតែម្តង។ ប៉ុន្តែបើក្នុងករណីទម្លាក់សមាជិកគណៈរដ្ឋមន្ត្រីណាម្នាក់ដោយញត្តិបន្ទោសនោះបានន័យថា ជាការទម្លាក់តែសមាជិកនោះតែម្នាក់ទេ។

### ខ.៣. មុខងារនីតិកម្ម

រដ្ឋសភាជាស្ថាប័ននីតិបញ្ញត្តិ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំតាក់តែងច្បាប់ អនុម័តច្បាប់ក៏ដូចជា ការធ្វើវិសោធនកម្មលើច្បាប់នានា និងរដ្ឋធម្មនុញ្ញជាដើម ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញមាត្រា៩០ ថ្មី(ពីរ) និង មាត្រា៩១ ថ្មី នៃរដ្ឋធម្មនុញ្ញ។

តាមមាត្រា៩០ ថ្មី(ពីរ) បានបញ្ជាក់ថា រដ្ឋសភាជាអង្គការនីតិបញ្ញត្តិ បានន័យថាមានសិទ្ធិគ្រប់គ្រាន់ក្នុងការ តាក់តែង និងអនុម័តច្បាប់ទាំងអស់ បន្ទាប់មកត្រូវបញ្ជូនទៅកាន់ព្រឹទ្ធសភាដើម្បីត្រួតពិនិត្យ និងថ្វាយព្រះមហាក្សត្រ ឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើ។

មាត្រា៩១ ថ្មី នៃរដ្ឋធម្មនុញ្ញកាន់តែបញ្ជាក់ច្បាស់ទៀតអំពីតួនាទីជាអង្គការនីតិបញ្ញត្តិរបស់សភា។ ក្នុងមាត្រាដដែល នេះបានបញ្ជាក់ថា អ្នកតំណាងរាស្ត្រមានសិទ្ធិដើម្បីតាក់តែងច្បាប់នានាបាន។ រដ្ឋសភាមានសិទ្ធិធ្វើវិសោធនកម្ម ច្បាប់នានា ដែលប្រកាសឱ្យប្រើប្រាស់បានរួចហើយ រដ្ឋសភាក៏អាចកែប្រែ ឬធ្វើវិសោធនកម្មបានទាំងអស់។ លើសពីនោះទៅទៀតតំណាងរាស្ត្រមិនត្រឹមតែមានសិទ្ធិធ្វើវិសោធនកម្មច្បាប់នានាប៉ុណ្ណោះទេ តែមានសិទ្ធិ ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញទៀតផង។[57]

ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី និង ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួន(១/៤)នៃចំនួនសមាជិករដ្ឋសភាទាំងមូល។[58]

ការសើរើ ឬធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយដែលអនុម័តដោយសភាតាមមតិ ភាគច្រើនពីរភាគបី(២/៣) នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

[56] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ២០២២, មាត្រា៩៨ ថ្មី(មួយ)។

[57] ឈុន ណារ៉េត, *សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ផាងពុម្ព ដារ៉ា,២០១៦), ១៤០។

[58] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្ម, មាត្រា១៥៣ ថ្មី(ពីមាត្រា ១៥១ ថ្មី)។

**សម្គាល់៖** ការអនុម័ត និងការធ្វើវិសោធនកម្មច្បាប់មួយចំនួនត្រូវបានហាមឃាត់មិនឱ្យមានការកែប្រែផងដែរ រួមមានដូចខាងក្រោម៖

- អនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់នយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអាសារសូន្យយោងតាមមាត្រា៩២ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣
- ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនធ្វើនៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា៧៧, ៨៦ និងតាមមាត្រា១៥៤ ថ្មី (ពីរ មាត្រា១៥២ ថ្មី)
- ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ យោងតាមមាត្រា១៥៥ ថ្មី (ពីរ មាត្រា១៥៣ ថ្មី)
- ប្រការដែលព្រះមហាក្សត្រគ្រងរាជ្យសម្បត្តិ ប៉ុន្តែមិនកាន់អំណាចឡើយ ហើយដែលមានចែងក្នុងវាក្យខណ្ឌទីមួយនៃមាត្រា៧ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ មិនអាចសុំឱ្យកែប្រែបានជាដាច់ខាត (មាត្រា១៧ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣)។[59]

**ខ.៣.១. ការធ្វើច្បាប់ដែលស្នើឡើងដោយសភា**

ច្បាប់ដែលស្នើឡើងដោយសមាជិកនៃរដ្ឋសភា ឬព្រឹទ្ធសភាហៅថា សេចក្តីស្នើច្បាប់។ ប្រការ២២ ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាបានចែងថា សេចក្តីស្នើច្បាប់ដែលតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាជាអ្នកធ្វើនោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរចែងជាមាត្រា ហើយមានសេចក្តីថ្លែងហេតុនៅខាងដើមជាប់មកជាមួយផង។ អ្នកតាក់តែងសេចក្តីស្នើច្បាប់មានសិទ្ធិចូលរាយការណ៍ជម្រាបគណៈកម្មការ ដែលពិនិត្យសេចក្តីស្នើនោះ។[60]

គិតត្រឹមខែកញ្ញា ឆ្នាំ២០២៤ ព្រះរាជាណាចក្រកម្ពុជាមានច្បាប់រហូតដល់៦៣២ច្បាប់ ដែលសភាបានអនុម័ត និងត្រូវបានប្រកាសឱ្យប្រើ។[61]

**ខ.៣.២. ការធ្វើច្បាប់ដែលស្នើឡើងដោយរាជរដ្ឋាភិបាល**

ច្បាប់ដែលស្នើឡើងដោយក្រសួង រដ្ឋមន្ត្រីណាមួយ ឬគណៈរដ្ឋមន្ត្រីគេហៅថា សេចក្តីព្រាងច្បាប់។ មុនដាក់ជូនរដ្ឋសភា គណៈរដ្ឋមន្ត្រីត្រូវអនុម័តសេចក្តីព្រាងច្បាប់នេះ បន្ទាប់មកបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ដោយមានភ្ជាប់មកជាមួយនឹងសេចក្តីថ្លែងហេតុ ហើយចែកជូនពង្រាងច្បាប់ជាលាយលក្ខណ៍អក្សរ និងសេចក្តីថ្លែងហេតុនោះទៅគ្រប់តំណាងរាស្ត្រនៃរដ្ឋសភាជាតិ។ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាក្រោយបាន

---

[59] គន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨), ១៤៧, ១៤៨។

[60] កៅ មុយថង,និងមុី វិចិត្រ, *រដ្ឋធម្មនុញ្ញកម្ពុជា* (ភ្នំពេញ៖បណ្ណាគារអង្គរ,២០០៦លើកទី១), ២០៤។

[61] ស្ថាប័នរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, បញ្ជីច្បាប់នីតិកាលទី៧, https://nac.org.kh/group-law/118, ទស្សនាចុងក្រោយនៅថ្ងៃទី២៥ ខែ៨ ឆ្នាំ២០២៤។

ទទួលពង្រាងច្បាប់នោះហើយ ត្រូវបញ្ជូនទៅបន្តទៅគណៈកម្មការតាមមុខជំនាញឱ្យពិនិត្យ បើកាលណាពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការនោះត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនរដ្ឋសភាដើម្បីជ្រាប។[62]

យោងតាមប្រការ២៤ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាបានចែងថា៖ សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នៅពេលណាដែលគេបញ្ជូនទៅដល់គណៈកម្មការជំនាញរួចហើយ គណៈកម្មការនោះមានសិទ្ធិដូចតទៅ៖

- សូមឱ្យរដ្ឋសភាលើកចោលពុំពិចារណាក៏បាន
- សូមឱ្យរដ្ឋសភាបញ្ចេញមតិជាមុនសិន តើគួរយកមកធ្វើការពិចារណា ឬទេ
- សូមឱ្យរដ្ឋសភាទទួលពិចារណា ហើយនឹងទុកជាការប្រញាប់។[63]

**ខ.៣.៣. នីតិវិធីពិនិត្យ និងអនុម័តច្បាប់នៅក្នុងរដ្ឋសភា**

នៅក្នុងនីតិវិធីពិនិត្យ និងអនុម័តនេះមានពីរដំណាក់កាលសំខាន់នោះរួមមាន៖ ទីមួយ គណៈកម្មាធិការអចិន្ត្រៃយ៍ (ខ.៣.៣.១) និងទីពីរ គណៈកម្មការជំនាញ (ខ.៣.៣.២)។

**ខ.៣.៣.១. គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា**

ក្រោយពីបានទទួលសេចក្តីព្រាងច្បាប់ពីរាជរដ្ឋាភិបាល ឬសេចក្តីស្នើច្បាប់ពីសមាជិកសភារួចប្រធានរដ្ឋសភាកោះប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យលើទម្រង់ច្បាប់ និងនីតិវិធី រួចសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ឱ្យគណៈកម្មការជំនាញពិនិត្យ។[64]

យោងតាមប្រការ៧ ថ្មី បានចែងថា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាមានសមាសភាពដូចខាងក្រោម៖

- ប្រធានរដ្ឋសភា
- អនុប្រធានទាំងពីរ នៃរដ្ឋសភា
- ប្រធានគណៈកម្មការជំនាញទាំង១០ នៃរដ្ឋសភា។

តាមខ្លឹមសារនៃប្រការខាងលើបានបន្តបញ្ជាក់ថា ប្រធានរដ្ឋសភាជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។ ហើយរាល់ការប្រជុំម្តងៗអាចយកជាផ្លូវការបានលុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិក។[65]

---

[62] កៅ មុយថង,និងម៉ី វិចិត្រ, *រដ្ឋធម្មនុញ្ញកម្ពុជា* (ភ្នំពេញ៖បណ្ណាគារអង្គរ,២០០៦លើកទី១), ២០៥។

[63] បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា, ២៧ តុលា ១៩៩៣, ប្រការ១៤។

[64] គន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨), ១៤៧, ១៤៩។

[65] បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា, ២៧ តុលា ១៩៩៣, ប្រការ៧ ថ្មី។

### ខ.៣.៣.២. គណៈកម្មការជំនាញ

គណៈកម្មការជំនាញត្រូវរៀបចំកិច្ចប្រជុំពិនិត្យផ្ទៃក្នុង។ គណៈកម្មការជំនាញអាចរៀបចំវេទិកាសាធារណៈ ដើម្បីស្តាប់ និងប្រមូលអនុសាសន៍ពីសាធារណមតិ។ ហើយអាចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ឬតំណាងក្រុមតំណាងរាស្ត្រ ឬក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខីនៃសេចក្តីស្នើច្បាប់(ប្រជុំមួយលើក ឬច្រើនលើក កែប្រែ ឬរក្សាទុកទាំងស្រុង) រួចអនុម័តព្រម ឬមិនព្រមដាក់ចូលសម័យប្រជុំរដ្ឋសភា។

កូរ៉ុមសម្រាប់ការប្រជុំគណៈកម្មការនានា ត្រូវឱ្យមានលើសពីពាក់កណ្តាលនៃសមាជិកទាំងមូល។ ឯការអនុម័តត្រូវយកតាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ គណៈកម្មការជំនាញធ្វើលិខិតជូនប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារួចហើយធ្វើរបាយការណ៍អំពីលទ្ធផលនៃការពិនិត្យសេចក្តីស្នើច្បាប់ ឬជាសេចក្តីព្រាងច្បាប់។ បន្ទាប់មកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាជួបប្រជុំពិនិត្យ និងអនុម័តបញ្ចូលក្នុងរបៀបវារៈសម័យប្រជុំរដ្ឋសភា បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាមកទល់នឹងបច្ចុប្បន្នបានបង្កើតគណៈកម្មការចំនួន១០ដោយឡែកៗពីគ្នា ដែលមានសមត្ថកិច្ចពាក់ព័ន្ធ និងវិស័យការងារជាក់លាក់មួយចំនួន។[66] គណៈកម្មការជំនាញនៃរដ្ឋសភារួមមានដូចខាងក្រោម៖

- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា
- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
- គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
- គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ
- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
- គណៈកម្មការនីតិកម្ម និងយុត្តិធម៌
- គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍
- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
- គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់។
- គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ។

[66] គន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨), ១៤៧, ១៥០។

### ២.២.១.៣. ស្ថាប័នព្រឹទ្ធសភា

ក្រោយការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទីពីរឆ្នាំ១៩៩៩ គេបានឃើញថាមានស្ថាប័នថ្មីមួយលេចឡើង គឺស្ថាប័នព្រឹទ្ធសភា ផ្ដើមបើកសម័យប្រជុំលើកទីមួយរបស់ខ្លួននៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ (គួរបញ្ជាក់ស្ថាប័ននេះធ្លាប់បានកើតឡើងពីឆ្នាំ១៩៤៧មក)។ ព្រឹទ្ធសភា គឺជាអង្គការនីតិបញ្ញត្តិកំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ជាស្ថាប័នដែលមានលក្ខណៈឯករាជ្យ និងដាច់ដោយឡែកពីអង្គការនីតិប្រតិបត្តិ។ ស្ថាប័នព្រឹទ្ធសភាមានសមាជិកស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ដែលសមាជិកម្នាក់ៗកើតចេញពីការចាត់តាំងខ្លះ និងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ។ ចំពោះនីតិកាលរបស់ព្រឹទ្ធសភាមានរយៈពេល ៦ឆ្នាំបើរាប់ចាប់ពីនីតិកាលទី២ មកទល់នឹងបច្ចុប្បន្ននេះ ដោយឡែកចំពោះនីតិកាលទី១ មានតែរយៈពេល៥ឆ្នាំតែប៉ុណ្ណោះ។[67]

គិតចាប់តាំងពីឆ្នាំ១៩៩៩ មកទល់នឹងបច្ចុប្បន្នស្ថាប័នព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាបានដំណើរការសកម្មភាពរបស់ខ្លួនបានចំនួន៥ នីតិកាលរួចមកហើយ ដែលនីតិកាលនីមួយៗ មានដូចខាងក្រោម៖

- នីតិកាលទី១ បើកសម័យប្រជុំដំបូងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩
- នីតិកាលទី២ បើកសម័យប្រជុំដំបូងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦
- នីតិកាលទី៣ បើកសម័យប្រជុំដំបូងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១២
- នីតិកាលទី៤ បើកសម័យប្រជុំដំបូងនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨
- នីតិកាលទី៥ បើកសម័យប្រជុំដំបូងនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤។[68]

#### ក. ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

ជាទូទៅការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវបានធ្វើឡើងជារៀងរាល់៦ឆ្នាំម្តង នៅថ្ងៃអាទិត្យសប្តាហ៍ទី៨ មុនដំណាច់ឆ្នាំទី៦ នៃនីតិកាលព្រឹទ្ធសភា។ ការបោះឆ្នោតនេះត្រូវអនុវត្តទៅតាមប្រព័ន្ធសមាមាត្រ និងមានការបែងចែកអាសនៈតាមមណ្ឌលនៃភូមិភាគ ហើយត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត។[69] ព្រឹទ្ធសភាមានសមាជិកស្មើនឹងពាក់កណ្តាលនៃចំនួនរដ្ឋសភាទាំងមូល ដែលសមាជិកទាំងនេះត្រូវបានចាត់តាំងខ្លះ និងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកខ្លះ។[70]

ប៉ុន្តែបើក្នុងករណីប្រទេសមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើតព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំតាមសំណើរបស់ព្រះមហាក្សត្រ។

---

67 សុខ យ៉ាន និងម៉ុក ដារ៉ា, *នីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖២០១២), ២៧។

68 អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស, *ការបន្តសម័យប្រជុំដំបូងព្រឹទ្ធសភានីតិកាលទី៥,* https://pressocm.gov.kh/archives/94098 (ភ្នំពេញ,២០២៤), ទស្សនាចុងក្រោយនៅថ្ងៃទី២៥ខែ៥ឆ្នាំ២០២៤។

69 យូ តូនី, *មេរៀននីតិរដ្ឋធម្មនុញ្ញ* (២០១៨), ៨២។

70 សុខ យ៉ាន,និងម៉ុក ដារ៉ា, *នីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖២០១២), ២៨។

ការប្រកាសនីតិកាលរបស់ព្រឹទ្ធសភា ត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[71]

ព្រឹទ្ធសភាមានសមាជិកស្មើនឹងពាក់កណ្តាលនៃចំនួនរដ្ឋសភាទាំងមូល ក្នុងករណីមានការប្រែប្រួលនៃចំនួនប្រជាពលរដ្ឋ ក៏ដូចជាភូមិសាស្ត្រ ដូច្នេះចំនួនអាសនៈនៅក្នុងព្រឹទ្ធសភាក៏មានការប្រែប្រួលផងដែរ ជាក់ស្តែងចំនួនអាសនៈនៅក្នុងព្រឹទ្ធសភាគិតត្រឹមនីតិកាលទី៥នេះមានការប្រែប្រួលដូចខាងក្រោម៖

– នីតិកាលទី១ មានចំនួន៦១អាសនៈ
– នីតិកាលទី២ មានចំនួន៦១អាសនៈ
– នីតិកាលទី៣ មានចំនួន៦១អាសនៈ
– នីតិកាលទី៤ មានចំនួន៦២អាសនៈ
– នីតិកាលទី៥ មានចំនួន៦២អាសនៈ។

ចំពោះអ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភាតម្រូវឱ្យមានលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុ៤០ ឆ្នាំឡើងទៅបើគិតដល់ថ្ងៃបោះឆ្នោត
- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- មានការតែងតាំងពីគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត។

រីឯអ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺតំណាងរាស្ត្រក្នុងមុខតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែងក្នុងក្របខណ្ឌនៃភូមិភាគនីមួយៗ។[72] ដើម្បីបោះឆ្នោតបានត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- មានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- មានឈ្មោះក្នុងបញ្ជីបោះឆ្នោត
- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- ពុំមែនជាជនវិកលចរិក ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។[73]

[71] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា១០២ ថ្មី(មួយ)។
[72] គន យឿន, រៀបរៀង, *មូលដ្ឋានច្បាប់ និង ស្ថាប័នច្បាប់* (២០១៨), ១៨៦។
[73] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា, លេខ នស/រកម/០៦០៥/០២០, ២១ កក្កដា ២០១៧, មាត្រា១១។

### ខ. តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភាមានតួនាទីសំខាន់ គឺជាស្ថាប័ននីតិបញ្ញត្តិកំពូលរបស់រដ្ឋ ដែលមានភារកិច្ចសម្រិតសម្រាំងច្បាប់ និងធ្វើជាអាជ្ញាកណ្តាលក្នុងការសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល។ តាមរយៈកិច្ចការនេះព្រឹទ្ធសភាមានមុខងារសំខាន់ចំនួនពីរទៀត(០២) រួមមាន៖ មុខងារជាតំណាង(ខ.១) និងមុខងារនីតិកម្ម(ខ.២)។

#### ខ.១. មុខងារតំណាង

ព្រឹទ្ធសភា មិនមែនគ្រាន់តែជាអ្នកតំណាងឱ្យភូមិភាគនីមួយៗដែលទទួលបានសម្លេងឆ្នោតនោះឡើយ ព្រោះសមាជិកព្រឹទ្ធសភាចំនួនពីរ(០២)រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកព្រឹទ្ធសភាចំនួនពីរ(០២) រូបទៀតត្រូវបានរដ្ឋសភាជ្រើសតាំងតំណាងស្ថាប័នជាតិ និងសមាជិកផ្សេងទៀតតំណាងឱ្យសមូលហភាពដែនដីត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។[74]

##### ខ.១.១. តំណាងសមូលហភាពដែនដី(ក្រុមប្រឹក្សាឃុំ សង្កាត់)

ព្រឹទ្ធសភាតំណាងឱ្យភូមិភាគ និងសមូលហភាពដែនដី(ក្រុមប្រឹក្សាឃុំ សង្កាត់) មាត្រា៩ និងមាត្រា១១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា បានបង្ហាញយ៉ាងច្បាស់អំពីអត្តសញ្ញាណរបស់សមាជិកព្រឹទ្ធសភា។[75] ការបែងចែកអាសនៈតាមមណ្ឌលត្រូវបានអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតហើយមានមណ្ឌលបោះឆ្នោតត្រូវបានរៀបចំ និងបែងចែកជាប្រាំបី(០៨) ភូមិភាគដោយមានចែងដូចខាងក្រោម៖

- ភូមិភាគទី១ រាជធានីភ្នំពេញ (មាន៦អាសនៈ)
- ភូមិភាគទី២ រួមមាន៖ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ (មាន៨អាសនៈ)
- ភូមិភាគទី៣ ខេត្តកណ្តាល (មាន៥អាសនៈ)
- ភូមិភាគទី៤ រួមមាន៖ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន (មាន១០អាសនៈ)
- ភូមិភាគទី៥ រួមមាន៖ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប (មាន៧អាសនៈ)
- ភូមិភាគទី៦ រួមមាន៖ ខេត្តព្រៃវែង និងខេត្តស្វាយរៀង (មាន៧អាសនៈ)
- ភូមិភាគទី៧ រួមមាន៖ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ (មាន៩អាសនៈ)
- ភូមិភាគទី៨ រួមមាន៖ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី (មាន៦អាសនៈ)។[76]

---

[74] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ១៩៩៩, មាត្រា១០០ ថ្មី។

[75] គន យឿន, *មូលដ្ឋានច្បាប់ និង ស្ថាប័នច្បាប់* (២០១៨), ១៩៥។

[76] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា, លេខ នស/រកម/០៦០៥/០២០, ២១ កក្កដា ២០១៧, មាត្រា៩។

ភាពជាតំណាង ក្រុមប្រឹក្សាឃុំ សង្កាត់ នាំឱ្យព្រឹទ្ធសភាមានបេសកកម្មផ្ទាល់របស់ខ្លួនក្នុងលក្ខណៈពិសេសមួយ ដោយត្រូវផ្សារភ្ជាប់ការងាររបស់ខ្លួនទៅនឹងកិច្ចការពារ និងលើកតម្កើងផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងប្រទេស រួមទាំងភូមិភាគទាំង៨ ទៀតផង។ ដូច្នេះ ព្រឹទ្ធសភាមានកាតព្វកិច្ចចូលរួមចំណែកយ៉ាងខ្ជាប់ខ្ជួន ក្នុងការតាមដានមើលលើការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ពោលគឺជួយជំរុញធ្វើឱ្យមាន ការអភិវឌ្ឍបានត្រឹមត្រូវតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។[77]

**ខ.១.២. អភ័យឯកសិទ្ធិរបស់ព្រឹទ្ធសភា**

សមាជិកព្រឹទ្ធសភាមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា និងមានអភ័យឯកសិទ្ធិសភា។[78] អភ័យឯកសិទ្ធិសភាត្រូវបានបែងចែកចេញជាពីររួមមាន៖ អភ័យឯកសិទ្ធិដាច់ខាត និង អភ័យឯកសិទ្ធិដោយប្រៀប សេចក្តីពិស្តារអំពីអភ័យឯកសិទ្ធិនេះបានរៀបរាប់នៅចំណុចខាងលើរួចមកហើយ។ មិនខុសពីរដ្ឋសភាទេ សមាជិកព្រឹទ្ធសភាគ្រប់ៗរូបសុទ្ធតែមានអភ័យឯកសិទ្ធិដូចគ្នាក្នុងការបំពេញមុខងាររបស់ខ្លួន ដើម្បីទទួលបាននូវប្រសិទ្ធភាពខ្ពស់ ដោយគ្មានសមាជិកព្រឹទ្ធសភាណាម្នាក់ត្រូវបានដកអភ័យឯកសិទ្ធិសភា ដោយមិនមានការយល់ព្រមពីព្រឹទ្ធសភាបានឡើយ។ គ្រប់យ៉ាងត្រូវបានធានាដោយរដ្ឋធម្មនុញ្ញចាប់តាំងពីផ្តើម នីតិកាលទី១ មក យោងតាមមាត្រា១០៤ ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា សមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា សមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ដោយហេតុពីបានសម្តែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។[79]

**ខ.១.៣. តំណាងស្ថាប័នជាតិ**

សមាជិកព្រឹទ្ធសភាពីរ(០២) រូបត្រូវបានតែងតាំងដោយព្រះមហាក្សត្រ និងពីរ(០២) រូបទៀតត្រូវបានជ្រើសតាំង ដោយរដ្ឋសភា។[80]ព្រឹទ្ធសភាតំណាងឱ្យព្រះមហាក្សត្រ និងរដ្ឋសភា ហើយក៏ជាអ្នកសម្របសម្រួលការងាររវាង រដ្ឋសភា និងរាជរដ្ឋាភិបាលផងដែរ តាមរយៈមាត្រា១១២ ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានផ្តល់នូវតួនាទី យ៉ាងសំខាន់ដល់ព្រឹទ្ធសភាអនុវត្តឥទ្ធិពលមួយសំខាន់លើការងាររវាងស្ថាប័នទាំងពីររួមមាន៖ រាជរដ្ឋាភិបាល និងរដ្ឋសភា។

នៅក្នុងមាត្រា១១២ ថ្មី ដដែលនេះមិនត្រូវបានអនុវត្តដោយមានប្រសិទ្ធភាពជាក់លាក់ទេ ដោយហេតុថាគ្មានការ បញ្ជាក់ឱ្យបានច្បាស់ពីសារធាតុដែលមាននៅក្នុងនោះឡើយ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនេះគ្រាន់តែ បញ្ជាក់ថា វាគ្រាន់តែជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា ដែលមិនអាចកំណត់បានដោយអត្ថបទច្បាប់ ឬ

---

[77] អគ្គលេខាធិការដ្ឋានរដ្ឋសភា ព្រឹទ្ធសភា, *សភាកម្ពុជា* (ភ្នំពេញ៖ ២០២១), ១៥៤។

[78] អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា, *ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា* (ភ្នំពេញ៖ ២០០៧), ១២។

[79] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ១៩៩៩, មាត្រា១០៤ ថ្មី។

[80] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ១៩៩៩, មាត្រា១០០ ថ្មី។

បទបញ្ញាណាមួយទេ។ ព្រឹទ្ធសភាត្រូវតែប្រើប្រាស់គ្រប់មធ្យោបាយក្នុងការធ្វើអន្តរាគមន៍ឱ្យបានគ្រប់ពេលវេលា ដើម្បីដោះស្រាយវិបត្តិនយោបាយតូចធំរវាងស្ថាប័នទាំងពីរ។ ព្រឹទ្ធសភាមិនអាចបង្ខំឱ្យស្ថាប័នទាំងពីរគោរពតាមទស្សនៈរបស់ខ្លួនតាមឆន្ទានុសិទ្ធិបានទេ និយាយមួយជ្រុងទៀតតួនាទីនេះមិនចងស្ថាប័នទាំងពីរនេះឡើយ។[81]

**ខ.១.៤. តំណាងប្រជាជាតិថ្នាក់មូលដ្ឋាន**

សមាជិកព្រឹទ្ធសភាភាគច្រើន ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកលមិនចំពោះ និងតាមនីតិវិធីបោះឆ្នោតជាសម្ងាត់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រមូលផ្តុំនៅក្នុងភូមិភាគទាំង៨។[82] ព្រឹទ្ធសភាមានកាតព្វកិច្ចចូលរួមចំណែកយ៉ាងខ្ជាប់ខ្ជួនក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងជួយផ្តល់អនុសាសន៍ ដើម្បីតម្រង់ទិសលើការអនុវត្តជាក់ស្តែងដល់ឃុំសង្កាត់ទូទាំងប្រទេស និងភូមិភាគ។ ប្រការនេះមានការពាក់ព័ន្ធដល់មូលដ្ឋានដ៏ធំដែលរាជរដ្ឋាភិបាលកំពុងកែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈព្រមទាំងការបង្វិតប្រជាធិបតេយ្យឱ្យទៅដល់ថ្នាក់មូលដ្ឋានឱ្យកាន់តែជិតប្រជាជន នេះគឺជាការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ភាពជាតំណាងបែបនេះមានចរិតពិសេសត្រង់ថា សមាជិកព្រឹទ្ធសភា គឺជាអ្នកជាប់ឆ្នោតតាមការជ្រើសតាំងដោយអ្នកជាប់ឆ្នោតទទួលបន្ទុកគ្រប់គ្រងដឹកនាំ ឃុំ សង្កាត់ទូទាំងប្រទេស និងតំណាងរាស្ត្រក្នុងតំណែង។[83]

**ខ.២. មុខងារនីតិកម្ម**

ព្រឹទ្ធសភាជាស្ថាប័ននីតិបញ្ញត្តិ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការពិនិត្យ និងឱ្យយោបល់ទៅលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬជាបញ្ហាទាំងពួងដែលរដ្ឋសភាបញ្ជូនមកឱ្យព្រឹទ្ធសភា ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១១៣ ថ្មី និងមានចែងក្នុងប្រការ៣២ បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា។

នេះបើយោងតាមមាត្រា១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានបញ្ជាក់ថា ព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួង ដែលរដ្ឋសភាដាក់ឱ្យពិនិត្យ។ បើសិនជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ។[84]

យោងតាមប្រការ៣២ បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា បានចែងថា សេចក្តីព្រាងច្បាប់ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូង ឬបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ស្នើឡើងដោយប្រធានរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភាត្រូវទទួលយកមកពិនិត្យ ព្រមទាំងចាត់បញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហា

[81] តន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨), ១៩៧។

[82] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា, លេខ នស/រកម/០៦០៥/០២០, ២១ កក្កដា ២០១៧, មាត្រា៩។

[83] តន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨), ១៩៨។

[84] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ១៩៩៩, មាត្រា១១៣ ថ្មី។

ទាំងពួងនោះទៅឱ្យគណៈកម្មការមួយ ឬច្រើនពិនិត្យសិក្សាទៅតាមវិស័យជាសមត្ថកិច្ច និងចម្លងចែកជូនគ្រប់សមាជិកព្រឹទ្ធសភាដោយមានភ្ជាប់សេចក្តីថ្លែងហេតុទៅជាមួយផង។

បើក្នុងករណីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះ ពាក់ព័ន្ធនឹងគណៈកម្មការច្រើន គណៈកម្មាធិការអចិន្ត្រៃយ៍ សម្រេចចាត់តាំងគណៈកម្មការណាមួយឱ្យទទួលបន្ទុកធ្វើរបាយការណ៍។[85]

គួរបញ្ជាក់ថា ក្រោយពីគណៈកម្មការ បានពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ឬសំណើសុំកែសម្រួលរួចហើយត្រូវធ្វើលិខិតស្នើសុំមកប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសុំដាក់បញ្ចូលក្នុងរបៀបវារៈនៃអង្គប្រជុំព្រឹទ្ធសភា និងនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងព្រឹទ្ធសភា។[86]

**ខ.២.១. ការធ្វើច្បាប់ដែលស្នើឡើងដោយព្រឹទ្ធសភា**

សេចក្តីស្នើច្បាប់ ដែលជាការផ្តួចផ្តើមពីសមាជិកព្រឹទ្ធសភាត្រូវសរសេរជាលាយលក្ខណ៍អក្សរ មានចំណងជើង ចែកជាជំពូក ចែកជាមាត្រា ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង។[87] ក្នុងប្រការដដែលបានបញ្ជាក់ថា សេចក្តីស្នើច្បាប់នេះត្រូវបញ្ជូនទៅរដ្ឋសភា។ ការបញ្ជូនទៅរដ្ឋសភានេះ គឺតាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា ក្រោយពីបានដាក់ឱ្យគណៈកម្មការជំនាញព្រឹទ្ធសភាផ្តល់យោបល់។[88]

ក្រោយការពិនិត្យឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួង ព្រឹទ្ធសភាត្រូវអនុវត្តតាមបទប្បញ្ញត្តិមាត្រា១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣។ តំណាងក្រុមសមាជិកព្រឹទ្ធសភានីមួយៗមានយោបល់ភ្លាមអំពីការយល់ព្រម ឬមិនយល់ព្រម ឬបញ្ចេញយោបល់ជំទាស់ បន្ទាប់ពីគណៈកម្មការបានបង្ហាញពីជំហរខ្លួនក្នុងរបាយការណ៍ក្នុងថិរវេលាមិនឱ្យលើសពីការកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា។[89]

**ខ.២.២. នីតិវិធីពិនិត្យ និងអនុម័តច្បាប់នៅក្នុងព្រឹទ្ធសភា**

មិនខុសពីរដ្ឋសភាទេនៅក្នុងនីតិវិធីពិនិត្យ និងអនុម័តច្បាប់របស់ព្រឹទ្ធសភា មានពីរដំណាក់កាលសំខាន់រួមមាន៖ ទីមួយ គណៈកម្មាធិការអចិន្ត្រៃយ៍(ខ.២.២.១) និងទីពីរ គណៈកម្មការជំនាញ(ខ.២.២.២)។

រាល់សេចក្តីព្រាងច្បាប់ដែលរាជរដ្ឋាភិបាលបានរៀបចំឡើង និងរាល់សេចក្តីស្នើច្បាប់ដែលសមាជិកសភាបានស្នើឡើងត្រូវបញ្ជូនទៅរដ្ឋសភា ដើម្បីពិនិត្យ និងអនុម័តជាលើកដំបូងរួចបានបញ្ជូនមកព្រឹទ្ធសភាពិនិត្យ និងឱ្យយោបល់។ បន្ទាប់ពីបានទទួលនូវអត្ថបទច្បាប់ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូងនោះរួចហើយ

[85] បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា, ១៨ កក្កដា ២០១២, ប្រការ, ៣២។
[86] បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា, ១៨ កក្កដា ២០១២, ប្រការ, ៣៣។
[87] បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា, ១៨ កក្កដា ២០១២, ប្រការ, ៣៤។
[88] អ៊ុក វណ្ណារ័ត្ន, *ការធ្វើច្បាប់ និងការអនុវត្តច្បាប់នៅកម្ពុជា* (២០០៨), ៣៧។
[89] បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា, ១៨ កក្កដា ២០១២, ប្រការ, ៥៧ ថ្មី, ៥៨។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាត្រូវយកមកពិនិត្យ ព្រមទាំងចាត់បញ្ជូននូវអត្ថបទច្បាប់ទៅគណៈកម្មាធិការជំនាញណាមួយ។

គណៈកម្មការជំនាញ ក្រោយពីបានទទួលអត្ថបទច្បាប់ពីគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវសុំយោបល់ពីសមាជិក សមាជិកាព្រឹទ្ធសភា (យល់ព្រម កែសម្រួល បដិសេធ) លើអត្ថបទច្បាប់ដែលសមាជិក សមាជិកាព្រឹទ្ធសភាម្នាក់ៗបានទទួល និងត្រូវបើកិច្ចប្រជុំផ្ទៃក្នុង ឬប្រជុំអន្តរកម្មការជំនាញដោយមានការចូលរួមបំភ្លឺពីតំណាងក្រសួងពាក់ព័ន្ធ ឬជាម្ចាស់អត្ថបទច្បាប់ដើម្បីពិនិត្យ និងឱ្យយោបល់លម្អិតលើអត្ថបទច្បាប់។[90]

ជាចុងក្រោយរាល់អត្ថបទច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ចប់សព្វគ្រប់រួចហើយ ត្រូវថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់។ ចំពោះច្បាប់រៀបចំអង្គការត្រូវបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យធម្មនុញ្ញភាពមុន បន្ទាប់មកថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់។[91]

#### ខ.២.២.១. គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

បន្ទាប់ពីបានទទួលពិនិត្យសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ពីរដ្ឋាភិបាល ឬបញ្ហាទាំងពួង សមាជិកព្រឹទ្ធសភាផ្តើមកោះប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការពិនិត្យ និងឱ្យយោបល់ទៅលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាទាំងពួងដែលរដ្ឋសភាបញ្ជូនមកឱ្យព្រឹទ្ធសភា។

ព្រឹទ្ធសភាមានគណៈកម្មាធិការអចិន្ត្រៃយ៍មួយ ដែលមានសមាសភាពចំនួន១៣រូបដូចខាងក្រោម៖

- ប្រធានព្រឹទ្ធសភា ជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍
- អនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ជាសមាជិក
- ប្រធានគណៈកម្មការជំនាញទាំង១០នៃព្រឹទ្ធសភាជាសមាជិក។[92]

រាល់ការប្រជុំទាំងឡាយចាត់ទុកថាបានការ លុះត្រាតែមានកូរ៉ុមលើសពីពីរភាគបី(២/៣) នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ហើយការអនុម័តទាំងឡាយត្រូវយកតាមមតិភាគច្រើនពីរភាគបី(២/៣) នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។[93]

#### ខ.២.២.២. គណៈកម្មការជំនាញ

ព្រឹទ្ធសភាមានគណៈកម្មការជំនាញនានាចំនួន១០។ ហើយគណៈកម្មការនីមួយៗមានសមាសភាព៥ រូប រួមមាន៖ ប្រធាន១ រូប អនុប្រធាន១ រូប លេខាធិការ១ រូប និងសមាជិកចំនួន២ រូប។ ផ្អែកតាមមាត្រា១១៤ ថ្មី(មួយ)

---

[90] អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា, *ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា* (ភ្នំពេញ៖ ២០០៧), ២៩។

[91] អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា, *ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា* (ភ្នំពេញ៖ ២០០៧), ៣០។

[92] គន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨), ១៩៩។

[93] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ២០០៦, មាត្រា១១១ ថ្មី (ពីរ)។

នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗទៀតដែលចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា។[94]

គណៈកម្មការជំនាញទាំង១០ នៃព្រឹទ្ធសភាព មានដូចតទៅ៖

- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត
- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
- គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន
- គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ
- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
- គណៈកម្មការនីតិកម្ម និងយុត្តិធម៌
- គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍
- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
- គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ។[95]

គណៈកម្មការជំនាញទាំង១០ បំពេញការងាររបស់ខ្លួនស្របទៅតាមតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការនីមួយៗ ដែលបានកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា។ ព្រោះគណៈកម្មការនីមួយៗមានលេខាធិការដ្ឋានអមគណៈកម្មការមួយ ដែលស្ថិតនៅក្នុងនាយកដ្ឋានជំនួយការគណៈកម្មការសម្រាប់ជួយផ្នែករដ្ឋបាល បច្ចេកទេស ទំនាក់ទំនងសាធារណៈ និងជួយសម្រួលការងារផ្នែកថវិកា។ មន្ត្រីបុគ្គលិកបម្រើការងារក្នុងលេខាធិការដ្ឋានអមគណៈកម្មការ គឺជាមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។ ក្រៅពីនេះគណៈកម្មការនីមួយអាចជួលអ្នកជំនាញការឱ្យជួយបំពេញការងារក្នុងគណៈកម្មការបាន។ អ្នកជំនាញការនៅត្រង់នេះពុំមែនជាមន្ត្រីអចិន្ត្រៃយ៍របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឡើយ។ ហើយគណៈកម្មការនីមួយៗមានថវិកាសម្រាប់ទ្រទ្រង់សេវារដ្ឋបាល និងបេសកកម្មផ្ទាល់ប្រចាំខែ។ ថវិកានេះត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍។[96]

[94] ឃុន ណាផ័ត, *សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ផាងពុម្ព ដារ៉ា,២០១៦), ១៧៧។

[95] បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា, ១៨ កក្កដា ២០១២, ប្រការ, ១៥ ថ្មី។

[96] អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា, *ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា* (ភ្នំពេញ៖ ២០០៧), ១៧។

### ២.២.២. ការអនុវត្តអំណាចនីតិប្រតិបត្តិ

អនុលោមតាមមាត្រា១១៨ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រានេះបានបន្តទៀតថា គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីជាសមាជិក។[97]

#### ២.២.២.១. រាជរដ្ឋាភិបាល

ដោយសារតែប្រទេសកម្ពុជាប្រកាន់យករបបគ្រប់គ្រងបែបប្រជាធិតេយ្យសភានិយម ដូច្នេះរាជរដ្ឋាភិបាលកើតចេញពីសភា។ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា តំណាងឱ្យអង្គនីតិប្រតិបត្តិនៃរាជរដ្ឋាភិបាល។ ស្ថាប័ននេះទទួលខុសត្រូវអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ស្របតាមកម្មវិធីនយោបាយដែលអនុម័តយល់ព្រមដោយសភា (រដ្ឋសភា និងព្រឹទ្ធសភា)។ ចំពោះប្រទេសកម្ពុជា ដែលជាប្រទេសប្រកាន់យកនូវរបបនយោបាយបែបសភានិយម ទន្ទឹមនេះអំណាចរដ្ឋបាលថ្នាក់ជាតិ ឬអំណាចនីតិប្រតិបត្តិនេះ ត្រូវបានប្រគល់ទៅឱ្យនាយករដ្ឋមន្ត្រីដែលជាប្រមុខរាជរដ្ឋាភិបាល ហើយនាយករដ្ឋមន្ត្រីមានមុខងារខាងនយោបាយផង និងមុខងាររដ្ឋបាលផង។

**ក. អំពីរាជរដ្ឋាភិបាល**

រាជរដ្ឋាភិបាល ជាអង្គការនីតិប្រតិបត្តិ មានសមត្ថកិច្ចកំណត់ និងអនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ស្របតាមគោលនយោបាយខ្លួន។ ក្នុងនោះមានកាតព្វកិច្ចថ្មីមួយ ដែលមិនមានក្នុងច្បាប់ចាស់ គឺត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ ក្នុងការអនុវត្តភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនខាងលើ ដែលជាការងារស្មុលទាំងអស់នេះបាន រាជរដ្ឋាភិបាលមានសិទ្ធិក្នុងការគ្រប់គ្រង ដឹកនាំបញ្ជា ប្រើប្រាស់រដ្ឋបាលសាធារណៈគ្រប់ថ្នាក់រួមទាំង កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងកងកម្លាំងប្រដាប់អាវុធផ្សេងទៀត ហើយត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋសភា អំពីនយោបាយទូទៅ និងសកម្មភាពរបស់ខ្លួន។[98]

**ខ. អំពីសមាសភាពរាជរដ្ឋាភិបាល**

ដូចបាននិយាយបញ្ជាក់ខាងដើម សមាសភាពនៃរាជរដ្ឋាភិបាលមាន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីជាសមាជិក។ នាយករដ្ឋមន្ត្រី ត្រូវបានជ្រើសរើសចេញពីសមាជិករដ្ឋសភា រីឯសមាសភាពដទៃទៀតនៃរាជរដ្ឋាភិបាលអាចជ្រើសរើសពីក្នុង ឬក្រៅរដ្ឋសភា តែត្រូវជាសមាជិកគណបក្សមានតំណាងក្នុងរដ្ឋសភា។[99] ប៉ុន្តែសមាជិករដ្ឋសភារូបនោះ គ្រាន់តែជាសមាជិករដ្ឋសភាធម្មតា ដោយមិនត្រូវមានមុខតំណែងអ្វីទាំងអស់នៅក្នុងគណៈកម្មការជំនាញទាំង១០ របស់រដ្ឋសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាឡើយ។ សមាជិក

[97] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា៨។

[98] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា ៤,៦,៧។

[99] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា៩។

រាជរដ្ឋាភិបាលទាំងអស់ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយទទួលបានការអនុម័តផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភា តាមបែបបទដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង។[100] នាយករដ្ឋមន្ត្រី និងសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលមានខុទ្ទកាល័យរបស់ខ្លួនមួយ និងមានទីប្រឹក្សា ជំនួយការ និងលេខាធិការ ស្របតាមបញ្ញត្តិច្បាប់ជាធរមាន។ បន្ថែមពីលើនេះទៀត ច្បាប់នេះបានបញ្ចូលនូវបញ្ញត្តិនៃរដ្ឋធម្មនុញ្ញមកបញ្ជាក់ឱ្យបានច្បាស់លាស់តែម្តងថា មុខងារសមាសភាពរាជរដ្ឋាភិបាល មានវិសមិតភាពជាមួយនឹងសកម្មភាពខាងវិជ្ជាជីវៈ ការធ្វើអាជីវកម្មគ្រប់ប្រភេទ ឬការកាន់មុខតំណែងជាថ្នាក់ដឹកនាំ ឬគណៈគ្រប់គ្រង ឬសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុន សហគ្រាស ហើយនឹងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ។[101] ហើយសមាសភាពរាជរដ្ឋាភិបាលទាំងអស់ ត្រូវទទួលខុសត្រូវរៀងៗខ្លួនចំពោះមុខនាយករដ្ឋមន្ត្រី និងចំពោះមុខរដ្ឋសភានូវអំពើដែលខ្លួនបានប្រព្រឹត្ត និងទទួលខុសត្រូវរួមគ្នាចំពោះមុខរដ្ឋសភា អំពីនយោបាយទូទៅ និងសកម្មភាពរបស់រាជរដ្ឋាភិបាល។[102]

បន្ថែមពីលើនេះ ច្បាប់ថ្មីក៏បានរំលេចនូវសមាសភាពមួយចំនួន ដែលមិនមែនជាសមាជិករាជរដ្ឋាភិបាល តែត្រូវផ្តល់តួនាទីក្នុងពេលបង្កើត និងចប់អាណត្តិការងារជាមួយរាជរដ្ឋាភិបាលដូចជា៖ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា និងជំនួយការ។

**២.២.២.២. តួនាទីរបស់នាយករដ្ឋមន្ត្រី**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- នាយករដ្ឋមន្ត្រីជាប្រមុខនៃរាជរដ្ឋាភិបាលមានភារកិច្ចទទួលខុសត្រូវរួមគ្នាជាមួយសមាជិកទាំងឡាយ នៃរាជរដ្ឋាភិបាលចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅ និងអំពីសកម្មភាពរួមរបស់រាជរដ្ឋាភិបាលទាំងមូល។ នាយករដ្ឋមន្ត្រីដឹកនាំការងារ និងចាត់ចែងរាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ។[103]
- នាយករដ្ឋមន្ត្រីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី។ ការប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រីត្រូវសម្រេចដោះស្រាយរាល់ភារកិច្ចទូទៅរបស់រាជរដ្ឋាភិបាល។
- នាយករដ្ឋមន្ត្រី អាចប្រគល់សិទ្ធិជូនសមាជិករាជរដ្ឋាភិបាលណាម្នាក់ កោះប្រជុំ និងធ្វើជាអធិបតីអង្គប្រជុំអន្តរក្រសួង ប៉ុន្តែអង្គប្រជុំនេះគ្មានសិទ្ធិសម្រេចលើការងារតាងនាមរាជរដ្ឋាភិបាលឡើយ។

[100] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ២០២២, មាត្រា១១៩ ថ្មី(ពីរ)។

[101] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា១០។

[102] យូ តូនី, មេរៀននីតិរដ្ឋធម្មនុញ្ញ (២០១៨), ៨៨។

[103] ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ ធាងពុម្ពដារ៉ា,២០១៦), ២២០។

- នាយករដ្ឋមន្ត្រីដឹកនាំចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការ សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងការពារប្រទេស។ នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាលណាម្នាក់ជាអ្នកចរចា និងជាអ្នកចុះហត្ថលេខា។
- នាយករដ្ឋមន្ត្រី ចុះហត្ថលេខាលើអនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា និងសារាចរផ្សេងៗ របស់រាជរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានា ដែលមានអានុភាពទូទៅរបស់រាជរដ្ឋាភិបាល ហើយត្រូវចុះក្នុងរាជកិច្ច។[104]
- នាយករដ្ឋមន្ត្រីមានសិទ្ធិស្នើសុំរដ្ឋសភា ដើម្បីកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ និងលើកសំណើជូនរដ្ឋសភា ដើម្បីត្រួតពិនិត្យ និងអនុម័តលើសេចក្ដីព្រាងច្បាប់។[105]
- នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រតែងតាំង ផ្លាស់ប្ដូរ បញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធាដូចតទៅ៖
  - ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
  - ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី
  - អគ្គលេខាធិការរាជរដ្ឋាភិបាល
  - អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ឬមុខតំណែងប្រហាក់ប្រហែល
  - ប្រតិភូរាជរដ្ឋាភិបាល
  - អភិបាលរាជធានី អភិបាលខេត្ត
  - ឯកអគ្គរាជទូត ឬមុខតំណែងប្រហាក់ប្រហែល
  - ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព
  - អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងនាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទកម្ពុជា
  - អគ្គស្នងការនគរបាលជាតិ។

មុខតំណែង និងក្របខណ្ឌមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិចាប់ពីថ្នាក់ឧត្តមសេនីយ៍ឡើងត្រូវតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រីស្របតាមបទប្បញ្ញត្តិជាធរមាន។[106]

[104] ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា១៨។
[105] ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា១៩។
[106] ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា២៣។

- នាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា មន្ត្រីការទូត (ភារធារី ឬអគ្គកុងស៊ុល) អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលស្រុក ខណ្ឌ ក្រុង ប្រធាននាយដ្ឋានអគ្គនាយករង អគ្គលេខាធិការរងក្រសួង។
- ក្នុងករណីពិសេស ឬប្រធានស័ក្តិនាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជាចំណាយ ក្រៅពីការកំណត់ក្នុងថវិកាជាតិ ដើម្បីដោះស្រាយកិច្ចការចាំបាច់ និងបន្ទាន់រួចរាយការណ៍សុំការអនុម័តពីអង្គការនីតិប្បញ្ញត្តិ ស្របតាមបទប្បញ្ញត្តិជាធរមាន។[107]
- នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ។
- នាយករដ្ឋមន្ត្រី អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់មុនប្រកាសឱ្យប្រើឱ្យទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យជាមុនអំពីធម្មនុញ្ញភាព។
- ក្រោយពីច្បាប់ណាមួយប្រកាសឱ្យប្រើរួចហើយ នាយករដ្ឋមន្ត្រីអាចស្នើក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពីធម្មនុញ្ញភាពនៃច្បាប់នោះបាន (មាត្រា១៤១ថ្មីនៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣)។
- នាយករដ្ឋមន្ត្រីត្រួតពិនិត្យការងារ សកម្មភាព អំពើប្រព្រឹត្ត និងការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល ហើយមានសិទ្ធិដក និងដាក់ជំនួសសមាជិករាជរដ្ឋាភិបាលតាមបែបបទ និងនីតិវិធីជាធរមាន។
- នាយករដ្ឋមន្ត្រីជាសមាជិកក្រុមប្រឹក្សារាជសម្បត្តិ (មាត្រា១៣ ថ្មីនៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣)។
- នាយករដ្ឋមន្ត្រីកោះអញ្ជើញប្រជុំសមាជជាតិ (មាត្រា ១៤៨ ថ្មីនៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣)។
- នាយករដ្ឋមន្ត្រីដឹកនាំគណៈរដ្ឋមន្ត្រីដើម្បីចូលគាល់ និងរាយការណ៍សភាពការណ៍ប្រទេសជាតិថ្វាយព្រះមហាក្សត្រពីរដងក្នុងមួយខែ (មាត្រា២០ថ្មីនៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣)។
- នាយករដ្ឋមន្ត្រីដឹកនាំការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

សរុបសេចក្តីមក នាយករដ្ឋមន្ត្រីមានសមត្ថកិច្ចរួមមាន៖

**ចេញបទបញ្ជាទូទៅនៃនីតិរួម៖** មានន័យថាជាសេចក្តីសម្រេចមួយដែលបញ្ញត្តិចេញនូវវិធានទូទៅ និងមិនចំពោះទាក់ទងគ្រប់វិស័យទាំងអស់ ហើយមានវិសាលភាពអនុវត្តគ្របដណ្តប់លើដែនដីជាតិទាំងមូល។[108] បើយោងតាមព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ បានចែងថា រាជរដ្ឋាភិបាលធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋលើកលែងតែកិច្ចការអ្វីដែលជាសមត្ថកិច្ចរបស់អង្គការនីតិប្បញ្ញត្តិ និងអង្គការតុលាការ។[109] ឃ្លានេះអាចឱ្យយល់បានថា នាយករដ្ឋមន្ត្រីមានសិទ្ធិចេញបទបញ្ជាអនុវត្តច្បាប់ ហើយនឹងបទបញ្ជាផ្សេងទៀត ដែលទាក់ទងនឹងកិច្ចការទូទៅរបស់រដ្ឋដែលពុំមែនជាកិច្ចការក្នុងសមត្ថកិច្ចរបស់

---

[107] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា២៩។
[108] ហៀង សាង, *នីតិរដ្ឋបាលទូទៅ* (២០២១), ២៨។
[109] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា៤។

រដ្ឋសភា ព្រឹទ្ធសភា និងតុលាការ។ ចំពោះបទបញ្ញាអនុវត្តច្បាប់ គឺវាអាស្រ័យលើច្បាប់សភាកំណត់ទុកឱ្យជាមុនថាត្រូវធ្វើតាមរយៈព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬសេចក្តីសម្រេច។

**ឧទាហរណ៍៖** ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ បានចែងថា ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងចាប់ពីថ្នាក់នាយកដ្ឋានឡើងត្រូវកំណត់ដោយអនុក្រឹត្យ។[110]

**ចេញសេចក្តីសម្រេចឯកត្តភូត៖** គឺជាលិខិតដែលមានគោលដៅធ្វើឱ្យមានប្រយោជន៍ ឬធ្វើឱ្យខូចប្រយោជន៍របស់បុគ្គលណាម្នាក់ជាកំណត់។ គេបានដឹងហើយថា សេចក្តីសម្រេចឯកត្តភូតអាចធ្វើឡើងតាមរយៈទម្រង់ព្រះរាជក្រឹត្យ។ ដូចគ្នាដែរ យើងឃើញថា សេចក្តីសម្រេចឯកត្តភូតក៏អាចធ្វើឡើងតាមរយៈទម្រង់ជាអនុក្រឹត្យដែលគេហៅថាអនុក្រឹត្យឯកត្តភូត។ បើយោងតាមព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ បានចែងថា៖ នាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិដែលមិនមានចែងក្នុងមាត្រា២៣ លើកលែងតែមន្ត្រីដែលមានចែងក្នុងកថាខណ្ឌទី១ មាត្រា៤៦ នៃច្បាប់នេះ។[111] មាត្រា៤៦ កថាខណ្ឌទី១ ចែងថា រដ្ឋមន្ត្រីមានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានចាប់ពីប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ និងថ្នាក់វរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ។ យោងតាមមាត្រា២៤ និង៤៦ ខាងលើនេះបានបង្ហាញថា នាយករដ្ឋមន្ត្រីមានសិទ្ធិចេញអនុក្រឹត្យតែងតាំង អនុក្រឹត្យផ្លាស់ប្តូរ និងអនុក្រឹត្យបញ្ចប់ភារកិច្ច ចំពោះមន្ត្រីរាជការជាន់ខ្ពស់ស៊ីវិល ដែលមិនត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ អនុក្រឹត្យទាំងនោះជាអនុក្រឹត្យឯកត្តភូត អនុក្រឹត្យឯកត្តភូតក៏មានចេញចំពោះបុគ្គលចំឈ្មោះផ្សេងទៀតក្រៅពីពួកមន្ត្រីរាជការដូចជា៖ ការជូនមេដាយប្រភេទចម្រុះ ដល់សប្បុរសជនដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនក្នុងវិស័យស្ថាបនាជាតិ។[112]

**ចេញបទបញ្ជានគរបាល** គឺជាវិធានដែលកាត់បន្ថយនូវសេរីភាពសាធារណៈ ក្នុងគោលបំណងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ហើយមានអានុភាពអនុវត្តលើផ្ទៃប្រទេសទាំងមូល។

ឧទាហរណ៍៖ អនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

### ២.២.៣. ការអនុវត្តអំណាចតុលាការ

ស្ថាប័នតុលាការ គឺជាស្ថាប័នមួយដ៏សំខាន់របស់រដ្ឋ ដែលទាមទារឱ្យមានជាចាំបាច់ និងមិនអាចខ្វះបាននោះទេ។ ស្ថាប័នតុលាការជំនុំជម្រះរឿងក្តីដោយអនុវត្តទៅតាមផ្លូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានរបស់រដ្ឋ។ អំណាចនៃការជម្រះក្តី គឺបានមកពីរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ដែលបានផ្តល់អំណាចឱ្យស្ថាប័នតុលាការតាមស្មារតីមាត្រា៥១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ដោយបានបែងចែកអំណាចដាច់ពីគ្នារវាងអំណាចនីតិបញ្ញត្តិ

[110] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា៣៩ កថាខណ្ឌទី៣។

[111] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨ មាត្រា២៤។

[112] មាត្រា១ នៃព្រះរាជក្រឹត្យលេខជស/រកត/១០៩៥/០១, ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥។

អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។[113] អំណាចតុលាការជាអំណាចឯករាជ្យមានន័យថា តុលារការមិនស្ថិតនៅក្រោមឥទ្ធិពល និងការបង្គាប់បញ្ជាពីអំណាចនីតិបញ្ញត្តិ(រដ្ឋសភា និងព្រឹទ្ធសភា) និងអំណាចនីតិប្រតិបត្តិ (រាជរដ្ឋាភិបាល) ឬអំណាចណាមួយរបស់រដ្ឋឡើយ ហើយអំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។[114]

**២.២.៣.១. រចនាសម្ព័ន្ធរបស់តុលាការ**

ច្បាប់ស្តីពីការរៀបចំអង្គការតុលាការថ្មីសព្វថ្ងៃតុលាការប្រទេសកម្ពុជាមានពីរ (០២) ថ្នាក់ គឺសាលាជម្រះក្តីជាន់ទាប និងសាលាជម្រះក្តីជាន់ខ្ពស់ ដែលមានសមត្ថកិច្ចសម្រាប់ដោះស្រាយរឿងក្តីទាំងអស់រួមនឹងរឿងក្តីរដ្ឋបាលផង។ ច្បាប់ថ្មីនេះបានបង្កើតឱ្យមានតុលាការចាត់តាំង ឬហៅថា យុត្តាធិការចាត់តាំង (Juridiction d'attribution) ដែលជាយុត្តាធិការជំនាញ (Juridiction specialisee) ដែលមានដូចជាៈ

- តុលាការរដ្ឋប្បវេណី
- តុលាការព្រហ្មទណ្ឌ
- តុលាការពាណិជ្ជកម្ម
- តុលាការការងារ។

យោងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការថ្មីនេះ បានប្រគល់អំណោចឱ្យតុលាការរដ្ឋប្បវេណីជាអ្នកមានសមត្ថកិច្ចដោះស្រាយរឿងក្តីរដ្ឋបាល ប៉ុន្តែនៅប្រទេសកម្ពុជាយើងសព្វថ្ងៃមិនទាន់បង្កើតតុលាការរដ្ឋបាលដាច់ចេញពីតុលាការធម្មតានេះទេ ហើយនីតិវិធីរដ្ឋប្បវេណីអាចយកមកអនុវត្តសម្រាប់វិវាទរដ្ឋបាលផងដែរ។ ដូច្នេះ គេមិនអាចនិយាយថា ប្រទេសកម្ពុជានៅមិនទាន់មានតុលាការរដ្ឋបាលបានទេ ពីព្រោះ "តុលាការរដ្ឋប្បវេណីដើរតួជាតុលាការរដ្ឋបាល" ផងដែរ។ ការបង្កើតឱ្យមានតុលាការជំនាញដាច់ដោយឡែកពីគ្នាបែបនេះ ធ្វើឱ្យចៅក្រមងាយស្រួលស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ពីព្រោះចៅក្រមមានជំនាញដោយឡែកៗពីគ្នា ហើយចៅក្រមនីមួយៗមិនអាចចេះច្បាប់អស់នោះទេ។ ប៉ុន្តែមិនពិបាកនោះទេ ដោយសារតែរដ្ឋសភាបានធ្វើច្បាប់គ្រប់សព្វអស់ទាំង ដូច្នេះក្រុមចៅក្រមប្រៀបដូចជា ស្មៀនដែលចាំតែបើកមាត្រាច្បាប់មើល និងសម្រេចសេចក្តីតាមច្បាប់ដែលបានចែង ឬរដ្ឋសភាបានគិតគូរហើយជាស្រេចតែប៉ុណ្ណោះ។[115]

[113] កៅ មុយថង, *នីតិរដ្ឋធម្មនុញ្ញ* (២០០៦), ៣៥៩។

[114] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, ១២៨ ថ្មី(មាត្រា១០៩ ចាស់) ។

[115] ឥន យឿន, *វិវាទរដ្ឋបាល* (២០១៦), ៦, ៧។

### ក. តុលាការជាន់ទាប

នៅព្រះរាជាណាចក្រកម្ពុជា តុលាការជាន់ទាបនេះទទួលដោះស្រាយរឿងក្ដីដំបូងគេបំផុត។ សាលាដំបូងនេះមានតុលាការពីរ (០២) ប្រភេទទៀត គឺតុលាការរាជធានី ខេត្ត (ក.១) និងតុលាការយោធា (ក.២) ។ ដោយឡែកតុលាការយោធាមានសមត្ថកិច្ចលើកងទ័ពទូទាំងប្រទេស និងចំពោះតែបទល្មើសយោធាប៉ុណ្ណោះ។[116]

#### ក.១. តុលាការរាជធានី ខេត្ត

តុលាការរាជធានី ខេត្ត មានសមត្ថកិច្ចដែនដីលាតសន្ធឹងលើទឹកដីនៃរាជធានី ខេត្ត ដែលខ្លួនតាំងនៅ។ តាមគោលការណ៍ តុលាការរាជធានី ខេត្ត ត្រូវចែកចេញជាតុលាការព្រហ្មទណ្ឌ តុលាការរដ្ឋប្បវេណី តុលាការពាណិជ្ជកម្ម និងតុលាការការងារ។[117] ប៉ុន្តែតាមការអនុវត្តជាក់ស្តែងដោយមិនទាន់មានចៅក្រមគ្រប់ចំនួន ដូច្នេះហើយការបែងចែកនៅមិនទាន់អាចធ្វើបានទេចៅក្រមនីមួយៗ អាចដោះស្រាយរឿងរដ្ឋប្បវេណីក៏បានដោះស្រាយរឿងព្រហ្មទណ្ឌក៏បាន។

**ផ្នែករដ្ឋប្បវេណី** មានក្រឡាបញ្ជី និងមន្ត្រីអនុវត្តសាលក្រម (ដែលចាត់តាំងឡើងទៅតាមករណីដែលមានសាលក្រមអនុវត្ត)។ ចៅក្រមមានភារកិច្ចធ្វើការផ្សះផ្សាស៊ើបអង្កេត និងជំនុំជម្រះក្ដីរឿងរដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ និងចៅក្រមមានភារកិច្ចធ្វើការកត់ត្រាកំណត់ហេតុនានា និងទុកដាក់សំណុំរឿងធ្វើសេវាកម្មខាងប្រគល់ដីកា និងសំបុត្រស្នាមផ្សេងៗ។ មន្ត្រីអនុវត្តសាលក្រមមិនមានអាទិភាពជាអចិន្ត្រៃយ៍ទេតែគេអាចចាត់តាំងអ្នកណាម្នាក់ឱ្យបំពេញតួនាទីនេះតាមករណីដែលត្រូវអនុវត្តសាលក្រម។ មន្ត្រីអនុវត្តសាលក្រមអាចជាចៅក្រម ឬក្រឡាបញ្ជីបំពេញការងារក្រោមការទទួលខុសត្រូវរបស់ចៅក្រម ដែលចាត់តាំងឱ្យអនុវត្តដោយប្រធាន តុលាការ។

**ផ្នែកព្រហ្មទណ្ឌ** មានចៅក្រម ក្រឡាបញ្ជី។ ចៅក្រមមានភារកិច្ចធ្វើការស៊ើបអង្កេតតាមសេចក្ដីសន្និដ្ឋានស្នើឱ្យស៊ើបអង្កេតរបស់អយ្យការ និងធ្វើការជំនុំជម្រះរឿងព្រហ្មទណ្ឌនៅរឿងទាំងឡាយដែលខ្លួនពុំបានធ្វើការស៊ើបអង្កេត។ ការបំពេញតួនាទីស៊ើបអង្កេតគេហៅថា "ចៅក្រមស៊ើបអង្កេត" កាលណាបំពេញតួនាទីក្នុងការជំនុំជម្រះគេហៅថា "ចៅក្រមជំនុំជម្រះ" ក្រឡាបញ្ជីមានតួនាទីជាអ្នកជំនួយចៅក្រមនៅក្នុងការកត់ត្រាកំណត់ហេតុនានារៀបចំទុកដាក់ឯកសារ និងសេវាកម្មប្រគល់ដីកា និងលិខិតស្នាមផ្សេងៗ។ តុលាការពាណិជ្ជកម្មនៃសាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីពាណិជ្ជកម្ម ដោយរួមទាំងរឿងក្ដីក្ស័យធនក្នុងរឿងពាណិជ្ជកម្ម ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីពាណិជ្ជកម្ម[118] តុលាការការងារនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះលើរឿងក្ដីការងារដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីការងារ។[119]

---

[116] ឈុន ណាវ៉េត, *សេចក្ដីផ្ដើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ រោងពុម្ពដារ៉ា,២០១៦), ៣០៤, ៣០៥។

[117] សឿន សោភ័ណ និងសាឡេះ សុវណ្ណារ៉ា, *នីតិរដ្ឋបាលទូទៅ* (២០២១), ៧១។

[118] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤ មាត្រា២២។

[119] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤ មាត្រា២៥។

**គ.២. តុលាការយោធា**

តុលាការយោធាមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញតែមួយគត់ ជាប្រភេទតុលាការជាន់ទាបដែលមានសមត្ថកិច្ច ជំនុំជម្រះរឿងក្តីដែលទាក់ទងទៅនឹងបទល្មើសយោធា ឬបទល្មើសប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់កងកម្លាំងប្រដាប់អាវុធដែលប្រព្រឹត្តដោយសមាជិកយោធិន។ យោធិននៃកងយោធពលខេមរភូមិន្ទ ត្រូវបានរាប់បញ្ចូលដូចជា យោធិនអាជីព យោធិនជាប់កិច្ចសន្យា កងរាជអាវុធហត្ថ ពលរដ្ឋដែលជាប់កាតព្វកិច្ចយោធិន និងយោធិនបម្រុង លើកលែងតែមន្ត្រីនគរបាលជាតិ។[120] ចំពោះយោធាដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌសាមញ្ញត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការរាជធានី ខេត្ត។ រាល់សកម្មភាពទាំងអស់ដែលប្រព្រឹត្តដោយតុលាការយោធាត្រូវរាយការណ៍ទៅក្រសួងការពារជាតិដូចជាស្ថិតិនៃការស៊ើបអង្កេត និងការជំនុំជម្រះជាដើម។ ស្ថាប័នអយ្យការយោធាដែលអមតុលាការយោធាក៏ស្ថិតនៅក្រោមក្រសួងការពារជាតិផងដែរ។

**ខ. តុលាការជាន់ខ្ពស់**

**ខ.១. សាលាឧទ្ធរណ៍**

សាលាឧទ្ធរណ៍ ត្រូវបានគេចាត់ទុកថាជាសាលាជម្រះក្តីជាន់ខ្ពស់ដែលមាននៅរាជធានីភ្នំពេញ និងចំនួនបី (០៣) ទៀតមានលក្ខណៈជាតំបន់គឺ សាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំ សាលាឧទ្ធរណ៍ខេត្តព្រះសីហនុ និងសាលាឧទ្ធរណ៍ខេត្តបាត់ដំបង។ ការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់នីមួយៗ និងការកំណត់ពីសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។[121]

សាលាឧទ្ធរណ៍មានសមត្ថកិច្ច ជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយណាដែលប្រគល់សមត្ថកិច្ចទៅឱ្យតុលាការផ្សេងទៀត។ សាលាឧទ្ធរណ៍សម្រេចសេចក្តីទាំងអង្គហេតុ និងអង្គច្បាប់លើរឿងក្តី ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។[122] ក្នុងរឿងក្តីព្រហ្មទណ្ឌក៏ដូចជារឿងក្តីឯទៀត ដែលសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបណ្តឹងឧទ្ធរណ៍ដែលប្តឹងមិនសុខចិត្ត និងសេចក្តីសម្រេចទាំងឡាយរបស់តុលាការរាជធានី ខេត្ត តុលាការយោធា ព្រមទាំងសេចក្តីសម្រេចទាំងឡាយរបស់អយ្យការអមតុលាការថ្នាក់ក្រោមទាំងអស់។ ប្រធានមានតួនាទីធ្វើយ៉ាងណា ដើម្បីធានាឱ្យតុលាការប្រព្រឹត្តទៅបានល្អ។ ក្រុមប្រឹក្សាជំនុំជម្រះមានចៅក្រមបី (០៣) រូបក្នុងនោះមានប្រធានមួយរូប និងពីរ (០២) រូបទៀតជាចៅក្រមប្រឹក្សា។ ការជំនុំជម្រះត្រូវធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជម្រះចូលរួមដោយតំណាងមហាអយ្យការមួយរូប ក្រឡាបញ្ជីមួយរូប និងជំនួយការក្រឡាបញ្ជីមួយរូប។ ជាគោលការណ៍សាលាឧទ្ធរណ៍បែងចែកជាផ្នែកដូចនឹងតុលាការកំពូលផងដែរគឺមានផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ ផ្នែកពាណិជ្ជកម្ម និងផ្នែកការងារ។

---

[120] ឥន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨), ៦៧។

[121] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤ មាត្រា៣៥។

[122] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤ មាត្រា៤២។

ក្រៅពីជំនុំជម្រះលើកទីពីរនូវរឿងក្តីព្រហ្មទណ្ឌទាំងឡាយរបស់តុលាការជាន់ទាប សាលាឧទ្ធរណ៍មានសមត្ថកិច្ចផងដែរក្នុងការបើកសវនាការជំនុំជម្រះលើសេចក្តីសម្រេចនានាមួយចំនួនទៀតដូចជា៖

- ជំនុំជម្រះលើសេចក្តីសម្រេចអំពីបណ្តឹងទាស់ ដែលភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកមិនចាត់ការរបស់ព្រះរាជអាជ្ញាអមតុលាការជាន់ទាប។
- ជំនុំជម្រះលើសេចក្តីសម្រេចអំពីបណ្តឹងទាស់សេចក្តីសម្រេចឃុំខ្លួនរបស់ចៅក្រមស៊ើបអង្កេតនៃតុលាការជាន់ទាប។
- ជំនុំជម្រះលើសេចក្តីសម្រេចអំពីការលើកលែងការចោទប្រកាន់ជនល្មើសរបស់ចៅក្រមស៊ើបអង្កេត នៃតុលាការជាន់ទាប ដោយសាលាឧទ្ធរណ៍ត្រូវសម្រេចរឿងនេះក្នុងរយៈពេល១៥ ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលបណ្តឹងឧទ្ធរណ៍។[123]
- ជំនុំជម្រះលើសេចក្តីសម្រេចអំពីការកែប្រែបទល្មើស និងបណ្តឹងតវ៉ាអំពីសមត្ថកិច្ចតុលាការជាន់ទាប និងវិវាទសមត្ថកិច្ចរវាងតុលាការជាន់ទាបទាំងឡាយ។

**ខ.២ តុលាការកំពូល**

តុលាការកំពូលជាស្ថាប័នជំនុំជម្រះក្តីខ្ពស់បំផុត ហើយមានសមត្ថកិច្ចគ្របដណ្តប់លើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជាមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខអំពីសាលដីការបស់សាលាឧទ្ធរណ៍។[124] តុលាការកំពូលមានសភាជំនាញដូចជា៖ សភាព្រហ្មទណ្ឌ សភារដ្ឋប្បវេណី សភាពាណិជ្ជកម្ម និងសភាការងារ។ ក្នុងករណីចាំបាច់ សភាជំនាញផ្សេងៗទៀតរបស់តុលាការកំពូល អាចត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ហើយសភានីមួយៗចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងនាមតុលាការកំពូល។[125]

តុលាការកំពូល មានសមត្ថកិច្ចដោះស្រាយរឿងក្តី ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់របស់ច្បាប់។[126] សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់អនុវត្តអំណាចតុលាការ ដែលគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង មានន័យថា តុលាការកំពូលត្រូវប្រើប្រាស់សិទ្ធិអំណាចដែលច្បាប់ប្រគល់ជូនដើម្បីដោះស្រាយរឿងក្តីទាំងអស់ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់កំណត់ ដើម្បីស្វែងរកយុត្តិធម៌ជូនភាគីនីមួយៗនៃរឿងក្តី។ ក្នុងរឿងក្តីព្រហ្មទណ្ឌ តុលាការកំពូលមានសមត្ថកិច្ចលើបណ្តឹងសាទុក្ខចំពោះសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ បានសេចក្តីថា

[123] ឈុន ណាវ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ រោងពុម្ពដារ៉ា,២០១៦),ទំព័រទី៣២០។

[124] ឈុន ណាវ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ រោងពុម្ពដារ៉ា,២០១៦),ទំព័រទី៣២៩។

[125] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤ មាត្រា៤៧។

[126] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤ មាត្រា៦១។

ប្រសិនបើនៅពេលគូភាគីនៃរឿងក្តីមិនយល់ស្រប ឬមិនពេញចិត្តទៅនឹងសាលដីកាណាមួយរបស់សាលាឧទ្ធរណ៍ទេនោះ គូភាគីនៃរឿងក្តីនេះអាចធ្វើការប្តឹងសាទុក្ខមកតុលាការកំពូលបានតាមរយៈការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានចេញសេចក្តីសម្រេច។[127] ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលជាអ្នកចេញសាលដីកានោះគឺជាអ្នកមានសិទ្ធិពិនិត្យ និងទទួលពាក្យបណ្តឹងសាទុក្ខ ដោយពិនិត្យមើលលើទម្រង់នៃពាក្យបណ្តឹងដើម្បីធានាបាននូវភាពត្រឹមត្រូវនៃពាក្យបណ្តឹងនោះ។ បណ្តឹងសាទុក្ខត្រូវតែមានហត្ថលេខារបស់ក្រឡាបញ្ជី និងអ្នកប្តឹង ឬអ្នកតំណាងដោយត្រូវមានភ្ជាប់ជាមួយលិខិតប្រគល់សិទ្ធិផងដែរ ហើយក្រឡាបញ្ជីនៃតុលាការនោះត្រូវចុះក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនោះ។ ក្រោយពីទទួលបាន បណ្តឹងសាទុក្ខ ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ត្រូវរៀបចំសំណុំរឿង និងបញ្ជូនទៅការិយាល័យក្រឡាបញ្ជីនៃតុលាការកំពូលក្នុងរយៈពេលយ៉ាងខ្លីបំផុត ដើម្បីក្រឡាបញ្ជីនៃតុលាការកំពូលធ្វើការចុះបញ្ជី ហើយអនុវត្តតាមនីតិវិធីច្បាប់ដែលមានជាធរមានរហូតដល់ពេលជំនុំជម្រះ។[128] ចំពោះបណ្តឹងសាទុក្ខនេះដែរ តុលាការកំពូលសម្រេចសេចក្តីដោយចៅក្រមប្រាំ(០៥) រូប ក្នុងនេះមានប្រធានក្រុមប្រឹក្សាមួយ(០១) រូប ហើយសេចក្តីសម្រេចរបស់តុលាការកំពូលជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

តុលាការកំពូលត្រូវសម្រេចសេចក្តីលើបញ្ហាច្បាប់ដែលលើកឡើងដោយអ្នកប្តឹងសាទុក្ខ និងដែលរៀបរាប់នៅក្នុងសារណា មានន័យថា តុលាការកំពូលដោះស្រាយ ស៊ើបអង្កេត ស្រាវជ្រាវ ជំនុំជម្រះ និងសម្រេចសេចក្តីតែលើអង្គច្បាប់តែប៉ុណ្ណោះ មិនស៊ើបអង្កេត ឬស្រាវជ្រាវលើអង្គហេតុនោះទេ។ បើតុលាការកំពូលយល់ឃើញថា សាលដីការបស់សាលាឧទ្ធរណ៍ពិតជាត្រឹមត្រូវនោះ តុលាការកំពូលអាចបដិសេធបណ្តឹងសាទុក្ខហើយតម្កល់សាលដីកានោះទុកជាបានការ។ ប៉ុន្តែ បើតុលាការកំពូលយល់ឃើញថា បណ្តឹងសាទុក្ខនោះត្រឹមត្រូវ មានន័យថា តុលាការកំពូលបដិសេធសាលដីកាដែលគេតវ៉ា នោះតុលាការកំពូលត្រូវបញ្ជូនសំណុំរឿងនោះទៅសាលាឧទ្ធរណ៍មួយផ្សេងទៀត ឬសាលាឧទ្ធរណ៍ដដែល ប៉ុន្តែការកាត់សេចក្តី ឬសម្រេចសេចក្តីដោយចៅក្រមថ្មីផ្សេងពីសមាសភាពចៅក្រមមុន។ រីឯបណ្តឹងសាទុក្ខលើកទី២ និងបណ្តឹងសើរើក៏ជាសមត្ថកិច្ចរបស់តុលាការកំពូលផងដែរ គឺសភាពេញអង្គនៃតុលាការនេះជាអ្នកមានសមត្ថកិច្ចលើបណ្តឹងទាំងពីរនេះ។ គួរបញ្ជាក់ផងដែរថា សភាពេញអង្គនៃតុលាការកំពូលត្រូវមានចៅក្រមយ៉ាងតិច០៩រូប ហើយមាន០១រូប ជាប្រធានដែលដឹកនាំផ្ទាល់ដោយប្រធានតុលាការកំពូល។[129]

[127] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤២២។

[128] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤២៣,៤២៤។

[129] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៣៩,កថាខណ្ឌទី១ និងទី៤។

### ២.២.៣.២. លក្ខណសម្បត្តិរបស់ចៅក្រម

ជំនាញវិជ្ជាជីវៈរបស់ចៅក្រមជាជំនាញមួយដែលត្រូវបានកំណត់ និងធានារ៉ាប់រង។ ជំនាញវិជ្ជាជីវៈចៅក្រមមិនអាចត្រូវបានគេដកហូតពីការងារទេ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់ពិន័យចៅក្រមដែលប្រព្រឹត្តខុស។[130] ដោយអំណាចតុលាការជាអំណាចមួយឯករាជ្យ អំណាចតុលាការត្រូវធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងគ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការនេះឡើយ។ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ឱ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។[131]

ដោយសារចៅក្រមជាអ្នកជម្រះក្តី ដូចនេះដើម្បីឱ្យការសម្រេចសេចក្តីរបស់ចៅក្រមប្រកបទៅដោយយុត្តិធម៌នោះ ចៅក្រមត្រូវមានលក្ខណសម្បត្តិដូចតទៅ៖

#### ក. ត្រូវមានភាពម្ចាស់ការក្នុងការកាត់ក្តី

វាជាបញ្ហាមួយដ៏សំខាន់នៅក្នុងការជម្រះក្តីដោយចៅក្រម ត្រូវមានទំនុកចិត្តលើខ្លួនឯងដោយឈរលើការយល់ឃើញនូវភាពត្រឹមត្រូវ ក្រោយពីធ្វើការពិចារណាថ្លឹងថ្លែងយ៉ាងល្អិតល្អន់របស់ខ្លួនដោយផ្អែកលើភស្តុតាងដែលមាន និងច្បាប់ដែលមានចែងជាធរមាន។ ការសម្រេចសេចក្តីរបស់ខ្លួនមិនចាំបាច់មានការសួរយោបល់ពីសំណាក់បុគ្គលណាមួយឡើយ មិនថាអ្នកនោះមានឋានៈជាអ្វីក៏ដោយ ដោយខ្លួនត្រូវឈរលើឧត្តមគតិ ឈរលើភាពពិតប្រាកដដែលបានកើតឡើង ហើយសង្ឃឹមយ៉ាងមុតមាំថា ការសម្រេចសេចក្តីរបស់ខ្លួនពិតជាប្រកបទៅដោយភាពពិតប្រាកដ។

#### ខ. ត្រូវតែមានភាពយុត្តិធម៌មិនលំអៀង

បានសេចក្តីថា ដើម្បីឱ្យមានភាពយុត្តិធម៌នោះ ចៅក្រមមិនត្រូវមានភាពលំអៀងទៅលើភាគីណាមួយឡើយ ដោយខ្លួនត្រូវឈរលើជំហរអព្យាក្រឹត្យ និងសច្ចភាពជានិច្ចមិនថាភាគីទាំងនោះជាគ្រួសារសាច់ញាតិ មិត្តភក្តិ អ្នកស្គាល់គ្នា ឬអ្នកដែលមានការឈ្លោះប្រកែកជាមួយគ្នាក៏ដោយ ក៏ចៅក្រមមិនត្រូវយកគំនុំផ្ទាល់ខ្លួនធ្វើជាមូលដ្ឋាននៃការសម្រេចរបស់ខ្លួនដែរ ពោលគឺចៅក្រមត្រូវកំណត់នូវគោលដៅតែមួយគត់របស់ខ្លួន គឺយកភាពយុត្តិធម៌ជូនទៅដល់ភាគីទាំងនោះឱ្យបានសមស្រប។

#### គ. មិនស្ថិតក្រោមឥទ្ធិពលនៃមជ្ឈដ្ឋានដទៃ

ដោយហេតុអំណាចតុលាការជាអំណាចមួយឯករាជ្យ មានតែចៅក្រមដែលមានសិទ្ធិជម្រះក្តីនោះ ដូច្នេះដោយយោងទៅលើអំណាចឯករាជ្យនេះ ចៅក្រមមិនត្រូវបានធ្វើការគាបសង្កត់បង្ខិតបង្ខំ គំរាមកំហែងពីសំណាក់ភាគី ឬក្រុមណាមួយ អង្គការ ឬស្ថាប័នណាមួយ ដើម្បីធ្វើការសម្រេចសេចក្តីនោះឡើយ ចៅក្រមត្រូវសម្រេចទៅតាមច្បាប់

[130] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា១៣៣ ថ្មី(មាត្រា១១៤ ចាស់)។

[131] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា១២៨ ថ្មី(មាត្រា១០៩ ចាស់), ១២៩ ថ្មី(មាត្រា១១០ ចាស់), ១៣០ ថ្មី(មាត្រា១១១ ចាស់)។

និងតាមការយល់ឃើញរបស់ខ្លួន ដើម្បីជៀសវាងកុំឱ្យគេចោទប្រកាន់ថា គាត់កាត់ក្តីដោយលំអៀងលើភាគីម្ខាងៗ ឬស្ថិតនៅក្នុងក្រុមនេះ ឬក្រុមនោះ និងដើម្បីកុំឱ្យប៉ះពាល់ដល់ភាពឥតលំអៀងរបស់គាត់ ។

**ឃ. ត្រូវជៀសវាងឱ្យផុតនូវអនាគតិទាំងបួន**

ដើម្បីធានាភាពយុត្តិធម៌មិនលំអៀង ចៅក្រមត្រូវជៀសវាងឱ្យផុតនូវអនាគតិទាំងបួន(០៤) រួមមាន៖

- ឆន្ទាគតិ : ការលំអៀងទៅតាមមនោសញ្ចេតនា ការស្រលាញ់ចូលចិត្ត ឬស្អប់
- ទោសាគតិ : លំអៀងដោយការខឹងសម្បារ ឬក្រេវក្រោធ
- មោសាគតិ : លំអៀងដោយភាពមិនចេះដឹង
- ភយាគតិ : លំអៀងដោយភាពភ័យខ្លាច។

**ង. ប្រកាន់ខ្ជាប់នូវសីលធម៌ និងគុណធម៌**

ដោយហេតុថា ចៅក្រមត្រូវសម្រេចថា តើត្រូវដាក់ទោស ឬមិនត្រូវដាក់ទោសទៅលើជនល្មើសណាមួយនោះ ដូច្នេះដើម្បីឱ្យការសម្រេចសេចក្តីរបស់ចៅក្រមមាននូវការគោរព កោតខ្លាចពីសំណាក់អ្នកទាំងអស់ នោះចៅក្រមត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ បានសេចក្តីថា ចៅក្រមត្រូវចេះគោរពមនុស្សដែលមានវ័យចំណាស់ជាងខ្លួន ត្រូវចេះនិយាយស្តីដោយក្តីគោរព ទោះបីអ្នកទាំងនោះមានចំណេះដឹងទាបជាងខ្លួនក៏ដោយ ចៅក្រមមិនត្រូវប្រកាន់យកនូវគំនិតមួយថាមានតែខ្លួនដែលខ្លាំងពូកែជាងគេ មានអំណាចលើគេ ចង់ឱ្យស្លាប់គឺស្លាប់ ចង់ឱ្យរស់គឺរស់ ចង់ឱ្យជាប់គុកគឺត្រូវតែជាប់គុកនោះឡើយ។ មិនតែប៉ុណ្ណោះ ផ្នែកគុណធម៌ក៏ចៅក្រមត្រូវតែមានផងដែរ ត្រូវគោរពស្រលាញ់អាណិតអាសូរដល់អ្នកមានភាពស្អាតស្អំ ស្លូតបូត មានចិត្តបរិសុទ្ធ។[132]

---

[132] ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ ធាងពុម្ពដារ៉ា,២០១៦), ៣៥១។

# ជំពូកទី៣

# ការត្រួតពិនិត្យនៃការអនុវត្តអំណាច

# ជំពូកទី៣
# ការត្រួតពិនិត្យនៃការអនុវត្តអំណាច

## ៣.១. ការត្រួតពិនិត្យដោយសភា

ការត្រួតពិនិត្យទៅលើស្ថាប័ននីតិប្រតិបត្តិនេះបានផ្តល់ទៅឱ្យរដ្ឋសភា និងព្រឹទ្ធសភា ដែលមានតួនាទីក្នុងការតាមដានការអនុវត្តច្បាប់ គោលនយោបាយ និងការអនុវត្តការងារផ្សេងៗរបស់រាជរដ្ឋាភិបាល។

### ៣.១.១. រដ្ឋសភា

តាមរយៈមុខងារទី៣របស់រដ្ឋសភារួមមាន៖ ត្រួតពិនិត្យមើលទៅលើការអនុវត្តច្បាប់ ដំណើរការការងាររបស់រាជរដ្ឋាភិបាល ដើម្បីធានាថាត្រូវបានអនុវត្តដោយត្រឹមត្រូវ មានប្រសិទ្ធភាព និងផ្តល់ផលប្រយោជន៍ទៅដល់ប្រជាជនច្រើនបំផុត។

#### ៣.១.១.១. ការត្រួតពិនិត្យលើការបង្កើតច្បាប់

ដូចដែលយើងដឹងរួចមកហើយថា ច្បាប់មានប្រភពចេញពីសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់។ នីតិវិធីក្នុងការតាក់តែងច្បាប់ចាប់ផ្តើមឡើងដោយសេចក្តីព្រាងច្បាប់ដែលជាគំនិតផ្តួចផ្តើមរបស់នាយករដ្ឋមន្ត្រី និងសេចក្តីស្នើច្បាប់ដែលជាគំនិតផ្តួចផ្តើមរបស់អង្គការនីតិបញ្ញត្តិពោលគឺ គំនិតផ្តួចផ្តើមរបស់តំណាងរាស្ត្រ (១/១០) ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគដប់ (១/៤)។[133]

នៅពេលដែលគំនិតផ្តួចផ្តើមធ្វើច្បាប់ជាសេចក្តីព្រាងច្បាប់ដែលកើតចេញពីអង្គភាពជំនាញរបស់ក្រសួង ឬស្ថាប័នដែលពាក់ព័ន្ធនឹងចាប់ផ្តើមសរសេរសេចក្តីព្រាងច្បាប់។ បន្ទាប់ពីបានជជែកវែកញែកនៅក្នុងគណៈកម្មាធិការនីតិកម្មក្នុងស្ថាប័នរបស់ខ្លួនរួចមក រដ្ឋមន្ត្រីទទួលបន្ទុកក្រសួងពាក់ព័ន្ធដែលជាអ្នករៀបចំចងក្រង និងធ្វើសេចក្តីព្រាងច្បាប់នោះ បញ្ជូនសេចក្តីព្រាងច្បាប់នេះទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីដាក់ជូនកិច្ចប្រជុំជំនាញបច្ចេកទេស កិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ ដើម្បីត្រួតពិនិត្យ និងកែសម្រួលជាមុនមុននឹងដាក់ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីពិភាក្សា និងអនុម័ត។

បន្ទាប់មកទៀត សេចក្តីព្រាងច្បាប់នឹងត្រូវបញ្ជូនទៅកាន់រដ្ឋសភាដើម្បីធ្វើការត្រួតពិនិត្យ ជាគោលការណ៍រដ្ឋសភានឹងធ្វើការត្រួតពិនិត្យទៅលើសេចក្តីព្រាងច្បាប់នេះ តែងតែផ្អែកលើគោលការណ៍ពីរ គឺទីមួយផ្អែកលើទម្រង់ និងទីពីរគតិច្បាប់។

ការត្រួតពិនិត្យលើទម្រង់ច្បាប់នេះ គឺរដ្ឋសភាពិនិត្យលើលិខិតលាយលក្ខណ៍អក្សរ ដោយដាក់ចំណងជើង ទម្រង់អត្ថបទ របៀបបែងចែកជាជំពូក របៀបដាក់លេខលំដាប់ មាត្រា ហើយត្រូវមានសេចក្តីថ្លែងហេតុនៅខាងដើមជាប់ជាមួយផង។ សេចក្តីថ្លែងហេតុនេះជាឯកសារលាយលក្ខអក្សរ ដែលតម្រូវឱ្យភ្ជាប់ជាមួយសេចក្តីព្រាងច្បាប់ ឬ

---

[133] Mlle Beatrice BALIVET, *សៀវភៅសេចក្តីផ្តើមនៃនីតិកម្ពុជា*, (២០០៦), ៦៧។

សេចក្តីស្នើច្បាប់ដែលបញ្ជូនមករដ្ឋសភា។ សេចក្តីថ្លែងហេតុនេះត្រូវមានខ្លឹមសារពន្យល់ពីគោលបំណងនៃសេចក្តីព្រាច្បាប់ ឬសេចក្តីស្នើច្បាប់ ព្រមទាំងមូលហេតុនៃការតម្រូវឱ្យអនុម័តច្បាប់នោះ។

ការត្រួតពិនិត្យលើគតិច្បាប់នេះ គឺរដ្ឋសភាពិនិត្យទៅខ្លឹមសារនៃសេចក្តីព្រាងច្បាប់នោះ ថាតើវាផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញប៉ះពាល់ដល់គោលការណ៍រក្សាការពារឯករាជ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិដែរឬទេ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាពិនិត្យហើយសម្រេចប្រគល់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះទៅគណៈកម្មការជំនាញដែលពាក់ព័ន្ធរបស់រដ្ឋសភាធ្វើការត្រួតពិនិត្យ។[134] ក្រោយពីទទួលសេចក្តីព្រាងច្បាប់ ឬសេក្តីស្នើច្បាប់មក គណៈកម្មការជំនាញធ្វើការពិនិត្យពិភាក្សាផ្ទៃក្នុងគណៈកម្មការ ដែលនៅក្នុងនោះមានសមាសភាពទាំងអស់ចំនួន១០ រូប រួមមានប្រធាន១ រូប អនុប្រធាន១ រូប លេខាធិការ១ រូប និងសមាជិក៧ រូប។ គណៈកម្មការអាចបើកសវនាការស្តីពីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ហើយអាចអញ្ជើញរដ្ឋមន្ត្រី មន្ត្រីរាជរដ្ឋាភិបាល ទីប្រឹក្សាច្បាប់ អ្នកជំនាញការ និងបុគ្គលិក ឬក្រុមនានា ដើម្បីផ្តល់ការបញ្ជាក់ ឬបំភ្លឺ ឬផ្តល់ព័ត៌មានលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ។ កាលបើពិនិត្យរួចហើយ ប្រធានគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនរដ្ឋសភា[135] បន្ទាប់មកត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះទៅគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាដើម្បីដាក់ចូលក្នុងរបៀបវារៈ។ ក្រោយមកទៀត នឹងមានការពិនិត្យជជែកពិភាក្សា និងអនុម័តនៅក្នុងរដ្ឋសភា។[136] សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលត្រូវបានអនុម័តដោយរដ្ឋសភារួចហើយ នឹងត្រូវបញ្ជូនទៅព្រឹទ្ធសភាដើម្បីពិនិត្យ។ ព្រឹទ្ធសភាត្រូវពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ។ បើជាការប្រញាប់រយៈពេលនេះត្រូវបន្ថយមកត្រឹមតែប្រាំថ្ងៃវិញ។ ក្នុងករណីដែលព្រឹទ្ធសភាឱ្យយោបល់ព្រម ឬពុំបានឱ្យយោបល់សោះក្នុងរយៈពេលដែលមានកំណត់ទុក ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយ នឹងត្រូវបញ្ជូនថ្វាយព្រះមហាក្សត្រដើម្បីឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ។ ប្រសិនបើព្រឹទ្ធសភាស្នើសុំឱ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួលដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះក៏បាន។

134 ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ រោងពុម្ពដារ៉ា,២០១៦), ២៥៤។

135 *បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា*, ប្រការ២១ ថ្មី ។

136 Mlle Beatrice BALIVET, *សៀវភៅសេចក្តីផ្តើមនៃនីតិកម្ពុជា*, (២០០៦), ៦៨។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភាត្រូវធ្វើក្នុងរយៈពេលមួយខែ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃក្នុងករណីត្រូវពិនិត្យថវិកាជាតិ និងហិរញ្ញវត្ថុ មកត្រឹមតែពីរថ្ងៃបើជាការប្រញាប់។[137]

បើរដ្ឋសភាបដិសេធទុកឱ្យហួសរយៈពេលកំណត់ ឬពន្យាពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ។ ក្នុងករណីដែលព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃបើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ និងមកត្រឹមតែបួនថ្ងៃបើជាការប្រញាប់។[138] ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទីពីរ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតជាចំហ និងយកតាមមតិភាគច្រើនដាច់ខាត។[139] ជាចុងបញ្ចប់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ត្រូវធ្វើថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើ។[140]

### ៣.១.១.២. ការត្រួតពិនិត្យហិរញ្ញវត្ថុ

សមត្ថកិច្ចក្នុងការត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋសភា គឺជាសមត្ថកិច្ចមួយដែលមានជាចាំបាច់សម្រាប់ប្រទេសជាតិទាំងមូលក្នុងការកម្រិតនូវចំណូល ចំណាយប្រចាំឆ្នាំ ជាពិសេសទៀតនោះគឺការកម្រិតពន្ធដារ និងបទដ្ឋានមួយចំនួនដែលទាក់ទិនទៅនឹងនិយ័តកម្មទៅលើទំនាក់ទំនងថវិការដ្ឋ។ ដូច្នេះហើយរដ្ឋសភាមានសិទ្ធិអំណាចរបស់ខ្លួនក្នុងការត្រួតពិនិត្យលើបញ្ជីសារពើភណ្ឌ ចំណូល និងចំណាយរបស់រដ្ឋ ហើយរួមទាំងមានការកំណត់នូវក្នុងរបបពន្ធផងដែរ។ ថវិការដ្ឋដែលអនុម័តដោយរដ្ឋសភារៀងរាល់ឆ្នាំ ក្នុងនោះក៏បញ្ជាក់នូវការប៉ាន់ប្រមាណនៃការប្រើប្រាស់ផ្នែកហិរញ្ញវត្ថុទាំងអស់របស់រដ្ឋ និងចំណូល ចំណាយទាំងអស់ដែលជាសេចក្តីត្រូវការចាំបាច់របស់រដ្ឋសម្រាប់បម្រើលើសេចក្តីត្រូវការ ឬការប្រើប្រាស់ទាំងឡាយ។ ចំពោះការអនុម័តច្បាប់ទូទៅ ឬច្បាប់ធម្មតា គឺរដ្ឋសភាពុំមានកំណត់រយៈពេលច្បាស់លាស់ទេ ប៉ុន្តែបើច្បាប់ដែលទាក់ទិននឹងហិរញ្ញវត្ថុរដ្ឋ រដ្ឋសភាពុំអាចអូសបន្លាយរយៈពេលនោះបានទេ ពីព្រោះហិរញ្ញវត្ថុជាវិស័យដ៏សំខាន់ និងជាដង្ហើមរបស់រដ្ឋ។ ដូចនេះ ការអនុម័តច្បាប់ទៅលើវិស័យហិរញ្ញវត្ថុត្រូវបានកំណត់ពេលវេលាយ៉ាងច្បាស់លាស់ណាស់ ហើយមានលក្ខណៈពិសេសទៀតផង ដូចជាមាត្រា៩០ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ក្នុងវាក្យខណ្ឌទីពីរបានកំណត់ថា "រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ"។[141] រីឯការធ្វើពង្រាងច្បាប់ស្តីពីថវិកាត្រូវបានរៀបចំឡើងដោយស្ថាប័ន ដែលបានកំណត់ដោយច្បាប់មួយពិតប្រាកដ ហើយកំណត់រយៈពេលក្នុងការអនុម័តទៅលើពង្រាងច្បាប់នោះនៅក្នុងរដ្ឋសភាវាអាស្រ័យនឹងការិយបរិច្ឆេទសម្រាប់

[137] Mlle Beatrice BALIVET, *សេចក្តីផ្តើមនៃនីតិកម្ពុជា* (២០០៦), ៦៨។

[138] Mlle Beatrice BALIVET, *សេចក្តីផ្តើមនៃនីតិកម្ពុជា* (២០០៦), ៦៨។

[139] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ១៩៩៩, មាត្រា១១៣ ថ្មី។

[140] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ១៩៩៩, មាត្រា២៨ ថ្មី។

[141] រដ្ឋធម្មនុញ្ញកម្ពុជា, វិសោធនកម្មឆ្នាំ២០០៦, មាត្រា៩០ ថ្មី(ពីរ)។

ឆ្នាំនីមួយៗ ដាក់ស្តែងនៅក្នុង មាត្រា១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃ៨ ខែកុម្ភៈ ឆ្នាំ២០២៣ កំណត់ថា "ឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ" ។[142] ត្រង់មាត្រានេះ គឺបញ្ជាក់ថារដ្ឋសភាត្រូវធ្វើការត្រួតពិនិត្យ និងការអនុម័តច្បាប់ស្តីពីថវិកា ដែលស្នើឡើងដោយរាជរដ្ឋាភិបាលឱ្យបានមុនដំណាច់ឆ្នាំនីមួយៗ។ បន្ទាប់ពីរដ្ឋសភាអនុម័តថវិការបស់រដ្ឋរួចហើយ រដ្ឋសភាមានភារកិច្ចតាមដានរាជរដ្ឋាភិបាលក្នុងការប្រើប្រាស់ថវិកា ឬនយោបាយដែលទាក់ទងទៅនឹងហិរញ្ញវត្ថុ ធនាគារដើម្បីឱ្យមានសមភាពទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋាននានា និងស្របតាមកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលដោយរដ្ឋសភាអាចបញ្ជូនគណៈកម្មាការរបស់ខ្លួនដែលពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុទៅតាមក្រសួងស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីសិក្សាពីរបាយការណ៍ ពីបញ្ហាពាក់ព័ន្ធផ្សេងៗ បន្ទាប់មកគណៈកម្មការត្រូវរៀបចំរបាយការណ៍បេសកកម្មរបស់ខ្លួនដាក់ជូនប្រធានគណៈកម្មការអចិន្ត្រៃយ៍ពិនិត្យ។ ក្នុងនោះរដ្ឋសភាមានសិទ្ធិអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺបញ្ហាណាមួយ ដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងធនាគារ និងធ្វើការស្រាវជ្រាវពីបញ្ហានោះទុកជាឯកសារ។

### ៣.១.១.៣. ការត្រួតពិនិត្យរាជរដ្ឋាភិបាល

ការត្រួតពិនិត្យរបស់រដ្ឋសភាទៅលើស្ថាប័នផ្សេងៗរបស់រដ្ឋ និងសមាជិកទាំងអស់របស់ស្ថាប័នរដ្ឋ គឺជាភារកិច្ចមួយរបស់រដ្ឋសភា ដែលចាំបាច់សម្រាប់ការត្រួតពិនិត្យទៅលើការអនុវត្តច្បាប់ដែលរដ្ឋសភាបានអនុម័តរួចហើយ។ ការត្រួតពិនិត្យនេះជាមុខងារមួយ និងមានការកំណត់ដោយការត្រួតពិនិត្យ និងកម្រិតយ៉ាងជាក់លាក់លើអំណាចដោយរដ្ឋសភាមិនអាស្រ័យនឹងទម្រង់គ្រប់គ្រងទេ ហើយអំណាចនោះមានវិសាលភាពអនុវត្តទៅលើមុខងារដែលមានក្នុងរដ្ឋ។ នេះបើយោងតាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១២១ បានកំណត់ថា សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល។ សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួនចំពោះមុខនាយករដ្ឋមន្ត្រី និងចំពោះមុខរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត។ មាត្រា១២៦ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន និងក្នុងករណីធ្វើខុសជាទម្ងន់ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសម្រេចប្តឹងទៅតុលាការមានសមត្ថកិច្ច ដោយរដ្ឋសភាសម្រេចក្នុងរឿងនេះតាមរយៈវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល។

ជាងនេះទៅទៀតរដ្ឋសភាអាចទម្លាក់សមាជិករាជរដ្ឋាភិបាលមួយរូបៗ ឬទម្លាក់នាយករដ្ឋមន្ត្រី ឬទម្លាក់គណៈរដ្ឋមន្ត្រីទាំងមូលតែម្តងនេះ បើយោងតាមមាត្រា៩៨ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានបញ្ជាក់ថា រដ្ឋសភាអាចទម្លាក់សមាជិគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសម្លេង

[142] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារៈ, លេខនស/០៣២៣/០០១ ១០ មីនា ២០២៣ មាត្រា១១។

ភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីមុខតំណែងដោយរដ្ឋសភារាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែងនេះ មានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង។ ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនមួយភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ទើរដ្ឋសភាអាចលើកមកពិភាក្សាបាន។

<u>**កំណត់សម្គាល់៖**</u> បើរដ្ឋសភាទម្លាក់សមាជិករាជរដ្ឋាភិបាលណាម្នាក់ដោយបញ្ញត្តិបន្ទោស គឺធ្លាក់តែសមាជិករាជរដ្ឋាភិបាលម្នាក់នោះទេ តែបើទម្លាក់នាយករដ្ឋមន្ត្រី គឺរាជរដ្ឋាភិបាលទាំងមូលត្រូវធ្លាក់ទាំងអស់តែម្តង។

រដ្ឋសភាមានតួនាទីត្រួតពិនិត្យរាជរដ្ឋាភិបាល និងអាចចោទសួរចំពោះសមាជិករាជរដ្ឋាភិបាល និងអាចកោះហៅសមាជិករាជរដ្ឋាភិបាលមកឆ្លើយបំភ្លឺអំពីបញ្ហាអ្វីមួយ ដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន។[143] យោងតាមមាត្រា៩៧ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានបញ្ជាក់ថា គណៈកម្មការទាំងឡាយរបស់រដ្ឋសភាអាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន។[144] តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរចោទសួរទៅសមាជិករាជរដ្ឋាភិបាល ក្នុងករណីដែលគេមានចម្ងល់ទាក់ទងការដឹកនាំការងារនៃក្រសួងរបស់ខ្លួន ឬវិស័យរបស់ខ្លួន។ ក្រោយពេលដែលសមាជិករាជរដ្ឋាភិបាលទទួលបានសំណួរពីអ្នកតំណាងរាស្ត្រហើយ ត្រូវឆ្លើយតបទៅវិញក្នុងរយៈពេល៧ថ្ងៃ បន្ទាប់ពីទទួលសំណួរ។

សមាជិករាជរដ្ឋាភិបាលអាចអញ្ជើញមកឆ្លើយបំភ្លឺដោយផ្ទាល់មាត់ចំពោះសមាជិករដ្ឋសភាហើយប្រធានរដ្ឋសភាអាចបើកឱ្យមាន ឬមិនឱ្យមានការជជែកពិភាក្សាដេញដោល។ បើគ្មានការបើកឱ្យជជែកពិភាក្សាដេញដោលទេ ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី ឬអ្នកតំណាងក្នុងករណីនាយករដ្ឋមន្ត្រីរវល់នឹងបញ្ចប់សំណួរតែម្តង។ បើមានការបើកឱ្យជជែកពិភាក្សាដេញដោលម្ចាស់សំណួរវាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រីអាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនលើសពីមួយពេលប្រជុំបានឡើយ។

រដ្ឋសភាទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ សម្រាប់ការឆ្លើយសំណួររបស់សមាជិករាជរដ្ឋាភិបាលទាំងឡាយ។ បើសំណួរចម្លើយនាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី ឬតំណាងក្នុងករណីនាយករដ្ឋមន្ត្រីមានធុរៈត្រូវមកឆ្លើយសំណួរ។ បើសំណួរចម្លើយសមាជិករាជរដ្ឋាភិបាលរូបណា សមាជិករូបនោះត្រូវមកឆ្លើយសំណួរនៅក្នុងរដ្ឋសភា ដោយខ្លួនឯង។

ទោះបីជាយ៉ាងណាក៏ដោយ សម័យប្រជុំជជែកពិភាក្សាដេញដោល ចោទឆ្លើយរវាងសមាជិករាជរដ្ឋាភិបាល និងសមាជិករដ្ឋសភានេះ គេមិនអនុញ្ញាតឱ្យមានការបោះឆ្នោតប្រភេទណាមួយឡើយ ទោះជាការអនុម័តច្បាប់ ឬ

[143] ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ រោងពុម្ពដារ៉ា,២០១៦), ១៤៣។

[144] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៩៧។

ការផ្តល់សេចក្តីទុកចិត្ត ចំពោះសមាជិករាជរដ្ឋាភិបាល ឬអ្វីក៏ដោយ ពីព្រោះវាអាចធ្វើឱ្យមានគំនុំរវាងសមាជិករាជរដ្ឋាភិបាល និងសមាជិករដ្ឋសភាដែលកើតពីការពិភាក្សាដេញដោលខាងលើនេះ។[145]

### ៣.១.២. ព្រឹទ្ធសភា

ក្នុងរដ្ឋធម្មនុញ្ញព្រឹទ្ធសភា ជាអង្គការមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។[146] សិទ្ធិអំណាចរបស់ព្រឹទ្ធសភាក្នុងស្ថាប័ននីតិបញ្ញត្តិដែលមានចែងក្នុងមាត្រា១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ អំពីការពិនិត្យរាល់សេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូង ហើយព្រមទាំងពិនិត្យបញ្ហាណាដែលរដ្ឋសភាដាក់ឱ្យពិនិត្យ។ តែទោះជាយ៉ាងណាក៏ដោយ ក៏រដ្ឋសភាមានសិទ្ធិសម្រេចចុងក្រោយលើដំណើរការនីតិបញ្ញត្តិនេះដែរ ឯព្រឹទ្ធសភាមានសិទ្ធិផ្តល់យោបល់កែតម្រូវលម្អតែប៉ុណ្ណោះ។ ក្រៅពីនោះ រដ្ឋធម្មនុញ្ញបានផ្តល់ឱ្យព្រឹទ្ធសភានូវសមត្ថកិច្ចសម្របសម្រួលរវាងរដ្ឋសភា និងរាជរដ្ឋាភិបាល។ ការអនុវត្តគោលការណ៍ប្រព័ន្ធសភាពីរជាន់ សំដៅធ្វើឱ្យមានតុល្យភាពនៅក្នុងអំណាចនីតិបញ្ញត្តិតែប៉ុណ្ណោះ ។

ព្រឹទ្ធសភាអាចតាមដានត្រួតពិនិត្យការអនុវត្តការងាររបស់រាជរដ្ឋាភិបាល ប៉ុន្តែជាទូទៅព្រឹទ្ធសភាពុំដើរតួនាទីប្រឆាំង ឬគាំទ្ររាជរដ្ឋាភិបាលឡើយ។ ព្រឹទ្ធសភាមានបេសកកម្មត្រួតពិនិត្យច្បាប់ឱ្យបានល្អ ដែលជាគោលដៅអាទិភាព ដោយមិនចំណុះបរិយាកាសនយោបាយ និងកាលៈទេសៈណាមួយនោះទេ។

#### ៣.១.២.១. ពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់

មុខងារសំខាន់របស់ព្រឹទ្ធសភា គឺការពិនិត្យឡើងវិញរាល់អត្ថបទច្បាប់ទាំងឡាយដែលរដ្ឋសភាបានអនុម័តរួចហើយ។ រដ្ឋសភាមិនអាចបញ្ជូនច្បាប់ដែលខ្លួនបានអនុម័តរួចហើយ ថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើជាផ្លូវការមុនពេលដាក់ឆ្លងឱ្យព្រឹទ្ធសភាពិនិត្យបានឡើយ។ ព្រឹទ្ធសភាមានអំណាចត្រួតពិនិត្យព្រមទាំងធ្វើអនុសាសន៍ទៅលើពង្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលត្រូវបានអនុម័តដោយរដ្ឋសភា។ ទោះបីជាព្រឹទ្ធសភាអាចធ្វើការបដិសេធ ឬស្នើឱ្យធ្វើវិសោធនកម្មទៅលើអត្ថបទច្បាប់ ប៉ុន្តែព្រឹទ្ធសភាពុំមានអំណាចចាប់បង្ខំឱ្យរដ្ឋសភាទទួលយកអនុសាសន៍របស់ខ្លួនឡើយ។ ចំណែកឯរដ្ឋសភាវិញអាចបដិសេធមិនទទួលអនុសាសន៍របស់ព្រឹទ្ធសភា ហើយនឹងអាចអនុម័តឱ្យចេញនូវច្បាប់ដែលព្រឹទ្ធសភាបានបដិសេធ។ ច្បាប់ណាក៏ដោយ បើទោះបីជាព្រឹទ្ធសភាបដិសេធ តែទីបំផុតនៅតែត្រូវបានរដ្ឋសភាអនុម័តហើយដាក់ថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខា និងប្រកាសឱ្យប្រើ។ រដ្ឋធម្មនុញ្ញមិនបានផ្តល់ឱ្យព្រឹទ្ធសភានូវអំណាចអនុម័តច្បាប់ ឬអំណាចជំទាស់អត្ថបទច្បាប់ឡើយ ប៉ុន្តែផ្តល់ឱ្យនូវតួនាទីប្រឹក្សា ឬអំណាចធ្វើអនុសាសន៍ដែលរដ្ឋសភាបានអនុម័ត។

[145] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៩៦។

[146] រដ្ឋធម្មនុញ្ញកម្ពុជា វិសោធនកម្មឆ្នាំ១៩៩៩, មាត្រា១១២ ថ្មី។

### ក. នីតិវិធីពិនិត្យអត្ថបទច្បាប់

នៅពេលមានអត្ថបទច្បាប់ (សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់) ដែលរដ្ឋសភាបានអនុម័តជាលើកដំបូង ឬបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យស្នើឡើងដោយប្រធានរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាត្រូវទទួលយកពិនិត្យ ព្រមទាំងចាត់បញ្ជូនសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះទៅឱ្យគណៈកម្មការជំនាញមួយ ឬច្រើនពិនិត្យសិក្សាទៅតាមវិស័យជាសមត្ថកិច្ច និងចម្លងចែកជូនគ្រប់សមាជិកព្រឹទ្ធសភាដោយមានភ្ជាប់សេចក្ដីថ្លែងហេតុទៅជាមួយផង។[147]

ក្នុងករណីសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួងនោះពាក់ព័ន្ធនឹងសមត្ថកិច្ចគណៈកម្មការច្រើន គណៈកម្មាធិការអចិន្ត្រៃយ៍សម្រេចចាត់តាំងគណៈកម្មការណាមួយឱ្យទទួលបន្ទុកធ្វើរបាយការណ៍។ នៅពេលអត្ថបទច្បាប់ទាំងនោះបានបញ្ជូនទៅគណៈកម្មការមួយ ឬច្រើនហើយគណៈកម្មការនោះត្រូវសុំយោបល់ពីសមាជិកព្រឹទ្ធសភា (យល់ព្រមកែសម្រួល ឬបដិសេធជាអសារបង់ ភ្ជាប់ដោយការកត់សម្គាល់ និងអនុសាសន៍)។ ការផ្ដល់យោបល់របស់សមាជិកព្រឹទ្ធសភាត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

សមាជិកព្រឹទ្ធសភាត្រូវពិនិត្យដោយយកចិត្តទុកដាក់ ដោយផ្ដោតទៅលើខ្លឹមសារទាំងមូលនៃសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះ។ ការពិនិត្យនេះត្រូវធ្វើក្នុងរយៈពេល៣ថ្ងៃយ៉ាងយូរមុនគណៈកម្មការប្រជុំពិនិត្យសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ឬបញ្ហាទាំងពួង បើជាការប្រញាប់១ថ្ងៃយ៉ាងយូរមុនគណៈកម្មការប្រជុំពិនិត្យ។ នៅពេលកិច្ចប្រជុំគណៈកម្មការពិនិត្យរួចហើយ (ទាំងយល់ព្រម និងសំណើកែសម្រួល) ត្រូវធ្វើការស្នើសុំតាមរយៈប្រធានគណៈកម្មការទៅប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីសុំដាក់បញ្ចូលក្នុងរបៀបវារៈនៃអង្គប្រជុំព្រឹទ្ធសភា។[148] ព្រឹទ្ធសភាអនុម័តលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ទាំងមូលនោះបាន។

ជារួមព្រឹទ្ធសភាត្រួតពិនិត្យហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្ដីព្រាង ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងឡាយទាំងពួងដែលរដ្ឋសភាបានដាក់ពិនិត្យ។ បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែ៥ថ្ងៃ តែអ្នកស្នើសុំត្រូវជូនហេតុផលជាលាយលក្ខណ៍អក្សរទៅព្រឹទ្ធសភា បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះក្នុងរយៈពេលដែលបានកំណត់ទុក ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រម នោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។

បើព្រឹទ្ធសភាសុំឱ្យកែសម្រួលសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះរដ្ឋសភាត្រូវយកមកត្រួតពិនិត្យពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភាត្រូវពិនិត្យ និងសម្រេចត្រង់បទប្បញ្ញត្តិណា ឬចំណុចណាដែលព្រឹទ្ធសភាបានសុំឱ្យកែសម្រួលដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។ ការបង្វិលទៅបង្វិលមករវាង

---

[147] ជុំ អ៊ីម, *ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា* (២០២១), ១៧៧។

[148] *បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា*, ប្រការ៣២ និង ៣៣។

ព្រឹទ្ធសភា និងរដ្ឋសភាត្រូវធ្វើឡើងក្នុងរយៈពេលមួយខែប៉ុណ្ណោះ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និងហិរញ្ញវត្ថុត្រូវបន្ថយមកត្រឹមពីរថ្ងៃបើសិនជាការប្រញាប់។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យាពេលដែលកំណត់ទុកពិនិត្យនោះរយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភាត្រួតពិនិត្យ និងព្រឹទ្ធសភាត្រួតពិនិត្យត្រូវបន្ថែមរយៈពេលឱ្យស្មើគ្នាផងដែរ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ នោះរដ្ឋសភានឹងមិនអាចយកសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹម១៥ថ្ងៃ ប្រសិនបើពិនិត្យអំពីថវិកាជាតិ និងហិរញ្ញវត្ថុ គឺបន្ថយមកត្រឹម៤ថ្ងៃ បើជាការប្រញាប់។ ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២ នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត (៥០%+១)។ សេចក្តីព្រាងច្បាប់ណា ឬសេចក្តីស្នើច្បាប់ណា ដែលបានសម្រេចដូចខាងលើនេះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ។[149]

### ៣.១.២.២. កម្មវត្ថុនៃការត្រួតពិនិត្យ

- **តាមដានការអនុវត្តច្បាប់៖** ព្រឹទ្ធសភាដើរតួនាទីសំខាន់ក្នុងការតាមដានដំណើរការការងាររបស់ស្ថាប័នរដ្ឋ និងត្រួតពិនិត្យយ៉ាងទៀងទាត់អំពីការអនុវត្តច្បាប់របស់ស្ថាប័ននីតិប្រតិបត្តិ។ ដើម្បីបំពេញមុខងារតាមដានការអនុវត្តច្បាប់ ព្រឹទ្ធសភាមានគណៈកម្មការជំនាញចំនួន១០ ទទួលខុសត្រូវតាមវិស័យជាសមត្ថកិច្ចរបស់ខ្លួន ។ គណៈកម្មការជំនាញនីមួយៗ បំពេញការងារទៅតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍។
- **ការអនុវត្តកម្មវិធី និងផែនការរបស់រាជរដ្ឋាភិបាល៖** ព្រឹទ្ធសភាក៏ដើរតួនាទីសំខាន់ក្នុងការអនុវត្តនូវកម្មវិធី និងផែនការរបស់រាជរដ្ឋាភិបាលលើការងារប្រជាធិបតេយ្យ នីតិរដ្ឋ ការងារកែទម្រង់រដ្ឋ ការងារកាត់បន្ថយភាពក្រីក្រ ការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចជាដើម។

### ៣.១.២.៣. វិធីត្រួតពិនិត្យ

ចំពោះការត្រួតពិនិត្យ ព្រឹទ្ធមានវិធីសាស្ត្រដូចខាងក្រោម៖

**ក. ចុះរកព័ត៌មានតាមមូលដ្ឋាន៖** ការធ្វើបេសកកម្មចុះរកព័ត៌មាននៅតាមមូលដ្ឋានគឺព្រឹទ្ធសភាបញ្ជូនគណៈប្រតិភូរបស់គណៈកម្មការឱ្យចេញទៅបំពេញបេសកម្មស្រាវជ្រាវស្វែងយល់ពីព័ត៌មានផ្ទាល់នៅនឹងកន្លែងក្នុង ឬក្រៅតាមការចាំបាច់ ព្រឹទ្ធសភាប្រមូលបញ្ហារសើបពីប្រភពផ្សេងៗតាមរយៈឯកសារអនាមិក ជួបសម្ភាសន៍អ្នកឯកទេសពាក់ព័ន្ធ សិក្សាវិភាគលើទិដ្ឋភាពផ្សេងៗ ឯកសារយោង បទដ្ឋានគតិយុត្ត ឬសំណុំរឿងប្រហាក់ប្រហែល សហការជាមួយអាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល និងប្រជាពលរដ្ឋដល់ទីកន្លែង។ គណៈកម្មការជំនាញអាចរៀបចំ

149 រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា១១៣ ថ្មី។

និងដឹកនាំសវនាការជាសាធារណៈនៅក្រៅព្រឹទ្ធសភាស្តីពីសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលផ្តល់ឱកាសឱ្យប្រជាពលរដ្ឋចូលរួមផ្តល់ពីគំនិត និងបង្ហាញពីកង្វល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ។ បន្ទាប់ពីបញ្ចប់បេសកកម្មហើយ គណៈប្រតិភូត្រូវធ្វើរបាយការណ៍ផ្តល់ព័ត៌មានដែលបានចុះស្រាវជ្រាវជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាពិនិត្យ។

**ខ. អញ្ជើញតំណាងរាជរដ្ឋាភិបាលមកបំភ្លឺ៖** គណៈកម្មការអាចអញ្ជើញបុគ្គលិកណាមួយដែលមានលក្ខណសម្បត្តិខ្ពស់ក្នុងជួររាជរដ្ឋាភិបាល ឬក៏អញ្ជើញសមាជិកគណៈរដ្ឋមន្ត្រីណាម្នាក់មកសាកសួរបាន ប្រសិនបើឃើញមានការខ្វះខាតលើអត្ថបទច្បាប់ណាមួយ ព្រឹទ្ធសភាអាចស្នើសុំឱ្យរាជរដ្ឋាភិបាល ឬរដ្ឋមន្ត្រីពាក់ព័ន្ធមកបំភ្លឺ និងអាចផ្តល់ជាអនុសាសន៍កែលម្អឡើងវិញក្នុងន័យស្ថាបនា។ ការអញ្ជើញមកសាកសួរនេះ គឺដើម្បីផ្តល់ព័ត៌មានផ្សេងៗ ពាក់ព័ន្ធនឹងមុខងារជាសមត្ថកិច្ចរបស់គណៈកម្មការតែប៉ុណ្ណោះពុំមែនជាការសាកសួរដេញដោលដើម្បីប្រឆាំង ឬគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ឬដើម្បីដាក់ញត្តិបន្ទោស ឬដកសមាជិកគណៈរដ្ឋមន្ត្រីនោះចេញពីតំណែងដូចរដ្ឋសភាឡើយ។

**គ. ពិនិត្យលើរបាយការណ៍សកម្មភាពរបស់រាជរដ្ឋាភិបាល ឬក្រសួងផ្ញើជូន៖** ព្រឹទ្ធសភាដើរតួនាទីសំខាន់ក្នុងការតាមដានត្រួតពិនិត្យការងាររបាយការណ៍សកម្មភាពរបស់រាជរដ្ឋាភិបាល ឬរបស់ក្រសួងដើម្បីទទួលបាននូវព័ត៌មានសំខាន់ៗដែលកើតមានឡើងនៅតាមបណ្តាក្រសួងស្ថាប័នផ្សេងៗ។ ករណីនេះបើសិនជាព្រឹទ្ធសភាពិនិត្យលើរបាយការណ៍ឃើញថាមានការខ្វះចន្លោះ ឬចំណុចខ្សោយត្រង់ណានោះព្រឹទ្ធសភាអាចធ្វើជារបាយការណ៍ទៅរាជរដ្ឋាភិបាល ដើម្បីផ្តល់ជាយោបល់កែលម្អ និងជាការរួមចំណែកក្នុងយន្តការស្ថាបនាចំណុចខ្វះខាត ឱ្យមានលក្ខណៈល្អឡើងវិញ។

## ៣.២. ការត្រួតពិនិត្យដោយតុលាការ

តុលាការរដ្ឋបាល គឺជាស្ថាប័នដែលមានបេសកកម្មដ៏ស្មុគស្មាញដើម្បីធ្វើការពិនិត្យមើលឡើងវិញ និងត្រួតពិនិត្យការប្រើប្រាស់អំណាចខាងប្រតិបត្តិ និងស្ថាប័នរដ្ឋបាល ថាតើអំណាចត្រូវបានអនុវត្តដោយយោងទៅតាមច្បាប់ ឬការប្រើដោយពុំត្រឹមត្រូវនៃអំណាចណាមួយ និងមានគោលបំណងដើម្បីការការពារមិនឱ្យមានការរំលោភបំពាន។[150]

រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានចែងថាអំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។[151] យោងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការថ្មី តុលាការប្រទេសកម្ពុជាមានពីរថ្នាក់រួមមាន៖ សាលាជម្រះក្តីជាន់ទាប និងសាលាជម្រះក្តីជាន់ខ្ពស់ដែលមានសមត្ថកិច្ចសម្រាប់ដោះស្រាយរឿងក្តី

[150] ឥន យឿន, *វិវាទរដ្ឋបាល* (ភ្នំពេញ៖ ២០១៦), ៦០។

[151] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា១២៨ ថ្មី(មាត្រា១០៩ ចាស់) វាក្យខណ្ឌទី៣។

ទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។[152] ច្បាប់ថ្មីនេះបានបង្កើតឱ្យមានតុលាការចាត់តាំង ឬហៅថាយុត្តាធិការចាត់តាំងដែលជាយុត្តាធិការជំនាញដែលមានដូចជា តុលាការរដ្ឋប្បវេណី តុលាការព្រហ្មទណ្ឌ តុលាការពាណិជ្ជកម្ម និងតុលាការការងារ។ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការថ្មីនេះបានប្រគល់អំណាចឱ្យតុលាការរដ្ឋប្បវេណីជាអ្នកមានសមត្ថកិច្ចដោះស្រាយរឿងក្តីរដ្ឋបាលពិតមែន ប៉ុន្តែនៅមិនទាន់បង្កើតតុលាការរដ្ឋបាលដាច់ពីតុលាការធម្មតានៅឡើយទេ ហើយនីតិវិធីរដ្ឋប្បវេណីអាចយកមកអនុវត្តសម្រាប់វិវាទរដ្ឋបាលផងដែរ។ ដូច្នេះ គេមិនអាចនិយាយបានថា ប្រទេសកម្ពុជានៅមិនទាន់មានតុលាការរដ្ឋបាលបានទេ ឬចៅក្រមបដិសេធមិនព្រមដោះស្រាយវិវាទរដ្ឋបាលបានទេ ពីព្រោះតុលាការរដ្ឋប្បវេណីដើរតួនាទីជាតុលាការរដ្ឋបាល។[153] ដូច្នេះ រឿងក្តីរដ្ឋបាលត្រូវបានច្បាប់ឱ្យដំណើរការតាមតុលាការរដ្ឋប្បវេណីនៃសាលាដំបូង សភារដ្ឋប្បវេណីនៃសាលាឧទ្ធរណ៍ និងសភារដ្ឋប្បវេណីនៃតុលាការកំពូល។[154]

## ៣.៣. ការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

គេដឹងហើយថាក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលមួយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ កម្ពុជាឆ្នាំ១៩៩៣ ដែលមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយព្រមទាំងមានសិទ្ធិពិនិត្យ និងសម្រេចលើករណីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។[155] ការអនុម័តទាំងឡាយរបស់រដ្ឋសភាដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ និងត្រូវចាត់ទុកជាអសារសូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ។[156] តាមគោលការណ៍ក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចយកបញ្ហាណាមួយមកពិនិត្យធម្មនុញ្ញភាពនៃច្បាប់ បកស្រាយរដ្ឋធម្មនុញ្ញ ឬច្បាប់ណាមួយដោយខ្លួនឯងបានជាដាច់ខាត។

### ៣.៣.១. គោលការណ៍នៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់

ការត្រួតពិនិត្យធម្មនុញ្ញភាពគឺសំដៅឆ្លៀងផ្ទាត់ថា តើច្បាប់ទាំងឡាយដែលស្ថិតនៅក្រោមឋានានុក្រមនៃរដ្ឋធម្មនុញ្ញស្របទៅនឹងច្បាប់កំពូលនេះដែរឬទេ? ក្រុមប្រឹក្សាធម្មនុញ្ញធ្វើការត្រួតពិនិត្យទាំងទម្រង់ និងគតិច្បាប់។ នៅក្នុងការសិក្សាស្រាវជ្រាវអំពីការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញទៅលើទម្រង់ ឬបែបបទនេះ គឺជាការត្រួតពិនិត្យ

---

[152] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ព្រះរាជក្រមលេខនស/០៧១៤/០១៥ ១៦ កក្កដា ២០១៤ មាត្រា៣។

[153] គន យឿន, *វិវាទរដ្ឋបាល* (ភ្នំពេញ៖ ២០១៦), ៦។

[154] គន យឿន, *សៀវិវាទរដ្ឋបាល* (ភ្នំពេញ៖ ២០១៦), ៦១។

[155] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា១៣៦ ថ្មី។

[156] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា៩២។

អំពីការប្រតិបត្តិនានាទៅតាមលក្ខខណ្ឌទាំងឡាយនៃរដ្ឋធម្មនុញ្ញដែលបានកំណត់ និងជាការទាមទារនានាដែលតម្រូវឱ្យមានការពាក់ព័ន្ធចំពោះការបង្កើតលិខិតបទដ្ឋានណាមួយនោះ។ មានន័យថា តើការបង្កើតលិខិតបទដ្ឋាននោះតម្រូវដោយអង្គការណាមួយ? តើអង្គការនោះបានធ្វើទៅតាមនីតិវិធីដែលរដ្ឋធម្មនុញ្ញបានតម្រូវដែរ ឬទេ?

### ៣.៣.២. ការត្រួតពិនិត្យធម្មនុញ្ញភាព

ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់មានពីរបែបគឺ ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល (ការត្រួតពិនិត្យជាមុន) និងការត្រួតពិនិត្យធម្មនុញ្ញជាបច្ឆាកាល (ការត្រួតពិនិត្យជាក្រោយ)។

#### ៣.៣.២.១. ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល

ការត្រួតពិនិត្យជាមុន គឺជាការត្រួតពិនិត្យទៅលើអត្ថបទច្បាប់ទាំងឡាយណាមុនពេលដែលច្បាប់នោះត្រូវបានប្រកាសឱ្យប្រើ ការត្រួតពិនិត្យច្បាប់មុនប្រកាសឱ្យប្រើគេហៅថាការត្រួតពិនិត្យជាអាទិកាល។ សេចក្តីសម្រេចស្តីពីភាពមិនស្របនឹងរដ្ឋធម្មនុញ្ញជាឧបសគ្គចំពោះការប្រកាសឱ្យប្រើ។ ដូច្នេះហើយការត្រួតពិនិត្យជាមុន ជាគោលការណ៍បង្កើតឡើងនូវការធានាភាពច្បាស់លាស់នៃច្បាប់ ដោយហេតុថាវាមានអានុភាពទប់ស្កាត់ជាមុន។[157]

ក្រោយពីរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ អត្ថបទច្បាប់រៀបចំអង្គការ ឬវិសោធនកម្មនៃច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាត្រូវដាក់ឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ដើម្បីពិនិត្យថាតើអត្ថបទច្បាប់ និងបទបញ្ជាផ្ទៃក្នុងនោះស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ។ ក្រៅពីអត្ថបទច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភា អត្ថបទច្បាប់ស្តីពីការផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ និងច្បាប់ធម្មតាទូទៅក៏អាចត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យផងដែរ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរ ថាតើបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ។[158]

អ្នកមានសិទ្ធិបញ្ជូនច្បាប់ដែលរដ្ឋសភាដែលបានអនុម័ត និងព្រឹទ្ធសភាពិនិត្យចប់សព្វគ្រប់ទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នោះត្រូវប្រកាសឱ្យប្រើរួមមាន៖

- ព្រះមហាក្សត្រ
- នាយករដ្ឋមន្ត្រី
- ប្រធានរដ្ឋសភា
- ប្រធានព្រឹទ្ធសភា

[157] សឿន សោភ័ណ, *នីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ សុខ ចេង, ២០១៩),ទំព័រទី ១២៤។

[158] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា១៤០ ថ្មី។

– សមាជិករដ្ឋសភាចំនួនមួយភាគដប់ (១/១០)
– សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន (១/៤)។

ពាក់ព័ន្ធនឹងបទបញ្ញាផ្ទៃក្នុងសភាទាំងពីរ (រដ្ឋសភា និងព្រឹទ្ធសភា) ក្រោយពីបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភារួចមកប្រធាននៃស្ថាប័នជាអ្នកស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញធ្វើការពិនិត្យអំពីធម្មនុញ្ញភាពនៃបញ្ញាផ្ទៃក្នុងនោះ។[159]

ជាក់ស្តែង មកដល់ពេលនេះក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចលទ្ធផលស្តីពីការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការមួយចំនួន ដែលក្នុងនោះយើងនឹងលើកយកសំណើសំខាន់ៗ មកធ្វើការបង្ហាញដូចខាងក្រោម៖

➢ នៅក្នុងឆ្នាំ១៩៩៩ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់មួយចំនួនដូចជា៖
– ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
– ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
– ច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
– ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
– ច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
– ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

➢ នៅក្នុងឆ្នាំ២០០៤ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់មួយចំនួនដូចជា៖
– ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
– ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
– ច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
– ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ
– ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។

➢ នៅក្នុងឆ្នាំ២០១៣ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់មួយចំនួនដូចជា៖
– ច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
– ច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
– ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម

[159] វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខនស/រកម/០១០៧/០០៥, ៣១ មករា ២០០៧ មាត្រា១៦ ថ្មី, ១៧ ថ្មី។

– ច្បាប់ស្តីពីវិសោធនកម្មច្បាប់ មាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
– ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាការពារជាតិ។

➢ នៅក្នុងឆ្នាំ២០១៤ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់មួយចំនួនដូចជា៖
– ច្បាប់ស្តីការរៀបចំអង្គការតុលាការ
– ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

➢ នៅក្នុងឆ្នាំ២០១៨ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់មួយចំនួនដូចជា៖
– ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
– ច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

➢ នៅក្នុងឆ្នាំ២០២០ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់មួយចំនួនដូចជា៖
– ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
– ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍។

➢ នៅក្នុងឆ្នាំ២០២៣ ប្រធានរដ្ឋសភា បានស្នើសុំត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់មួយចំនួនដូចជា៖
– ច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
– ច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន
– ច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច

ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាពតបទៅនឹងសំណើខាងលើ និងសំណើដទៃទៀត ដោយបានចេញសេចក្តីសម្រេចផ្លូវការដែលជាសេចក្តីសម្រេចបិទផ្លូវតវ៉ាសម្រាប់យកទៅអនុវត្តឱ្យស្របទៅតាមស្មារតីនៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣។[160]

តួយ៉ាង ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចលទ្ធផលស្តីពីការត្រួតពិនិត្យធម្មនុញ្ញភាព នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងព្រឹទ្ធសភាបានចំនួន១៨ សេចក្តីសម្រេចស្មើនឹង១៨សំណើដែលក្នុងនោះយើងនឹងលើកយកសំណើ សំខាន់ៗមកធ្វើការបង្ហាញដូចខាងក្រោម៖

➢ នៅក្នុងឆ្នាំ១៩៩៩ ក្រុមប្រឹក្សាធម្មនុញ្ញបានត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា តាមសំណើរបស់ប្រធានព្រឹទ្ធសភា។

➢ នៅក្នុងឆ្នាំ២០០៣ ក្រុមប្រឹក្សាធម្មនុញ្ញបានត្រួតពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ៣៦ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា។

[160] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា១៤២ ថ្មី(មាត្រា១២៣ ចាស់)។

- នៅក្នុងឆ្នាំ២០០៤ ក្រុមប្រឹក្សាធម្មនុញ្ញបានត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានស្តីទីរដ្ឋសភា។
- នៅក្នុងឆ្នាំ២០០៥ ក្រុមប្រឹក្សាធម្មនុញ្ញបានត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភារួមមាន៖
  - ប្រការ៤៤ ថ្មីនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា តាមសំណើរបស់ប្រធានព្រឹទ្ធសភា
  - ប្រការ៤៧ ថ្មី(ពីរ)នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាតាមសំណើរបស់ប្រធានរដ្ឋសភាស្តីទី
  - វិសោធនកម្មប្រការ២,៣,៤,៥,៦,៧,៩,១០,១៤,១៥,១៧,២២,៣១ថ្មី,៣៣,៤០,៤១,៤៨,៥១,៥៥,៥៦ ៥៨,៥៩,៦០ និងប្រការ៨៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា។
- ក្នុងឆ្នាំ២០០៦ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភារួមមាន៖
  - វិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា តាមសំណើរបស់ប្រធានព្រឹទ្ធសភា
  - បទបញ្ជាផ្ទៃក្នុងថ្មីនៃព្រឹទ្ធសភា តាមសំណើរបស់ប្រធានព្រឹទ្ធសភា
  - វិសោធនកម្មប្រការ១៥ ថ្មី និងប្រការ៤៨ ថ្មីនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាតាមសំណើរបស់ប្រធានរដ្ឋសភា
  - វិសោធនកម្មប្រការ២ ថ្មី,៥ ថ្មី,១០ ថ្មី, ៣៥, ៤៧ ថ្មី(ពីរ) និងប្រការ៨២ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាតាមសំណើរបស់អនុប្រធានទី១ នៃរដ្ឋសភា។
- នៅក្នុងឆ្នាំ២០១៤ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភារួមមាន៖
  - វិសោធនកម្ម ជំពូកទី១២ ប្រការ៤៨ ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា
  - វិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ តាមសំណើរបស់ប្រធានស្តីទី ព្រឹទ្ធសភា
  - វិសោធនកម្ម ប្រការ១៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា។
- នៅក្នុងឆ្នាំ២០១៧ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភារួមមាន៖
  - វិសោធនកម្មប្រការ៩ ប្រការ១១ ប្រការ១២ ប្រការ១៤ ប្រការ៧៨ ប្រការ៧៩ ប្រការ៨០ ប្រការ៨១ និងចំណងជើងជំពូកទី១៣ ព្រមទាំងបន្ថែមជំពូកទី១២ (ស្ទួន) ប្រការ៧៥ (ស្ទួន) និងប្រការ ៧៧(ស្ទួន) នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាតាមសំណើរបស់ប្រធានស្តីទីព្រឹទ្ធសភា[161]
  - វិសោធនកម្ម ជំពូកទី១២ថ្មី ប្រការ៤៨ថ្មី(បី) នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាតាមសំណើរបស់ប្រធានរដ្ឋសភា។

[161] សេចក្តីសម្រេចលេខ ១៨៨/០២៨/២០១៧ កបធ.ច ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧

- នៅក្នុងឆ្នាំ២០២២ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភារួមមាន៖ វិសោធនកម្មប្រការ២ ថ្មី(ពីរ) ប្រការ៥ ថ្មី(ពីរ) ប្រការ១០ ថ្មី(បី) ប្រការ១៦ និងប្រការ៣៥ ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានស្តីទីរដ្ឋសភា។
- នៅក្នុងឆ្នាំ២០២៣ ក្រុមប្រឹក្សាធម្មនុញ្ញ បានត្រួតពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភារួមមាន៖
  - វិសោធនកម្មប្រការ៤ ថ្មី ប្រការ៦ ថ្មី(ពីរ) ប្រកា២៩ ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា តាមសំណើរបស់ប្រធានរដ្ឋសភា
  - វិសោធនកម្មប្រការ២,ប្រការ៧, ប្រការ៨, ប្រការ២៩, ប្រការ៣៩, ប្រការ៤២, ប្រការ៤៧, ប្រការ៦០, ប្រការ៧២ និងប្រការ៨៤ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា តាមសំណើរបស់ប្រធានស្តីទីព្រឹទ្ធសភា។

**៣.៣.២.២. ការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល**

ការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាបច្ឆាកាល គឺជាការត្រួតពិនិត្យទៅលើអត្ថបទច្បាប់ទាំងឡាយណា ដែលច្បាប់ទាំងនោះត្រូវបានប្រកាសឱ្យប្រើរួចហើយ។ ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើរួចហើយ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន តំណាងរាស្ត្រមួយភាគដប់ ឬតុលាការអាចស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។[162]

ប្រជារាស្ត្រមានសិទ្ធិប្តឹងពីធម្មនុញ្ញភាពនៃច្បាប់បានតាមរយៈប្រធានរដ្ឋសភា ឬតំណាងរាស្ត្រចំនួនមួយភាគដប់ (១/១០) តាមរយៈប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន(១/៤)។[163]

នៅក្នុងរដ្ឋធម្មនុញ្ញមិនបានកំណត់នូវលក្ខខណ្ឌការត្រួតពិនិត្យធម្មនុញ្ញភាពដោយអញ្ញត្រកម្មនេះទេ។ ក៏ប៉ុន្តែមានចែក្នុងមាត្រា១៩ វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា បុគ្គលនោះអាចលើកអំពីធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬសេចក្តីសម្រេចរបស់ស្ថាប័ននានា ដែលគេអះអាងថា ប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន។ បើយោងតាមមាត្រានេះ សិទ្ធិប្តឹងទៅតុលាការអាចជាសិទ្ធិរបស់ដើមចោទ ចុងចោទ ក៏ដូចជាគូភាគីនៅតុលាការដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មាត្រា១៩ វាក្យខណ្ឌទី២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបន្ថែមថា បើយល់ឃើញថា ការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើកករណីនេះទៅតុលាការកំពូលក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរ។ ប្រសិនបើចៅក្រមយល់ថា មានមូលដ្ឋានច្បាស់លាស់ ចៅក្រមត្រូវបញ្ជូនសំណុំរឿងទៅតុលាការកំពូលដែលត្រូវពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល១៥ថ្ងៃ

[162] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញមាត្រា១៨ ថ្មី។

[163] រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣, មាត្រា១៤១ ថ្មី។

យ៉ាងយូរ ដូចក្នុងមាត្រា១៩ វាក្យខណ្ឌទី៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា តុលាការកំពូលត្រូវធ្វើការពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ ថ្ងៃយ៉ាងយូរ លើកលែងតែតុលាការកំពូលយល់ឃើញថាពាក្យបណ្តឹងតវ៉ានេះមិនអាចទទួលបាន។[164] តុលាការកំពូលពេលនេះធ្វើការជម្រះ ដោយពិនិត្យជាលើកទីពីរមុនបញ្ជូនបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ។ បញ្ញត្តិនេះ មានលក្ខណៈគួរឱ្យកត់សម្គាល់យ៉ាងខ្លាំង ដោយសារតែវាមានវិសាលភាពទៅដល់ការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល ដែលធ្វើឱ្យក្រុមប្រឹក្សាធម្មនុញ្ញអាចពិនិត្យបានដោយមានបណ្តឹងពីគូភាគីក្នុងរឿងក្តី។

### ៣.៣.៣. សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត

ក្រុមប្រឹក្សាធម្មនុញ្ញ ក៏មានសមត្ថកិច្ចក្នុងការដោះស្រាយនៅវិវាទទាក់ទងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភា និងដោះស្រាយទៅលើវិវាទកម្មការបោះឆ្នោតផងដែរ។[165] ក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ា និងបណ្តឹងរបស់គណបក្សនយោបាយទាំងឡាយដែលក្រសួងមហាផ្ទៃបានបដិសេធមិនព្រមចុះបញ្ជីគណបក្សនយោបាយ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ា និងបណ្តឹងជំទាស់នឹងបញ្ជីដំបូងនៃការចុះបញ្ជីបោះឆ្នោត និងបណ្តឹងក្នុងពេលឃោសនាបោះឆ្នោត។

❖ **សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភា**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ផ្សេងៗទៀត ដែលបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា កំណត់ថា ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចៈ

១. លើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយ ឬរបស់បេក្ខជន ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនរបស់ខ្លួន។ បណ្តឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេលប្រាំ(០៥)ថ្ងៃ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេលដប់(១០)ថ្ងៃ យ៉ាងយូរបន្ទាប់ពីបានទទួលពាក្យបណ្តឹង។[166]

---

[164] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខនស/រកម/០៤៩៨/០៦, ០៨ មេសា ១៩៩៨ មាត្រា១៩ ។

[165] វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខនស/រកម/០១០៧/០០៥, ៣១ មករា ២០០៧ មាត្រា ២៥ ថ្មី។

[166] វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខនស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨ មាត្រា ២៦.១ ថ្មី។

២. ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់បុគ្គល ឬតំណាង ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបដិសេធបណ្ដឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោតរបស់ខ្លួន។ បណ្ដឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេលប្រាំ(៥)ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីចម្លងសេចក្តីសម្រេចពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្ដឹងតវ៉ានេះដោយបើកសវនាការជាសាធារណៈក្នុងរយៈពេលដប់(១០)ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលបានពាក្យបណ្ដឹង។[167]

៣. ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ា ឬជំទាស់ជាលាយលក្ខណ៍អក្សររបស់បុគ្គល ឬតំណាង ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធតវ៉ាអំពីការបាត់បង់ឈ្មោះ ឬជំទាស់អំពីការចុះឈ្មោះ ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃបុគ្គលណាម្នាក់ដែលមានលក្ខណៈមិនត្រឹមត្រូវតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត។ បណ្ដឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេលប្រាំ(០៥)ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលបានសេចក្តីចម្លងសេចក្តីសម្រេចបដិសេធពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្ដឹងតវ៉ា ឬជំទាស់នេះ ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេលដប់(១០) ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលបានពាក្យបណ្ដឹង។[168]

៤. ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ាដោយផ្ទាល់ ជាលាយលក្ខណ៍អក្សររបស់គណបក្សនយោបាយ ដែលបានឈរឈ្មោះបោះឆ្នោត ចំពោះលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន។ បណ្ដឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេលចិតសិបពីរ (៧២) ម៉ោងយ៉ាងយូរបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្ដឹងតវ៉ា ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេលពីដប់(១០)ថ្ងៃ ទៅម្ភៃ(២០)ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលបានពាក្យបណ្ដឹង។[169]

៥. ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់បុគ្គល ឬគណបក្សនយោបាយ ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធបណ្ដឹងតវ៉ាអំពីលទ្ធផលបោះឆ្នោតបណ្ដោះអាសន្នរបស់ខ្លួន។ បណ្ដឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេលចិតសិបពីរ(៧២)ម៉ោងយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីការបដិសេធ។ ក្រុមប្រឹក្សាធម្មនុញ្ញ

[167] វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខនស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨ មាត្រា ២៦.២ ថ្មី។

[168] វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខនស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨ មាត្រា ២៦.៣ ថ្មី។

[169] វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខនស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨ មាត្រា ២៦.៤ ថ្មី។

ត្រូវសម្រេចលើបណ្តឹងតវ៉ានេះ ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេលពីដប់(១០)ថ្ងៃទៅម្ភៃ(២០)ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលបានពាក្យបណ្តឹង។[170]

៦. ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សររបស់បុគ្គល ដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានចែងក្នុងជំពូកទី១០ (ទោសបញ្ញត្តិ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងជំពូកទី១០ (ទោសបញ្ញត្តិ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ បណ្តឹងនេះត្រូវបានធ្វើឡើងក្នុងរយៈពេលចិតសិបពីរ(៧២)ម៉ោង បន្ទាប់ពីទទួលបានសេចក្តីសម្រេចនេះ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេលដប់ (១០)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានពាក្យបណ្តឹងតវ៉ា។[171]

[170] វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខនស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨ មាត្រា ២៦.៥ ថ្មី។

[171] វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, លេខនស/រកម/០៣១៨/០០៥, ១០ មីនា ២០១៨ មាត្រា ២៦.៦ ថ្មី។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទ **ការបែងចែកអំណាចទាំងបី អនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣** រួចមកយើងឃើញថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលជាសមិទ្ធផលនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ហើយច្បាប់ និងសេចក្ដីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ហើយរដ្ឋធម្មនុញ្ញនេះទៀតសោត ចែងបញ្ញត្តិពីចំណុចសំខាន់ៗ ដែលពាក់ព័ន្ធនឹងរបបនយោបាយ ការបែងចែកអំណាចរបស់រដ្ឋ មុខងាររបស់ស្ថាប័ននីមួយៗ វិស័យនានារបស់រដ្ឋ និងចំណុចសំខាន់ៗមួយចំនួនទៀតតែប៉ុណ្ណោះ។ តាមរយៈនេះរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ បានកំណត់ថា ប្រទេសកម្ពុជាជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

តាមរយៈនេះ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា៥១ បានចែងថា អំណាចត្រូវបានបែងចែកជាបី(០៣) និងដាច់ដោយឡែកពីគ្នាដោយក្នុងនោះរួមមាន អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ដើម្បីធានានូវការអនុវត្តអំណាចទាំងបី(០៣) នេះឱ្យមានភាពត្រឹមត្រូវ និងមានតុល្យភាព ដោយមិនមានការរំលោភអំណាចគ្នាទៅវិញទៅមក គេមានគោលការណ៍នៃការត្រួតពិនិត្យក្នុងការអនុវត្តអំណាច ដោយធ្វើយ៉ាងណាឱ្យមានតុល្យភាពរវាងគ្នានឹងគ្នា។ ហើយចំពោះគោលការណ៍តាមដានការត្រួតពិនិត្យនេះដែរ គឺធ្វើឡើងតាមរយៈ៖ ទីមួយ ការត្រួតពិនិត្យដោយសភាតាមរយៈការចោទសំណួរចំពោះសមាជិករាជរដ្ឋាភិបាល និងអាចកោះអញ្ជើញសមាជិករាជរដ្ឋាភិបាលមកឆ្លើយបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន និងព្រឹទ្ធសភាតាមរយៈតាមដានត្រួតពិនិត្យការងារ និងការអនុវត្តគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាល ជាពិសេសត្រួតពិនិត្យការប្រើប្រាស់ថវិកាជាតិរបស់រាជរដ្ឋាភិបាល។ ដោយឡែកទីពីរ ការត្រួតពិនិត្យដោយតុលាការ ដែលធ្វើឡើងចំពោះបញ្ហាដែលទាក់ទងនឹងឧបាស្រ័យពីបទរំលោភអំណាច និងឧបាស្រ័យវិវាទ ពេញទី និងទីបី ក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពតាមរយៈមធ្យោបាយចំនួនពីរ(០២) របៀបរួមមាន៖ ការត្រួតពិនិត្យជាអាទិកាល និងការត្រួតពិនិត្យជាបច្ឆាកាល។

អាស្រ័យហេតុដូច្នេះ ផ្អែកលើការបកស្រាយខាងលើ និងដោយឈរលើមូលដ្ឋានទ្រឹស្ដី ដែលមានការធានានូវគោលការណ៍នៃការបែងចែកអំណាច និងការត្រួតពិនិត្យនៃការអនុវត្តអំណាច យើងអាចធ្វើការសន្និដ្ឋានបានថា ការបែងចែកអំណាចតាមរយៈរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ គឺពិតជាមានសារៈសំខាន់ណាស់ ព្រោះរដ្ឋធម្មនុញ្ញជាច្បាប់គ្រឹះដ៏សំខាន់សម្រាប់ដំណើរការដឹកនាំប្រទេស ការគ្រប់គ្រងរដ្ឋ ការអនុវត្តអំណាចរបស់រដ្ឋ។ តាមរយៈរដ្ឋធម្មនុញ្ញនេះដែរ បានបង្ហាញឱ្យឃើញថា ព្រះរាជាណាចក្រកម្ពុជាពិតជាប្រទេសដែលប្រកាន់នូវប្រជាធិបតេយ្យពិតប្រាកដមែន។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, ព្រះរាជក្រមចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ច្បាប់រដ្ឋធម្មនុញ្ញបន្ថែមកម្ពុជាឆ្នាំ២០០៤ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១, ០៨ កក្កដា ២០០៤
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា, ព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០, ២១ កក្កដា ២០១៧
- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ, ព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥, ៣១ សីហា ឆ្នាំ២០០៦
- បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២, ២៨ មិថុនា ២០១៨
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤។
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, ព្រះរាជក្រមលេខនស/រកម/០៤៩៨/០៦, ០៨ មេសា ១៩៩៨
- វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, ព្រះរាជក្រមលេខនស/រកម/០១០៧/០០៥, ៣១ មករា ២០០៧
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ព្រះរាជក្រមលេខ នស/០៣២៣/០០១ ១០ មីនា ២០២៣
- ក្រមនីតិវិធីព្រហ្មទណ្ឌ,ព្រះរាជក្រមលេខ នស/រកត/០៨០៧/០២៤, ១០ សីហា ២០០៧


## សៀវភៅ និងស្នាដៃនិពន្ធផ្សេងៗទៀត


- សាយ បូរី, *នីតិរដ្ឋបាលទូទៅ* (២០០៦)
- ឈុន ណារ៉េត, *សេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ រោងពុម្ពដារ៉ា, ២០១៦)
- យូ តូនី, *មេរៀននីតិរដ្ឋធម្មនុញ្ញ* (២០១៨)
- សុខ ចិន្តា និងសុខ យ៉ាន, *នីតិរដ្ឋធម្មនុញ្ញ* (២០២១)
- ហៀង សាង, *នីតិរដ្ឋបាលទូទៅ*(២០២១)
- ឥន យឿន, *វិវាទរដ្ឋបាល* (២០១៦)
- ឥន យឿន, *មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់* (២០១៨)
- ឥន យឿន, *ទាក់ទងនឹងវិស័យច្បាប់* (ភ្នំពេញ៖ ក្រុមសៀវភៅ ISB, ២០២១)
- កៅ មុយថង, *រដ្ឋធម្មនុញ្ញកម្ពុជា* (ភ្នំពេញ៖ បណ្ណាគារអង្គរ, ២០០៦)
- កៅ មុយថង, *នីតិរដ្ឋធម្មនុញ្ញ* (២០០៦)
- សុខ យ៉ាន និងម៉ុក ដារ៉ា, *នីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖២០១២)

– ឌី ពុទ្ធារ៉ា, ទ្រឹស្តីរដ្ឋ (២០២២)
– អ៊ុក វណ្ណារ័ត្ន, *ការធ្វើច្បាប់ និងការអនុវត្តច្បាប់នៅកម្ពុជា* (២០០៨)
– ជុំ អ៊ីម, *ស្ថាប័ននយោបាយនៃព្រះរាជាណាចក្រកម្ពុជា* (២០២១)
– អ៊ុន សកក្កដា, *ប្រវត្តិគំនិតនយោបាយ* (ភ្នំពេញ៖ ២០២០)
– ម៉ុក ដារ៉ា, *នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប* (២០២៤)
– សឿន សោភ័ណ, *នីតិរដ្ឋធម្មនុញ្ញ* (ភ្នំពេញ៖ សុខ ចេង, ២០១៩)
– សឿន សោភ័ណ និងសាឡេះ សុវណ្ណារ៉ា, *នីតិរដ្ឋបាលទូទៅ* (២០២១)
– ម៉ែន វុធ, *នីតិរដ្ឋធម្មនុញ្ញ និងស្ថាប័ននយោបាយ* (២០២០)
– អ៊ុក វណ្ណារ័ត្ន, *ការធ្វើច្បាប់ និងការអនុវត្តច្បាប់នៅកម្ពុជា* (២០០៨)
– ជីង ផេងស្រួយ, *នីតិរដ្ឋធម្មនុញ្ញ* (២០១១)
– សេង ប៊ុនធឿន, *នីតិរដ្ឋធម្មនុញ្ញ និងការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជា* (២០១៥)
– អគ្គលេខាធិការដ្ឋានរដ្ឋសភា ព្រឹទ្ធសភា, *សភាកម្ពុជា* (ភ្នំពេញ៖ ២០២១)
– អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា, *ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា* (ភ្នំពេញ៖ ២០០៧)
– Mlle Beatrice BALIVET, *សៀវភៅសេចក្តីផ្តើមនៃនីតិកម្ពុជា* (២០០៦)

## គេហទំព័រ

– គេហទំព័រ https://www.youtube.com/watch?v=ChHuvw5oer0, ទស្សនាចុងក្រោយនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤
– គេហទំព័រ https://pressocm.gov.kh/archives/94098, ទស្សនាចុងក្រោយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤
– គេហទំព័រ https://nac.org.kh/group-law/118, ទស្សនាចុងក្រោយនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៤

# ពន្យល់ពាក្យ

- **កូរ៉ុម៖** ចំនួនវត្តមានចាំបាច់នៃសមាជិក ដែលមានសិទ្ធិសម្រេចដើម្បីឱ្យការប្រជុំ ឬមហាសន្និបាតរបស់បុគ្គលមានសុពលភាព។
- **ការិយបរិច្ឆេទ៖** ជាការកំណត់ ឬកម្រិតនៃកិច្ចការដែលត្រូវធ្វើ។
- **គណៈរដ្ឋមន្ត្រី៖** ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។
- **គតិយុត្តិ៖** តាមគន្លងច្បាប់ ឬដែលទាក់ទងនឹងច្បាប់ ដែលត្រឹមត្រូវតាមច្បាប់។
- **និរាករណ៍៖** លុបចោលលែងឱ្យប្រើប្រាស់ច្បាប់នោះតទៅទៀត ន័យម្យ៉ាងទៀតជាការលុបចោល ឬទុកជាមោឃៈនូវច្បាប់ មានពីមុនមកដែលធ្វើឡើងជាញឹកញាប់ ឬដោយការលុបចោលច្បាប់នោះចោលតាមកិច្ចអនុម័តច្បាប់ថ្មីមួយទៀត។
- **និរន្តរភាព៖** ជាភាពឥតចន្លោះ ភាពឥតស្រាក ភាពដែលមានជានិច្ច សេចក្ដីដែលកើតមាន ឥតឈប់ឈរ។
- **នីត្យានុកូលភាព៖** ជាការកំណត់នូវភាពពេញលក្ខណៈច្បាប់របស់រដ្ឋបាលសាធារណៈនៅក្នុងការប្រើប្រយោជន៍ទូទៅ។
- **បទដ្ឋាននិយ័តកម្ម៖** ជាកម្មភាពដែលធ្វើឱ្យមានដំណើរការយ៉ាងទៀតទាត់នៅក្នុងទំនាក់ទំនងសង្គម។
- **សភាធម្មនុញ្ញ៖** ត្រូវបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋដែលមានតួនាទីបង្កើតរដ្ឋធម្មនុញ្ញ។
- **សមិទ្ធិ៖** សេចក្ដីសម្រេច សេចក្ដីកើតការ ការសម្រេចប្រយោជន៍ដ៏ស្ដុកស្ដម្ភ លទ្ធផលដែលសម្រេចបានពិតៗ។
- **សេចក្ដីថ្លែងហេតុ៖** មានខ្លឹមសារពន្យល់ពីគោលបំណងនៃសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ព្រមទាំងមូលហេតុនៃការតំរូវឱ្យអនុម័តច្បាប់នោះ។
- **អនុប្បវាទ៖** មិនគាំទ្រ និងមិនប្រឆាំងដោយនៅស្ងៀម។
- **អព្យាក្រឹត៖** នៅចំណុចកណ្ដាលមិននៅខាងបក្សសម្ព័ន្ធណាមួយ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធជារូបភាព

- **ឧបសម្ព័ន្ធទី១** ៖ និមិត្តសញ្ញា  ទីតាំង សមាជិកព្រឹទ្ធសភា
- **ឧបសម្ព័ន្ធទី២** ៖ និមិត្តសញ្ញា  ទីតាំង សមាជិករដ្ឋសភា
- **ឧបសម្ព័ន្ធទី៣** ៖ និមិត្តសញ្ញា ទីតាំង សមាជិករាជរដ្ឋាភិបាល
- **ឧបសម្ព័ន្ធទី៤** ៖ និមិត្តសញ្ញា ទីតាំង តុលាការ
- **ឧបសម្ព័ន្ធទី៥** ៖ និមិត្តសញ្ញា ទីតាំង ក្រុមប្រឹក្សាធម្មនុញ្ញ

## ២. ឧបសម្ព័ន្ធជាលិខិតបទដ្ឋានគតិយុត្ត

- **ឧបសម្ព័ន្ធទី១** ៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- **ឧបសម្ព័ន្ធទី២** ៖ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
- **ឧបសម្ព័ន្ធទី៣** ៖ បទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- **ឧបសម្ព័ន្ធទី៤** ៖ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- **ឧបសម្ព័ន្ធទី៥** ៖ ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ
- **ឧបសម្ព័ន្ធទី៦** ៖ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

# ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១** ៖ និមិត្តសញ្ញា សមាជិកព្រឹទ្ធសភា

***រូបភាពទី១ ៖*** *និមិត្តសញ្ញា តំណាងស្ថាប័នព្រឹទ្ធសភា*




***រូបភាពទី២ ៖*** *ស្ថាប័នព្រឹទ្ធសភា ទីតាំង វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ*




រូបភាពទី៣ ៖ *ការបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៥ នាថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤*



រូបភាពទី៤ ៖ *ក្រោយការបើកសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី៥ នាថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤*




រូបភាពទី៥ ៖ *ការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ ព្រឹទ្ធសភានីតិកាលទី៥*

រូបភាពទី៦,៧,៨ ៖ *លទ្ធផលបោះឆ្នោតជ្រើសរើសសមាសភាព ប្រធាន អនុប្រធានទី១ អនុប្រធានទី២ ព្រឹទ្ធសភានីតិកាលទី៥*



រូបភាពទី៦៖ *ប្រធាន*



រូបភាពទី៧ ៖ *អនុប្រធានទី១*



រូបភាពទី៨ ៖ *អនុប្រធានទី២*




រូបភាពទី៩ ៖ *សមាសភាព ប្រធាន អនុប្រធានទី១ អនុប្រធានទី២ ព្រឹទ្ធសភានីតិកាលទី៥*





រូបភាពទី១០ ៖ *ការសច្ចាប្រណិធានរបស់សមាជិកព្រឹទ្ធសភា ក្នុងព្រះបរមរាជវាំង*

**ឧបសម្ព័ន្ធទី២** ៖ និមិត្តសញ្ញា សមាជិករដ្ឋសភា



*រូបភាពទី១ ៖ និមិត្តសញ្ញា តំណាងស្ថាប័នរដ្ឋសភា*




*រូបភាពទី២ ៖ ស្ថាប័នរដ្ឋសភា មានទីតាំង វិថីរដ្ឋសភា, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, រាជធានីភ្នំពេញ*




**រូបភាពទី៣ ៖** *ការបើកសម័យប្រជុំដំបូងរដ្ឋសភា នីតិកាលទី៧ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣*




**រូបភាពទី៤៖** *ក្រោយការបើកសម័យប្រជុំដំបូងរដ្ឋសភា នីតិកាលទី៧ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣*





**រូបភាពទី៥,៦ ៖** *ការសច្ចាប្រណិធានរបស់សមាជិករដ្ឋសភា ក្នុងព្រះបរមរាជវាំង*




*រូបភាពទី៧ ៖ សម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ ក្រោមអធិបតីភាព* ***សម្តេចអគ្គមហាពញាចក្រី ហេង សំរិន*** *ព្រឹទ្ធសមាជិករដ្ឋសភា និងជាប្រធានបណ្តោះអាសន្ន នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣*



*រូបភាពទី៨ ៖ ការបោះឆ្នោតលើបញ្ជីរាយនាមសមាសភាពជាកញ្ចប់ ប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តដល់សមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៧*






*រូបភាពទី៩,១០ ៖ សមាសភាព ប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា*

## **ឧបសម្ព័ន្ធទី៣** ៖ និមិត្តសញ្ញា សមាជិករាជរដ្ឋាភិបាល



*រូបភាពទី១ ៖ និមិត្តសញ្ញា តំណាងស្ថាប័នរាជរដ្ឋាភិបាល*



*រូបភាពទី២ ៖ ស្ថាប័នរាជរដ្ឋាភិបាល មានទីតាំង Friendship Building, 41 មហាវិថី សហពន្ធ័រុស្ស៊ី (១១០), រាជធា*





*រូបភាពទី៣,៤ ៖ ការសច្ចាប្រណិធានរបស់សមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៧ ក្នុងព្រះបរមរាជវាំង*



*រូបភាពទី៥ ៖ ការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដំបូង នីតិកាលទី៧ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣*




*រូបភាពទី៥ ៖ ការប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី*

**ឧបសម្ព័ន្ធទី៤** ៖ និមិត្តសញ្ញា ទីតាំង តុលាការ



***រូបភាពទី១ ៖** និមិត្តសញ្ញា តំណាងស្ថាប័នតុលាការ*



***រូបភាពទី២** ៖ ស្ថាប័នតុលាការកំពូល មានទីតាំង មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, រាជធានី*



**រូបភាពទី៣ ៖** *សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ភ្នំពេញ មានទីតាំង វិថីលោកតាក្រមហាក ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ*



**រូបភាពទី៤ ៖** *សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ មានទីតាំង ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ*



**រូបភាពទី៥ ៖** *សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ មានទីតាំង ភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ*



**រូបភាពទី៦ ៖** *សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង មានទីតាំង ផ្លូវលេខ៥៧ ភូមិចំការឫស្សី សង្កាត់ព្រែកព្រះស្ដេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង*



**រូបភាពទី៧ ៖** *សាលាដំបូងរាជធានីភ្នំពេញ មានទីតាំង វិថីលោកតាក្រមហាក ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ។ សាលាដំបូងមាននៅតាមបណ្ដារាជធានីខេត្ត នីមួយៗនៃព្រះរាជាណាចក្រកម្ពុជា។*



**រូបភាពទី៨ ៖** *តុលាការយោធា មានទីតាំង ផ្លូវ៦២០ ភូមិដំណាក់ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ*

**ឧបសម្ព័ន្ធទី៥ ៖** និមិត្តសញ្ញា ទីតាំង ក្រុមប្រឹក្សាធម្មនុញ្ញ

*រូបភាពទី១ ៖ និមិត្តសញ្ញា តំណាងស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញ*




*រូបភាពទី២ ៖ ក្រុមប្រឹក្សាធម្មនុញ្ញ មានទីតាំង អគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ*




*រូបភាពទី៣ ៖ សកម្មភាពប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ*

# ឧបសម្ព័ន្ធគតិយុត្ត

**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ**

ទូរស័ព្ទ/ទូរសារ : (+៨៥៥) ២៣ ៧២៦ ០៣១

: (+៨៥៥) ២៣ ៧២០ ៩១៣

អ៊ីម៉ែល : info@ccc.gov.kh

គេហទំព័រ : www.ccc.gov.kh

# ព្រះរាជក្រម

នស/រកម/០៦១៨/០១៧

យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ក្រសួងមុខងារសាធារណៈ រដ្ឋបាល
ចូល លេខ: ៥០៥៦
ទទួលថ្ងៃទី ០៥ ខែ ០៧ ឆ្នាំ ១៨
ម៉ោង ១០:៣៣

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្ដីសម្រេចលេខ ១៩៤/០០៦/២០១៨ កបធ.ច ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្ដីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ
# នៃគណៈរដ្ឋមន្ត្រី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងធានាប្រសិទ្ធភាពការងាររបស់គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអង្គការនីតិប្រតិបត្តិដូចបានបញ្ញត្តនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២ .-**

ច្បាប់នេះមានគោលដៅកំណត់អំពីសមាសភាព សមត្ថកិច្ច និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រីដែលជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តទៅលើអង្គការនីតិប្រតិបត្តិ ។

# ជំពូកទី ២
## សមត្ថកិច្ច និងសមាសភាពគណៈរដ្ឋមន្ត្រី

**មាត្រា៤ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការនីតិប្រតិបត្តិ មានសមត្ថកិច្ចកំណត់និងអនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ ។ រាជរដ្ឋាភិបាលធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់អង្គការនីតិប្បញ្ញត្តិនិងអង្គការតុលាការ ។

**មាត្រា៥ .-**

រាជរដ្ឋាភិបាលដឹកនាំកិច្ចការទូទៅរបស់រដ្ឋស្របតាមកម្មវិធីនយោបាយរបស់ខ្លួន ។

**មាត្រា៦ .-**

រាជរដ្ឋាភិបាលត្រូវការពារនីត្យានុកូលភាព ធានាសណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

**មាត្រា៧ .-**

រាជរដ្ឋាភិបាលគ្រប់គ្រង ដឹកនាំ បញ្ជា ប្រើប្រាស់រដ្ឋបាលសាធារណៈគ្រប់ថ្នាក់ រួមទាំងកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងកម្លាំងប្រដាប់អាវុធផ្សេងៗទៀត ក្នុងការធ្វើសកម្មភាពរបស់ខ្លួន ។

**មាត្រា៨ .-**

សមាសភាពនៃរាជរដ្ឋាភិបាលមាន ៖

- នាយករដ្ឋមន្ត្រី
- ឧបនាយករដ្ឋមន្ត្រី
- ទេសរដ្ឋមន្ត្រី
- រដ្ឋមន្ត្រី ។

**មាត្រា៩ .‒**

នាយករដ្ឋមន្ត្រីជាសមាជិករដ្ឋសភា ។ សមាជិករាជរដ្ឋាភិបាលឯទៀតអាចជ្រើសរើសយកក្នុងចំណោមសមាជិករដ្ឋសភា ឬក្រៅសមាជិករដ្ឋសភា ប៉ុន្តែត្រូវជាសមាជិកគណបក្សមានតំណាងនៅក្នុងរដ្ឋសភា ។ សមាជិករាជរដ្ឋាភិបាលទាំងអស់ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយពីរដ្ឋសភាបានបោះឆ្នោតទុកចិត្ត ។

**មាត្រា១០ .‒**

មុខងារនៃសមាជិករាជរដ្ឋាភិបាលមានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈ ការធ្វើអាជីវកម្មគ្រប់ប្រភេទ ឬការកាន់មុខតំណែងជាថ្នាក់ដឹកនាំ ឬគណៈគ្រប់គ្រង ឬសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនសហគ្រាស ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ។

**មាត្រា១១ .‒**

នៅពេលផុតនីតិកាលរបស់រដ្ឋសភាឬពេលផ្លាស់ប្តូររាជរដ្ឋាភិបាល រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង ។

**មាត្រា១២ .‒**

នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលនៅក្នុងមុខតំណែង ត្រូវទទួលបានប្រាក់បំណាច់មុខងារក្នុងការបំពេញភារកិច្ចដែលកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣

## គណៈរដ្ឋមន្ត្រី សមត្ថកិច្ចរបស់នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល

**មាត្រា១៣ .‒**

គណៈរដ្ឋមន្ត្រីទទួលខុសត្រូវរួមចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅ និងសកម្មភាពរបស់រាជរដ្ឋាភិបាល ។

នាយករដ្ឋមន្ត្រី ជាប្រមុខរាជរដ្ឋាភិបាល ដឹកនាំ បញ្ជារាល់សកម្មភាពការងាររបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ។

**មាត្រា១៤ .‒**

នាយករដ្ឋមន្ត្រីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី ។

អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រីមានអង្គប្រជុំធំ និងអង្គប្រជុំពិនិត្យស្រាវជ្រាវ ។

រាល់អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី ត្រូវមានកំណត់ហេតុ ។

**មាត្រា១៥ .‒**

អង្គប្រជុំធំ គឺជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាល ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។

នាយករដ្ឋមន្ត្រីអាចអញ្ជើញអ្នកពាក់ព័ន្ធនានាចូលរួមក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី តាមការចាំបាច់ ។

នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

**មាត្រា១៦ .—**

នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិជូនសមាជិករាជរដ្ឋាភិបាលណាម្នាក់កោះប្រជុំនិងធ្វើជាអធិបតីនៃអង្គប្រជុំអន្តរក្រសួង ប៉ុន្តែអង្គប្រជុំនេះគ្មានសិទ្ធិសម្រេចកិច្ចការតាងនាមរាជរដ្ឋាភិបាលឡើយ ។

**មាត្រា១៧ .—**

នាយករដ្ឋមន្ត្រីដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ការពារជាតិ សន្តិសុខជាតិ និងវិស័យផ្សេងទៀតដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនណាម្នាក់ជាអ្នកចរចា និងចុះហត្ថលេខា ។

បែបបទ និងនីតិវិធីនៃការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំងនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១៨ .—**

នាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា និងសារាចររបស់រាជរដ្ឋាភិបាល ។ លិខិតបទដ្ឋានគតិយុត្តនានាដែលមានអានុភាពទូទៅរបស់រាជរដ្ឋាភិបាល ត្រូវចុះក្នុងរាជកិច្ច ។

**មាត្រា១៩ .—**

នាយករដ្ឋមន្ត្រីមានសិទ្ធិស្នើសុំរដ្ឋសភា ដើម្បីកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។

នាយករដ្ឋមន្ត្រីលើកសំណើជូនរដ្ឋសភា ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងច្បាប់ ។

**មាត្រា២០ .—**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ ដើម្បីបញ្ចប់មុខតំណែងសមាជិករាជរដ្ឋាភិបាលដោយព្រះរាជក្រឹត្យ ។

**មាត្រា២១ .—**

នាយករដ្ឋមន្ត្រីលើកសំណើផ្លាស់ប្តូរ និងជំនួសសមាជិករាជរដ្ឋាភិបាលជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្ត ។ ក្រោយពីរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយ សមាជិករាជរដ្ឋាភិបាលនោះត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

**មាត្រា២២ .—**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងនៅតាមក្រសួង ស្ថាប័ននានា ដោយព្រះរាជក្រឹត្យ ។

**មាត្រា២៣ .—**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមុខតំណែងមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិដូចខាងក្រោម ៖

- ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ឬមុខតំណែងប្រហាក់ប្រហែល
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ឯកអគ្គរាជទូត ឬមុខតំណែងប្រហាក់ប្រហែល

- ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព
- អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងនាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការនគរបាលជាតិ

មុខតំណែង និងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិចាប់ពីថ្នាក់ឧត្តមសេនីយ៍ឡើង ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ស្របតាមបទប្បញ្ញត្តិជាធរមាន ។

**មាត្រា២៤.–**

នាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិ ដែលមិនមានចែងក្នុងមាត្រា២៣ លើកលែងតែមន្ត្រីដែលមានចែងក្នុងកថាខណ្ឌទី២ មាត្រា៤៦ នៃច្បាប់នេះ ។

**មាត្រា២៥.–**

នាយករដ្ឋមន្ត្រីលើកសំណើផ្តល់គោរមងារដល់ឥស្សរជន វរជន ឬសប្បុរសជនណាមួយ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា២៦.–**

នាយករដ្ឋមន្ត្រីលើកសំណើផ្តល់ ឬអាចផ្តល់គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិ ឥស្សរជន វរជន ឬសប្បុរសជន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា២៧.–**

នាយករដ្ឋមន្ត្រី អាចលើកសំណើផ្តល់ងារកិត្តិយសជាប្រតិភូរាជរដ្ឋាភិបាលដល់ឥស្សរជនណាមួយដោយព្រះរាជក្រឹត្យ ។

**មាត្រា២៨.–**

ក្នុងករណីពិសេស ឬប្រធានសក្តិ នាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជាចំណាយក្រៅពីការកំណត់ក្នុងថវិកាជាតិ ដើម្បីដោះស្រាយកិច្ចការចាំបាច់និងបន្ទាន់ រួចហើយត្រូវរាយការណ៍សុំការអនុម័តពីអង្គការនីតិប្បញ្ញត្តិ ស្របតាមបទប្បញ្ញត្តិជាធរមាន ។

**មាត្រា២៩.–**

ក្នុងពេលដែលនាយករដ្ឋមន្ត្រីអវត្តមាន ឧបនាយករដ្ឋមន្ត្រី១(មួយ)រូប ទទួលការងារជំនួសតាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី។

**មាត្រា៣០.–**

ឧបនាយករដ្ឋមន្ត្រីជាសមាជិករាជរដ្ឋាភិបាល ដែលមានអាសនានុក្រមលើទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ។

ឧបនាយករដ្ឋមន្ត្រីជួយការងារនាយករដ្ឋមន្ត្រី តាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី ។ កិច្ចការដែលពាក់ទងនឹងការដឹកនាំរួមរបស់រាជរដ្ឋាភិបាល បើគ្មានការយល់ព្រមពីនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីគ្មានសិទ្ធិសម្រេចឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៣១ .–**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលដែលដឹកនាំ គ្រប់គ្រងក្រសួង ហៅថា រដ្ឋមន្ត្រី ។

សមាជិករាជរដ្ឋាភិបាលដែលមិនដឹកនាំក្រសួង ត្រូវទទួលភារកិច្ចតាមការកំណត់របស់នាយករដ្ឋមន្ត្រី ។

**មាត្រា៣២ .–**

នាយករដ្ឋមន្ត្រី និងសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល មានខុទ្ទកាល័យរបស់ខ្លួនមួយនិងមានទីប្រឹក្សា ជំនួយការ លេខាធិការដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

**មាត្រា៣៣ .–**

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងៗខ្លួនចំពោះនាយករដ្ឋមន្ត្រីនិងចំពោះរដ្ឋសភាអំពីអំពើដែលខ្លួនបានប្រព្រឹត្ត ។

នាយករដ្ឋមន្ត្រីត្រួតពិនិត្យការងារ សកម្មភាព អំពើប្រព្រឹត្ត និងការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល ហើយមានសិទ្ធិដក និងដាក់ជំនួសសមាជិករាជរដ្ឋាភិបាលតាមបែបបទនិងនីតិវិធីជាធរមាន ។

## ជំពូកទី ៤
## ទីស្តីការគណៈរដ្ឋមន្ត្រី

**មាត្រា៣៤ .–**

ត្រូវបានបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលសម្រាប់សម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី ។

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានតួនាទីគ្រប់គ្រង និងចាត់ចែងការងារទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៣៥ .–**

ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់ ។

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បំពេញភារកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា៣៦ .–**

ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

តួនាទី ភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣៧ .–**

ទីស្តីការគណៈរដ្ឋមន្ត្រីអាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់ ។

**មាត្រា៣៨ .–**

ការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រីត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៥
## ការបង្កើតក្រសួង

**មាត្រា៣៩.–**

ការបង្កើតក្រសួងត្រូវកំណត់ដោយច្បាប់ ។

ក្រសួងនីមួយៗត្រូវអនុវត្តសមត្ថកិច្ចស្របតាមច្បាប់ដែលបង្កើតក្រសួងនោះ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ចាប់ពីថ្នាក់នាយកដ្ឋានឡើង ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាស ។

ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងក្រសួងពីរ ឬច្រើន គណៈរដ្ឋមន្ត្រីត្រូវពិនិត្យ និងសម្រេច ។

**មាត្រា៤០.–**

រដ្ឋមន្ត្រីដឹកនាំការងារក្នុងក្រសួង និងគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក ដែលជាភ្នាក់ងាររដ្ឋបាលនៅក្រោមឱវាទរបស់ខ្លួន ។

**មាត្រា៤១.–**

រដ្ឋមន្ត្រីមានភារកិច្ចដឹកនាំ គ្រប់គ្រងក្រសួង និងអង្គភាពចំណុះក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលកំណត់ក្នុងច្បាប់ ។

**មាត្រា៤២.–**

នៅពេលដែលរដ្ឋមន្ត្រីណាម្នាក់អវត្តមាន ឬមានភារកិច្ចមិនអាចដឹកនាំ គ្រប់គ្រងក្រសួងបានជាបណ្តោះអាសន្ន រដ្ឋលេខាធិការប្រចាំការដូចមានចែងក្នុងមាត្រា៤៤ នៃច្បាប់នេះ ត្រូវទទួលដឹកនាំការងារប្រចាំថ្ងៃរបស់ក្រសួង ក្នុងឋានៈជារដ្ឋមន្ត្រីស្តីទី ហូតដល់មានវត្តមានរដ្ឋមន្ត្រីនៃក្រសួងសាមី ។ ក្នុងករណីដែលរដ្ឋលេខាធិការប្រចាំការ មិនអាចបំពេញតួនាទីជារដ្ឋមន្ត្រីស្តីទីបាន រដ្ឋមន្ត្រីអាចចាត់តាំងរដ្ឋលេខាធិការផ្សេងទៀតជារដ្ឋមន្ត្រីស្តីទី ។

រដ្ឋមន្ត្រីស្តីទីមិនមែនជាសមាជិករាជរដ្ឋាភិបាល ហើយត្រូវអនុវត្តសិទ្ធិអំណាចតាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រី ។

ក្នុងករណីដែលមានកិច្ចការចាំបាច់តាមរដ្ឋធម្មនុញ្ញ និងច្បាប់តម្រូវឱ្យរដ្ឋមន្ត្រីជាអ្នកបំពេញតួនាទីនោះ នាយករដ្ឋមន្ត្រីចាត់តាំងសមាជិករាជរដ្ឋាភិបាលណាម្នាក់ ដើម្បីបំពេញកិច្ចការនោះជំនួសឱ្យរដ្ឋមន្ត្រីដែលអវត្តមាន ។

តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទីត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៤៣.–**

ក្រសួងនីមួយៗមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់ ។

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បំពេញភារកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីនៃក្រសួងសាមី ។

**មាត្រា៤៤.–**

ក្រសួងនីមួយៗមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងសាមី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ក្រសួង ។

តួនាទី ភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ។

**មាត្រា៤៥.–**

ក្រសួងនីមួយៗអាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៤៦ .–**

រដ្ឋមន្ត្រីមានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមាន ចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ និងថ្នាក់វរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ។

រដ្ឋមន្ត្រីមានសិទ្ធិតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ តាមបែបបទនីតិវិធីជាធរមានដោយប្រកាស ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល និងថ្នាក់ក្រោមវរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ។

រាជរដ្ឋាភិបាល អាចចេញអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលរបស់ក្រសួងដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា៤៧ .–**

រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាស សេចក្តីសម្រេច សារាចរ និងសេចក្តីណែនាំ ។

ប្រកាស សេចក្តីសម្រេច សារាចរ ឬសេចក្តីណែនាំរបស់ក្រសួង មិនអាចចែងអំពីកិច្ចការដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងនោះ ហើយក៏ពុំអាចមានទំនាស់ជាមួយលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលឡើយ ។

## ជំពូកទី ៦

## ការបង្កើតស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា

**មាត្រា៤៨ .–**

រាជរដ្ឋាភិបាលអាចលើកសំណើបង្កើត ឬអាចបង្កើតស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា តាមការចាំបាច់ ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

**មាត្រា៤៩ .–**

ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានាដែលបានបង្កើតឡើង ស្របតាមមាត្រា៤៨ នៃច្បាប់នេះ មិនមានក្របខ័ណ្ឌមន្ត្រីរាជការដោយឡែករបស់ខ្លួនឡើយ ។ មន្ត្រីរាជការដែលបំពេញការងារនៅក្នុងស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា ត្រូវជ្រើសយកពីក្របខ័ណ្ឌមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី និង/ឬក្រសួងពាក់ព័ន្ធ លើកលែងតែមានកំណត់ក្នុងច្បាប់ដោយឡែក ។

ប្រធានស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា មានសិទ្ធិលើកសំណើតែងតាំង ឬមានសិទ្ធិតែងតាំង ផ្លាស់ប្តូរមន្ត្រីរាជការរបស់ខ្លួន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា ដែលបានបង្កើតឡើង ស្របតាមមាត្រា៤៨ នៃច្បាប់នេះ មានសមត្ថកិច្ចដូចមានកំណត់នៅក្នុងច្បាប់ និង/ឬលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ។

**មាត្រា៥០ .-**

នាយករដ្ឋមន្ត្រីអាចចាត់តាំងសមាជិករាជរដ្ឋាភិបាល១(មួយ)រូប ឱ្យទទួលដឹកនាំ គ្រប់គ្រងស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានាដែលបានបង្កើតឡើងស្របតាមមាត្រា៤៨ នៃច្បាប់នេះ ។

## ជំពូកទី ៧
## រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
## រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា និងជំនួយការ

**មាត្រា៥១ .-**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទីប្រឹក្សា និងជំនួយការដែលមានឋានៈស្មើអគ្គនាយកឡើងទៅ ។

**មាត្រា៥២ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សា និងជំនួយការនាយករដ្ឋមន្ត្រី បំពេញភារកិច្ចតាមការប្រគល់ពីនាយករដ្ឋមន្ត្រី ។

**មាត្រា៥៣ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ មិនមែនជាសមាជិករាជរដ្ឋាភិបាលទេ ហើយក៏មិនមែនជាភ្នាក់ងាររដ្ឋបាលអចិន្ត្រៃយ៍ដែរ ។

នៅពេលណាដែលរាជរដ្ឋាភិបាលចប់អាណត្តិ ឬលាលែង ឬត្រូវបានទម្លាក់ដោយរដ្ឋសភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការ ដូចមានចែងក្នុងមាត្រា៣២ មាត្រា៣៧ មាត្រា៤៥ និងមាត្រា៥២ នៃច្បាប់នេះ ក៏ត្រូវអស់តំណែងដែរ ។

**មាត្រា៥៤ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការនៅក្នុងមុខតំណែង ទទួលបានប្រាក់បំណាច់មុខងារក្នុងការបំពេញភារកិច្ច ។

ប្រាក់បំណាច់មុខងារនៃរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា៥៥ .-**

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៣

ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មី មកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៥៦ ._**

ច្បាប់នេះត្រូវយកទៅអនុវត្តចាប់ពីនីតិកាលទី៦ នៃរដ្ឋសភាតទៅ ។

**មាត្រា៥៧ ._**

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១៣/០១២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ និងច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា៥៨ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥៩ ._**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨

ពរណ.១៨០៦.៦៤១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ហត្ថលេខា**
**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ហត្ថលេខា**
**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

លេខ:៦៤១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ២រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

រដ្ឋសភា
ចូល
លេខ ៤៣៤៧
ថ្ងៃទី ២៣/៧ ឆ្នាំ២០១៤ ម៉ោង ៥:៣០
បញ្ជូនទៅ ......

# ព្រះរាជក្រម

នស/រកម/០៧១៤/០១៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៨៩/០០៣/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការរៀបចំអង្គការតុលាការ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

## មាត្រា ១.—

ច្បាប់នេះមានគោលបំណង៖

- ធានាឯករាជ្យនៃអំណាចតុលាការ
- ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ
- ធានាឲ្យមានកិច្ចដំណើរការល្អរបស់អង្គការតុលាការ និងអង្គការអយ្យការ
- លើកកម្ពស់សេវាសាធារណៈឲ្យមានប្រសិទ្ធភាព និងឆាប់រហ័ស
- ធានាក្នុងការផ្ដល់យុត្តិធម៌លើរឿងក្ដីគ្រប់ប្រភេទ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹងសុវត្ថិភាពសង្គម ។

## មាត្រា ២.—

ច្បាប់នេះមានគោលដៅ៖

- កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការតុលាការគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់ដែលជាសាលាជម្រះក្ដីនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអយ្យការអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា
- កំណត់អំពីសមត្ថកិច្ចរបស់តុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ទៅតាមជំនាញ
- រៀបចំការងារគ្រប់គ្រង ការងាររដ្ឋបាល និងដំណើរការប្រព្រឹត្តទៅរបស់តុលាការ ។

## មាត្រា ៣.—

សាលាជម្រះក្ដីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖

- សាលាដំបូង
- សាលាឧទ្ធរណ៍
- តុលាការកំពូល ។

សាលាដំបូង ជាសាលាជម្រះក្ដីជាន់ទាប ។ សាលាឧទ្ធរណ៍ និងតុលាការកំពូល ជាសាលាជម្រះក្ដីជាន់ខ្ពស់ ។

យោងតាមសេចក្ដីត្រូវការចាំបាច់ជាក់ស្ដែង ការបង្កើតសាលាជម្រះក្ដីណាមួយ ឬសាលាជម្រះក្ដីវិសាមញ្ញត្រូវធ្វើឡើងដោយច្បាប់ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ៤.-**

សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ អនុវត្តអំណាចតុលាការ ដែលគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

**មាត្រា ៥.-**

សាលាជម្រះក្តីជាន់ទាបត្រូវបែងចែកជាតុលាការជំនាញ ។ ការបង្កើត ការលុបចោល និងការកែប្រែតុលាការជំនាញត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ប្រធានសាលាដំបូង មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើប្រធានតុលាការជំនាញទាំងអស់នៃសាលាដំបូងនោះ ។ ប្រធានតុលាការជំនាញនីមួយៗ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើចៅក្រមដែលជាសមាជិក ។ ប្រធានសាលាដំបូងមិនអាចធ្វើជាប្រធានតុលាការជំនាញណាមួយបានឡើយ ។ ប្រធានតុលាការជំនាញនីមួយៗ អាចធ្វើជាប្រធានតុលាការជំនាញបានតែមួយគត់នៃសាលាដំបូងនោះ ។

សាលាជម្រះក្តីជាន់ខ្ពស់ត្រូវបែងចែកជាសភាជំនាញ ។ ការបង្កើត ការលុបចោល និងការកែប្រែសភាជំនាញ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ប្រធានសាលាជម្រះក្តីជាន់ខ្ពស់ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើប្រធានសភាជំនាញទាំងអស់នៃសាលាជម្រះក្តីជាន់ខ្ពស់នោះ ។ ប្រធានសភាជំនាញនីមួយៗ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើចៅក្រមដែលជាសមាជិក ។ ប្រធានសាលាជម្រះក្តីជាន់ខ្ពស់មិនអាចធ្វើជាប្រធានសភាជំនាញណាមួយបានឡើយ ។ ប្រធានសភាជំនាញនីមួយៗ អាចធ្វើជាប្រធានសភាជំនាញបានតែមួយគត់នៃសាលាជម្រះក្តីជាន់ខ្ពស់នោះ ។

**មាត្រា ៦.-**

មានតែចៅក្រមទេ ដែលមានសិទ្ធិជម្រះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយឯករាជ្យ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្តនិងសម្បជញ្ញៈរបស់ខ្លួន ។

ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែសាលាជម្រះក្តីប៉ុណ្ណោះ ទើបមានអំណាចកាត់សេចក្តី និងចេញសេចក្តីសម្រេចរបស់តុលាការបាន ។

**មាត្រា ៧.-**

សវនាការត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែសាធារណភាពនេះអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់ល្អ ឬមានបទប្បញ្ញត្តិពិសេសក្នុងច្បាប់ចែងផ្សេងពីនេះ ។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

នៅគ្រប់ករណីទាំងអស់ សាលក្រម និងសាលដីកាតុលាការ ត្រូវប្រកាសនៅក្នុងសាលសវនាការដែលបើកជាសាធារណៈ ។

ការពិភាក្សាសម្រេចសេចក្តីរបស់អង្គជំនុំជម្រះត្រូវធ្វើជាសម្ងាត់ ។

លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ ការប្រកាសសាលក្រម ឬសាលដីការបស់តុលាការត្រូវធ្វើឡើងដោយប្រធានអង្គជំនុំជម្រះ ឬចៅក្រមមួយរូបក្នុងចំណោមចៅក្រមដែលជាសមាសភាពនៃអង្គជំនុំជម្រះ ។

គ្រប់សាលក្រម និងសាលដីកាតុលាការ ត្រូវតែមានសំអាងហេតុ ។

លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ សាលក្រម និងសាលដីកា ត្រូវចុះហត្ថលេខាដោយប្រធានអង្គជំនុំជម្រះ និងចុះហត្ថលេខាអមដោយក្រឡាបញ្ជីនៃសវនាការ ។

## មាត្រា ៨.-

នៅអមសាលាដំបូង ត្រូវមានអង្គការអយ្យការមួយ ហៅថា អយ្យការអមសាលាដំបូង ។

នៅអមសាលាឧទ្ធរណ៍ ត្រូវមានអង្គការអយ្យការមួយហៅថាមហាអយ្យការអមសាលាឧទ្ធរណ៍ ។

នៅអមតុលាការកំពូល ត្រូវមានអង្គការអយ្យការមួយ ហៅថា មហាអយ្យការអមតុលាការកំពូល ។

តំណាងអង្គការអយ្យការ ត្រូវមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីផ្សេងៗទៀតដែលច្បាប់កំណត់ ។

## មាត្រា ៩.-

នៅគ្រប់អង្គការតុលាការ និងអង្គការអយ្យការគ្រប់ជាន់ថ្នាក់ មានក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលព្រមទាំងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ជាជំនួយការតាមការចាំបាច់ ។

ក្រឡាបញ្ជីជួយចៅក្រម និងព្រះរាជអាជ្ញានៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ និង អយ្យការ ។

តួនាទី និងមុខងាររបស់ក្រឡាបញ្ជី ត្រូវកំណត់ក្នុងលក្ខន្តិកៈក្រឡាបញ្ជី ។

បែបបទ និងលក្ខខណ្ឌនៃការជ្រើសរើសមន្ត្រីជំនាញផ្នែកច្បាប់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ១០.-

នៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ មានអង្គភាពរដ្ឋបាលមួយ ដែលស្ថិតនៅក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌ សម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការ។

នៅថ្នាក់សាលាដំបូង អង្គភាពរដ្ឋបាលនេះ ហៅថា លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមានឋានៈស្មើនឹងនាយកដ្ឋាន ។

នៅថ្នាក់សាលាឧទ្ធរណ៍ អង្គភាពរដ្ឋបាលនេះ ហៅថា អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍មានឋានៈស្មើនឹងអគ្គនាយកដ្ឋាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

នៅថ្នាក់តុលាការកំពូល អង្គភាពរដ្ឋបាលនេះ ហៅថា អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល មានថ្នាក់ស្មើនឹងអគ្គនាយកដ្ឋាន ។

**មាត្រា ១១.-**

ក្រសួងយុត្តិធម៌ មានសិទ្ធិត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់ ដោយមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការមួយជាសេនាធិការ ។ ក្រសួងយុត្តិធម៌អាចចេញលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំចាំបាច់នានា ដើម្បីធានាដំណើរការប្រព្រឹត្តទៅល្អប្រសើរនៃការគ្រប់គ្រងរដ្ឋបាលតុលាការគ្រប់ជាន់ថ្នាក់ ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចាត់ឲ្យធ្វើអធិការកិច្ចលើបញ្ហាណាមួយជាកំណត់ រួចធ្វើរបាយការណ៍ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីពិនិត្យ និងសម្រេច ។

សាលាជម្រះក្តីជាន់ខ្ពស់ មានសមត្ថកិច្ចត្រួតពិនិត្យលើកិច្ចការជម្រះក្តីរបស់សាលាជម្រះក្តីជាន់ទាប ។ ការត្រួតពិនិត្យនេះ ប្រព្រឹត្តទៅក្នុងក្របខណ្ឌនៃនីតិវិធីឧបាស្រ័យ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

## ជំពូកទី ២
## សាលាដំបូង និងអយ្យការអមសាលាដំបូង
## ផ្នែកទី ១
## សាលាដំបូង
## អនុផ្នែកទី ១
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាដំបូង

**មាត្រា ១២.-**

សាលាដំបូងជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលត្រូវបង្កើតឲ្យមាននៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។ ការដាក់ឲ្យដំណើរការសាលាដំបូងនានា ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

សាលាដំបូងត្រូវបែងចែកជាតុលាការជំនាញ ។ សាលាដំបូង គឺជាសាលាជម្រះក្តីទូទៅដែលមានសមត្ថកិច្ចជំនុំជម្រះក្តីទៅលើរឿងក្តីទាំងអស់ លើកលែងតែរឿងក្តីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីសែាមញ្ញដែលបង្កើតឡើងដោយច្បាប់ដោយឡែក ។

**មាត្រា ១៣.-**

សមាសភាពសាលាដំបូង រួមមាន៖

- ប្រធាន

- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាដំបូង ។

## មាត្រា ១៤.-

សាលាដំបូងនីមួយៗបែងចែកជាតុលាការជំនាញ ដូចខាងក្រោម៖

- តុលាការរដ្ឋប្បវេណី
- តុលាការព្រហ្មទណ្ឌ
- តុលាការពាណិជ្ជកម្ម
- តុលាការការងារ ។

តុលាការជំនាញផ្សេងទៀតរបស់សាលាដំបូង អាចត្រូវបង្កើតឡើង ដោយយោងតាមសេចក្ដីត្រូវការចាំបាច់ ។ ការបង្កើតនេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

តុលាការជំនាញនីមួយៗរបស់សាលាដំបូង ចេញសេចក្ដីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ ។

## មាត្រា ១៥.-

សមាសភាពរបស់តុលាការជំនាញនីមួយៗរួមមាន៖

- ប្រធានតុលាការ
- ចៅក្រម
- ក្រឡាបញ្ជី ។

ប្រធានតុលាការជំនាញនីមួយៗ រួមទាំងចៅក្រម និងក្រឡាបញ្ជី ត្រូវចាត់តាំងដោយប្រធានសាលាដំបូង ។ ដំណើរការរបស់តុលាការជំនាញទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាដំបូងដោយអនុលោមទៅតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

## មាត្រា ១៦.-

តុលាការជំនាញនីមួយៗនៃសាលាដំបូង សម្រេចសេចក្ដីដោយមានចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិស្ដីពីនីតិវិធីជាធរមានផ្សេងទៀត ។ ក្នុងករណីចៅក្រមណាម្នាក់មានធុរៈ ឬស្ថិតក្នុងស្ថានភាពមិនអាចបំពេញកិច្ចការបាន ចៅក្រមនោះអាចជំនួសដោយចៅក្រមនៅក្នុងលំដាប់បន្តបន្ទាប់ ដែលមានកំណត់ក្នុងដីកាសម្រេចប្រចាំឆ្នាំរបស់ប្រធានសាលាដំបូង ។

ក្នុងករណីដែលតុលាការជំនាញណាមួយមិនអាចបើកសវនាការបាន ដោយមានមូលហេតុមកពីខ្វះចៅក្រម ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមពីតុលាការជំនាញផ្សេងមកបំពេញ ។ ប្រសិនបើត្រូវស្នើសុំចៅក្រមមួយរូប ឬច្រើនរូបនៃសាលាដំបូងផ្សេងសម្រាប់បំពេញសមាសភាពនៃតុលាការជំនាញនេះ ប្រធានសាលាដំបូងត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ១៧.-

ប្រធានសាលាដំបូងចាត់វិធានការគ្រប់គ្រងជាចាំបាច់សម្រាប់ដំណើរការនៃសាលាដំបូង ។ ក្នុងករណីប្រធានសាលាដំបូងស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងប្រធានសាលាដំបូងស្ថិតក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអនុប្រធានសាលាដំបូងម្នាក់ ឬបើគ្មានអនុប្រធានទេ អាចចាត់តាំងចៅក្រមណាម្នាក់ឲ្យធ្វើជាប្រធានស្តីទីជំនួសបាន ដើម្បីធានាដំណើរការរបស់សាលាដំបូង រហូតដល់មានការតែងតាំងប្រធានសាលាដំបូងជាផ្លូវការ ។ ការតែងតាំងប្រធានសាលាដំបូង ត្រូវធ្វើក្នុងរយៈពេលខ្លីបំផុត និងយ៉ាងយូរបំផុតមិនឲ្យលើសពី ៣០(សាមសិប) ថ្ងៃ ។

ប្រធានសាលាដំបូងត្រូវចេញដីកាសម្រេចដើម្បីៈ

- ចាត់តាំងអនុប្រធានសាលាដំបូងណាម្នាក់ ឲ្យចាត់ចែងការងារជំនួសខ្លួនបាន ក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានសាលាដំបូង ឲ្យទទួលបន្ទុកធ្វើជាប្រធានតុលាការជំនាញនីមួយៗដោយផ្អែកតាមជំនាញ ឬបទពិសោធន៍ការងារ ។ ក្នុងករណីខ្វះអនុប្រធានប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមណាម្នាក់ ដែលមានឋានន្តរស័ក្តិខ្ពស់ ឬមានបទពិសោធន៍ច្រើនឲ្យធ្វើជាប្រធានតុលាការជំនាញបាន
- កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងតុលាការជំនាញនីមួយៗ និងនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការជំនាញទាំងនេះ ក្នុងករណីដែលចៅក្រមណាម្នាក់អវត្តមាន ឬមានធុរៈ
- ចាត់តាំង និងផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុងតុលាការជំនាញនីមួយៗ តាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង ។

## មាត្រា ១៨.-

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចអនុញ្ញាតឲ្យសាលាដំបូងបើកសវនាការនៅក្រៅទីតាំងស្នាក់ការរបស់ខ្លួនបាន តាមការស្នើសុំពីប្រធានសាលាដំបូង ។

## អនុផ្នែកទី ២
## សមត្ថកិច្ច

### មាត្រា ១៩.-

សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យសាលាជម្រះក្តីផ្សេងទៀត ។

ក្នុងករណីចាំបាច់ ដើម្បីជាប្រយោជន៍សាធារណៈ សុវត្ថិភាព សន្តិសុខសង្គម និងដំណើរការល្អនៃយុត្តិធម៌តុលាការ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចផ្ទេរសមត្ថកិច្ចក្នុងការចាត់ការរឿងក្តីពីសាលាដំបូងមួយទៅសាលាដំបូងមួយទៀតបាន ។

ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងតុលាការជំនាញផ្សេងៗនៅក្នុងសាលាដំបូង ប្រធានសាលាដំបូងត្រូវកោះប្រជុំប្រធានតុលាការជំនាញដែលពាក់ព័ន្ធដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមសំណើរបស់ប្រធានតុលាការជំនាញណាមួយដើម្បីសម្រេចអំពីសមត្ថកិច្ច ។ប្រធានសាលាដំបូងសម្រេចលើវិវាទសមត្ថកិច្ចនេះដោយដីកាសម្រេច ។ ដីកាសម្រេចនេះ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

### មាត្រា ២០.-

តុលាការព្រហ្មទណ្ឌនៃសាលាដំបូងជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌទាំងឡាយ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ លើកលែងតែមានបទប្បញ្ញត្តិច្បាប់ចែងផ្សេងពីនេះ ។

តុលាការព្រហ្មទណ្ឌនៃសាលាដំបូងជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ដោយចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

មន្ទីរស៊ើបសួរនៃសាលាដំបូង គឺជាផ្នែកមួយនៃតុលាការព្រហ្មទណ្ឌ និងមានសមត្ថកិច្ចស៊ើបសួររឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមយ៉ាងតិច ០២ (ពីរ) រូប តាមដីកាសម្រេចឲ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរនៅមន្ទីរស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង ។ ដីកាសម្រេចនេះ ត្រូវកំណត់ផងដែរអំពីលំដាប់លេខរៀងសម្រាប់ការទទួលបំពេញការងារ ។ ក្នុងករណីពុំមានចៅក្រមស៊ើបសួរ ឬខ្វះចៅក្រមស៊ើបសួរប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមនៃតុលាការជំនាញផ្សេង ដើម្បីបំពេញមុខងារស៊ើបសួរបាន ។

ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរអាចបំពេញការងារជាចៅក្រមនៅតុលាការជំនាញផ្សេងទៀតបាន តាមការចាត់តាំងរបស់ប្រធានសាលាដំបូង ។

### មាត្រា ២១.-

តុលាការរដ្ឋប្បវេណីនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីទាំង

ឡាយណាដែលពុំមានបទប្បញ្ញត្តិណាមួយ ប្រគល់សមត្ថកិច្ចទៅឲ្យតុលាការជំនាញផ្សេងទៀត ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

តុលាការរដ្ឋប្បវេណីនៃសាលាដំបូងជំនុំជម្រះរឿងក្តីរដ្ឋប្បវេណីដោយមានចៅក្រមទោល ឬដោយមានក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

## មាត្រា ២២.-

តុលាការពាណិជ្ជកម្មនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម ដោយរួមទាំងរឿងក្តីក្ស័យធនក្នុងរឿងពាណិជ្ជកម្ម ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។

## មាត្រា ២៣.-

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយមានចៅក្រម ០៣ (បី) រូប និងអមដោយទីប្រឹក្សា ០២ (ពីរ) រូប ជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្មក្នុងករណីរឿងក្តីពាណិជ្ជកម្ម ដែលកម្មវត្ថុបណ្តឹងមានតម្លៃចាប់ពី ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ឡើងទៅ ។

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយមានចៅក្រម ០១ (មួយ) រូប និងអមដោយទីប្រឹក្សា ០២ (ពីរ) រូប ជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្មក្នុងករណីរឿងក្តីពាណិជ្ជកម្ម ដែលកម្មវត្ថុបណ្តឹងមានតម្លៃចាប់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ដល់ក្រោម ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ។

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយចៅក្រម ០១ (មួយ) រូប ដោយមិនចាំបាច់មានការចូលរួមពីទីប្រឹក្សាពាណិជ្ជកម្មឡើយក្នុងករណីរឿងក្តីពាណិជ្ជកម្ម ដែលកម្មវត្ថុបណ្តឹងមានតម្លៃក្រោម ១០០.០០០.០០០ (មួយរយលាន) រៀល ។

សាលក្រមរបស់តុលាការពាណិជ្ជកម្មត្រូវសម្រេចដោយចៅក្រម ០១ (មួយ) រូប ឬ ០៣ (បី) រូប យោងទៅតាមកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្ម ។

ទីប្រឹក្សាពាណិជ្ជកម្មមិនបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងតុលាការពាណិជ្ជកម្មនៃសាលាដំបូងឡើយ ។ ទីប្រឹក្សាពាណិជ្ជកម្មត្រូវចូលមកបំពេញមុខងាររបស់ខ្លួននៅសាលាដំបូងតាមការអញ្ជើញរបស់ប្រធានតុលាការពាណិជ្ជកម្មនៃសាលាដំបូង ។

## មាត្រា ២៤.-

របៀបបទនៃការជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ២៥.-**

គុលាការការងារនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះលើរឿងក្តីការងារ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីការងារ ។

**មាត្រា ២៦.-**

តុលាការការងារនៃសាលាដំបូងត្រូវជំនុំជម្រះដោយចៅក្រម ០១ (មួយ) រូប អមដោយទីប្រឹក្សាការងារ ០២ (ពីរ) រូប ដែល ០១ (មួយ) រូបជាកម្មករនិយោជិត និង០១ (មួយ) រូបទៀតជានិយោជក ។

សាលក្រមរបស់តុលាការការងារនៃសាលាដំបូង ត្រូវសម្រេចដោយចៅក្រម ០១(មួយ) រូប ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាការងារ ។

ទីប្រឹក្សាការងារ ពុំបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងតុលាការការងារនៃសាលាដំបូងឡើយ ។ ទីប្រឹក្សាការងារត្រូវចូលរួមបំពេញមុខងាររបស់ខ្លួននៅសាលាដំបូង តាមការអញ្ជើញរបស់ប្រធានតុលាការការងារ ។

**មាត្រា ២៧.-**

តុលាការការងារដែលមានសមត្ថកិច្ច គឺតុលាការការងារនៃសាលាដំបូងនាទីកន្លែងវិវាទការងារ ។

ទោះបីមានការកំណត់សមត្ថកិច្ចដូចកថាខណ្ឌខាងលើក៏ដោយ ក៏កម្មករនិយោជិតអាចប្តឹងទៅសាលាដំបូងតាមការកំណត់ដូចខាងក្រោម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ៖

- នាលំនៅឋានរបស់ខ្លួន ឬ
- នាទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បងរបស់ក្រុមហ៊ុន ឬ
- នាលំនៅឋានរបស់អ្នកតំណាង ឬអ្នកទទួលខុសត្រូវរបស់ក្រុមហ៊ុន ប្រសិនបើគ្មានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បងរបស់ក្រុមហ៊ុនទេ ។

**មាត្រា ២៨.-**

បែបបទនៃការបោះឆ្នោតជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាការងារ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ។

## ផ្នែកទី ២
## អយ្យការអមសាលាដំបូង

**មាត្រា ២៩.-**

សមាសភាពអយ្យការអមសាលាដំបូង រួមមាន៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង ។

**មាត្រា ៣០.-**

អង្គការអយ្យការជាអង្គអវិភាគ ។ អយ្យការមានមុខងារធ្វើបណ្ដឹងអាជ្ញា និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ ។ ព្រះរាជអាជ្ញារង ចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន ព្រះរាជអាជ្ញាត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសបាន ។ ក្នុងករណីដែលព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឲ្យធ្វើជាព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់អយ្យការអមសាលាដំបូងរហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ ។

**មាត្រា ៣១.-**

ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ព្រះរាជអាជ្ញាចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារងទាំងអស់ ។

ព្រះរាជអាជ្ញាមានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ ។ សេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារង ត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្ដីសន្និដ្ឋាននោះទេ ហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្ដីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាមព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្ដង ឲ្យធ្វើជាតំណាងអយ្យការនៅក្នុងសវនាការនៃសាលាដំបូង ។

ប៉ុន្តែ នៅពេលសវនាការ ព្រះរាជអាជ្ញារងអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមគំនិតដែលខ្លួនយល់ឃើញថា ស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននៅពេលសវនាការ ខុសពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

# ផ្នែកទី ៣
# លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

## មាត្រា៣២.–

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង គឺជាសេនាធិការឲ្យសាលាដំបូង និងអយ្យការអមសាលាដំបូងលើៈ

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការ សម្រាប់ជាជំនួយបច្ចេកទេសដល់កម្មវិធីការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- ការងាររៀបចំគម្រោងថវិកាជូនប្រធានសាលាដំបូងនិងព្រះរាជអាជ្ញា ដើម្បីពិនិត្យ និងសម្រេច
- រាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានសាលាដំបូង និងព្រះរាជអាជ្ញា
- ការអនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត
- ការងារទំនាក់ទំនងសាធារណៈ
- ការងារបញ្ជូនសាលក្រមរបស់សាលាដំបូង ជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំ និងបញ្ជូនរបាយការណ៍ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌
- ការងារផ្សេងទៀតដែលប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងប្រគល់ឲ្យ
- អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត ។

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវបែងចែកជាការិយាល័យតាមចំនួនចាំបាច់ជាក់ស្តែង ។ ការិយាល័យដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៣៣.–

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។ ប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។ មន្ត្រីបម្រើការងារនៅលេខាធិការដ្ឋានថ្នាក់ក្រោមប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ប្រធាន និងអនុប្រធានលេខាធិការដ្ឋាន ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។ ប្រធាន និង អនុប្រធានការិយាល័យ ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅលេខាធិការដ្ឋានទាំងអស់ ដោយរួមទាំងប្រធានលេខាធិការដ្ឋានផងត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។

**មាត្រា ៣៤.-**

សន្និបាតរបស់សាលាដំបូង ប្រព្រឹត្តទៅក្រោមអធិបតីភាពនៃប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ដើម្បីបូកសរុបលទ្ធផលការងារកន្លងមក និងកំណត់ទិសដៅការងាររដ្ឋបាលរបស់សាលាដំបូងសម្រាប់ឆ្នាំបន្ទាប់ទៀត ។ របាយការណ៍សន្និបាតរបស់សាលាដំបូងត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌ ។

## ជំពូកទី ៣
## សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
### ផ្នែកទី ១
### សាលាឧទ្ធរណ៍
#### អនុផ្នែកទី ១
#### ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាឧទ្ធរណ៍

**មាត្រា ៣៥.-**

សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្ដីថ្នាក់ទីពីរ ។

សាលាឧទ្ធរណ៍រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់ ។ ការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍តំបន់នីមួយៗ និងការកំណត់ពីសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

**មាត្រា ៣៦.-**

សមាសភាពសាលាឧទ្ធរណ៍រួមមាន៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជីនិង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាឧទ្ធរណ៍ ។

**មាត្រា ៣៧.-**

សាលាឧទ្ធរណ៍មានសភាជំនាញ ដូចខាងក្រោម៖

- សភាព្រហ្មទណ្ឌ
- សភារដ្ឋប្បវេណី
- សភាស៊ើបសួរ
- សភាពាណិជ្ជកម្ម
- សភាការងារ ។

ក្នុងករណីចាំបាច់សភា ជំនាញផ្សេងទៀតនៃសាលាឧទ្ធរណ៍អាចត្រូវបង្កើតឡើង ដោយព្រះរាជក្រឹត្យ ។

សភានីមួយៗ ចេញសេចក្តីសម្រេចដោយស្វ័យភាព ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងនាមសាលាឧទ្ធរណ៍ដែលសភានោះស្ថិតនៅ ។

**មាត្រា ៣៨.-**

សមាសភាពរបស់សភានីមួយៗរួមមាន៖

- ប្រធានសភា
- ចៅក្រម និង
- ក្រឡាបញ្ជី ។

ប្រធានសភានីមួយៗ ត្រូវចាត់តាំងដោយប្រធានសាលាឧទ្ធរណ៍ ។

ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាឧទ្ធរណ៍ ។

**មាត្រា ៣៩.-**

សភានីមួយៗនៃសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយមានចៅក្រម ០៣(បី) រូប ដែល ០១(មួយ) រូបជាប្រធាន ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

រឿងក្តីណាដែលតុលាការកំពូលបានបង្វិលមកវិញ នោះសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះនៅក្នុងសវនាការមួយ ដែលមានចៅក្រម ០៥ (ប្រាំ) រូប ហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះលើកមុន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៤០.-**

ប្រធានសាលាឧទ្ធរណ៍ ចាត់វិធានការគ្រប់គ្រងជាចាំបាច់សម្រាប់ដំណើរការនៃសាលាឧទ្ធរណ៍ ។ ប្រធានសាលាឧទ្ធរណ៍ត្រូវចេញដីកាសម្រេចដើម្បីៈ

- ចាត់តាំងអនុប្រធានសាលាឧទ្ធរណ៍ណាម្នាក់ ឲ្យចាត់ចែងការងារជំនួសខ្លួនបានក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានសាលាឧទ្ធរណ៍ ឲ្យទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗទៅតាមជំនាញ និងបទពិសោធន៍ការងារ ។ ក្នុងករណីខ្វះអនុប្រធានសាលាឧទ្ធរណ៍ ប្រធានសាលាឧទ្ធរណ៍ អាចចាត់តាំងចៅក្រមណាម្នាក់ដែលមានឋានន្តរស័ក្តិខ្ពស់ ឬមានបទពិសោធន៍ការងារច្រើន ឲ្យធ្វើជាប្រធានសភាបាន
- កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃសភានីមួយៗ ក្នុងករណីចៅក្រមណាម្នាក់អវត្តមាន ឬមានធុរៈ
- ចាត់តាំង និងផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុងសភានីមួយៗ តាមការចាំបាច់ជាក់ស្តែង ។

## អនុផ្នែកទី ២
## សមត្ថកិច្ច

**មាត្រា ៤១.-**

សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនលើកលែងតែរឿងក្តីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យតុលាការផ្សេងទៀត ។

**មាត្រា ៤២.-**

សាលាឧទ្ធរណ៍សម្រេចសេចក្តីទាំងអង្គហេតុ និងអង្គច្បាប់ លើរឿងក្តីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៤៣.-**

សភាព្រហ្មទណ្ឌមានសមត្ថកិច្ចជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូង និងរឿងក្តីផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៤៤.-**

សភារដ្ឋប្បវេណីមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីផ្សេងទៀតដែលស្ថិតក្នុងដែន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជាធរមាន ។ សេចក្តីសម្រេចត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី) រូប ដែល ០១ (មួយ) រូប ជាប្រធាន ។

**មាត្រា ៤៥.-**

សភាស៊ើបសួរមានសមត្ថកិច្ចដោះស្រាយលើបណ្តឹងនានាចំពោះកិច្ចស៊ើបសួរ ឬដីកាសម្រេចនានារបស់ចៅក្រមស៊ើបសួរ និងរឿងក្តីផ្សេងទៀតដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។ សេចក្តីសម្រេចរបស់សភាស៊ើបសួរត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី) រូបដែល ០១ (មួយ) រូប ជាប្រធាន ។

**មាត្រា ៤៦.-**

សភាពាណិជ្ជកម្មមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។ សភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះដោយចៅក្រម ០៣ (បី) រូប ដែល ០១(មួយ) រូប ជាប្រធាននិងអមដោយទីប្រឹក្សា ០២ (ពីរ) រូបជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្ម និងមិនមែនជាទីប្រឹក្សាពាណិជ្ជកម្មនៅក្នុងរឿងក្តីតែមួយ ដែលត្រូវបានជំនុំជម្រះដោយសាលាដំបូង និងសាលាឧទ្ធរណ៍ ។ សាលដីការបស់សភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី)រូប ដែល ០១(មួយ)រូប ជាប្រធានក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្ម ។

ទីប្រឹក្សាពាណិជ្ជកម្មមិនបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ឡើយ ។ ទីប្រឹក្សាពាណិជ្ជកម្មត្រូវចូលមកបំពេញមុខងាររបស់ខ្លួនតាមការអញ្ជើញរបស់ប្រធានសភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ប៉ុណ្ណោះ ។

បែបបទនៃការជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៤៧.-**

សភាការងារនៃសាលាឧទ្ធរណ៍ មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូង ក្នុងរឿងក្តីការងារ និងរឿងក្តីផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីការងារ ។ សភាការងារនៃសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះដោយចៅក្រម ០៣ (បី) រូប ដែល ០១(មួយ) រូប ជាប្រធាន និងអមដោយទីប្រឹក្សា ០២ (ពីរ) រូប ដែល ០១ (មួយ) រូប ជាកម្មករនិយោជិត និង ០១ (មួយ) រូប ទៀតជានិយោជក និងមិនមែនជាទីប្រឹក្សាការងារនៅក្នុងរឿងក្តីតែមួយ ដែលត្រូវបានជំនុំជម្រះដោយសាលាដំបូង និង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សាលាឧទ្ធរណ៍ ។ សេចក្តីសម្រេចរបស់សភាការងារនៃសាលាឧទ្ធរណ៍ ត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី) រូប ដែល ០១ (មួយ) រូប ជាប្រធាន ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាការងារ ។

ទីប្រឹក្សាការងារមិនបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភាការងារនៃសាលាឧទ្ធរណ៍ឡើយ ។ ទីប្រឹក្សាការងារត្រូវចូលមកបំពេញមុខងាររបស់ខ្លួន តាមការអញ្ជើញរបស់ប្រធានសភាការងារនៃសាលាឧទ្ធរណ៍ប៉ុណ្ណោះ ។

បែបបទនៃការជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាការងារត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ។

## មាត្រា ៤៨.-

សភារួមក្រុមអាចត្រូវបង្កើតឲ្យមានដំណើរការបាន ដោយដីកាសម្រេចរបស់ប្រធានសាលាឧទ្ធរណ៍ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយ កាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នា នៅចំពោះមុខសភាផ្សេងគ្នានៃសាលាឧទ្ធរណ៍តែមួយ ។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានសាលាឧទ្ធរណ៍ ។

សេចក្តីសម្រេចរបស់សភារួមក្រុម អំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទច្បាប់ មានអំណាចបង្ខំឲ្យសភាទាំងអស់នៃសាលាឧទ្ធរណ៍គោរពតាម ។

កាលបើសភារួមក្រុមត្រូវបង្កើតឡើង សភានេះត្រូវមានសមាសភាពជាចៅក្រមយ៉ាងតិច ០៥ (ប្រាំ) រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ ។ សភារួមក្រុមស្ថិតក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍ ។

ប្រធានសាលាឧទ្ធរណ៍ចេញដីកាសម្រេច ដោយអនុលោមតាមសេចក្តីសម្រេចរបស់សភារួមក្រុម ។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

# ផ្នែកទី ២
# មហាអយ្យការអមសាលាឧទ្ធរណ៍

## មាត្រា ៤៩.-

នៅអមសាលាឧទ្ធរណ៍មានមហាអយ្យការដែលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង

- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## មាត្រា ៥០.-

មុខងាររបស់មហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន ។

ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ស្ថិតក្នុងស្ថានភាពទំនេររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ ឲ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ រហូតដល់មានការតែងតាំងអគ្គព្រះរាជអាជ្ញាជាផ្លូវការ ។

## មាត្រា ៥១.-

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទៅក្នុងការងារផ្សេងៗនៃមហាអយ្យការនិងអង្គជំនុំជម្រះ ។

សេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មិនយល់ព្រមលើសេចក្ដីសន្និដ្ឋាននោះទេ ហើយតំណាងមហាអយ្យការដែលជាអ្នកធ្វើសេចក្ដីសន្និដ្ឋាននោះ នៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្ដងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ ។

ប៉ុន្តែ នៅពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរី តាមការដែលខ្លួនយល់ឃើញថា ស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងមហាអយ្យការដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការ ខុសពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់បាន ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ផ្នែកទី ៣
## អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍

**មាត្រា ៥២.-**

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ គឺជាសេនាធិការឲ្យសាលាឧទ្ធរណ៍ និង មហាអយ្យការអមសាលាឧទ្ធរណ៍លើៈ

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការសម្រាប់ជាជំនួយការបច្ចេកទេសដល់កម្មវិធីការងាររបស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- ការងាររៀបចំគម្រោងថវិកាជូនប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដើម្បីពិនិត្យ និងសម្រេច
- ការអនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត
- របាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ការងារទំនាក់ទំនងសាធារណៈ
- ការងារបញ្ជូនសាលដីការបស់សាលាឧទ្ធរណ៍ជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំ និងបញ្ជូនរបាយការណ៍ ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌
- ការងារផ្សេងទៀតដែលប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ប្រគល់ឲ្យ
- អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត។

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍បែងចែកជានាយកដ្ឋាន ដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៥៣.-**

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ។ អគ្គលេខាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិគ្រោះយោបល់ជាមួយប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ដើម្បីលើកសំណើជូននាយករដ្ឋមន្ត្រី ។ អគ្គលេខាធិការត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ។

អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានថ្នាក់ក្រោមប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។អនុប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន និងអនុប្រធានការិយាល័យត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានទាំងអស់ដោយរួមទាំងអគ្គលេខាធិការផង ត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។

**មាត្រា ៥៤.-**

សន្និបាតរបស់សាលាឧទ្ធរណ៍នីមួយៗ ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍នោះ ដើម្បីបូកសរុបលទ្ធផលការងារកន្លងមក និងកំណត់ទិសដៅការងាររដ្ឋបាលរបស់សាលាឧទ្ធរណ៍សម្រាប់ឆ្នាំបន្ទាប់ទៀត ។ របាយការណ៍សន្និបាតរបស់សាលាឧទ្ធរណ៍ ត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌ ។

## ជំពូកទី ៤
## តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
### ផ្នែកទី ១
### តុលាការកំពូល
#### អនុផ្នែកទី ១
#### ការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការកំពូល

**មាត្រា ៥៥.-**

តុលាការកំពូលមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## មាត្រា ៥៦.-

សមាសភាពតុលាការកំពូលរួមមាន៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅតុលាការកំពូល ។

## មាត្រា ៥៧.-

តុលាការកំពូលមានសភាជំនាញ ដូចខាងក្រោម៖

- សភាព្រហ្មទណ្ឌ
- សភារដ្ឋប្បវេណី
- សភាពាណិជ្ជកម្ម
- សភាការងារ ។

ក្នុងករណីចាំបាច់ សភាជំនាញផ្សេងទៀតរបស់តុលាការកំពូល អាចត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

សភានីមួយៗ ចេញសេចក្ដីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាព ក្នុងនាមតុលាការកំពូល ។

## មាត្រា ៥៨.-

សមាសភាពរបស់សភានីមួយៗរួមមាន៖

- ប្រធានសភា
- ចៅក្រម និង
- ក្រឡាបញ្ជី ។

ប្រធានសភានីមួយៗត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូល ។ ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានតុលាការកំពូល។

## មាត្រា ៥៩.-

សភានីមួយៗនៃតុលាការកំពូលសម្រេចសេចក្ដីដោយចៅក្រម ០៥(ប្រាំ)រូប ដែល ០១ (មួយ) រូបជាប្រធាន ដោយអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីជាធរមាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា ៦០.-

ប្រធានតុលាការកំពូល ចាត់វិធានការគ្រប់គ្រងជាចាំបាច់ក្នុងការប្រព្រឹត្តទៅនៃតុលាការកំពូល និងណែនាំសភាទាំងអស់របស់តុលាការកំពូលឲ្យអនុវត្តច្បាប់ ។

ប្រធានតុលាការកំពូលត្រូវចេញដីកាសម្រេចដើម្បីៈ

- ចាត់តាំងអនុប្រធានតុលាការកំពូលណាម្នាក់ ឲ្យចាត់ចែងការងារជំនួសខ្លួនបានក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានតុលាការកំពូល ឲ្យទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗ ទៅតាមជំនាញ និងបទពិសោធន៍ការងារ ។ ក្នុងករណីខ្វះអនុប្រធាន ប្រធានតុលាការកំពូលអាចចាត់តាំងចៅក្រមណាម្នាក់ឲ្យធ្វើជាប្រធានសភាបាន ។

## អនុផ្នែកទី ២
## សមត្ថកិច្ច

## មាត្រា ៦១.-

តុលាការកំពូល មានសមត្ថកិច្ចដោះស្រាយរឿងក្ដីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់របស់ច្បាប់ ។

## មាត្រា ៦២.-

សភាពេញអង្គត្រូវបង្កើតឲ្យមានដំណើរការ ដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល ដើម្បីជំនុំជម្រះ ជាអាទិ៍ៈ

- លើបណ្ដឹងសាទុក្ខលើកទីពីរចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ស្របតាមនីតិវិធីជាធរមាន
- លើបណ្ដឹងសើរើចំពោះសាលក្រម និងសាលដីកាស្ថាពរ ស្របតាមនីតិវិធីជាធរមាន ។

សភាពេញអង្គក៏អាចត្រូវបង្កើតឲ្យមានដំណើរការផងដែរ ដើម្បីជំនុំជម្រះលើបណ្ដឹងសើរើ ឬបណ្ដឹងជំនុំជម្រះសាជាថ្មី ក្នុងករណីដែលមានការស្នើសុំឲ្យមានការពិនិត្យ និងសម្រេចឡើងវិញចំពោះរឿងក្ដីណាមួយ ពីព្រះមហាក្សត្រដែលជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

សភាពេញអង្គប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ។

សភាពេញអង្គនៃតុលាការកំពូល គឺជាអង្គជំនុំជម្រះដែលចេញសេចក្ដីសម្រេចក្នុងនាមតុលាការកំពូល ។

កាលបើសភាពេញអង្គត្រូវបង្កើតឲ្យមានឡើង សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ១៩ (ប្រាំបួន) រូប ដែលមានចៅក្រមជាតំណាងនៃសភាទាំងអស់របស់តុលាការកំពូល ។

សភាពេញអង្គស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ៦៣.-**

សភារួមក្រុមអាចត្រូវបង្កើតឲ្យមានដំណើរការបាន ដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយកាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នា នៅចំពោះមុខសភាផ្សេងគ្នានៃតុលាការកំពូល ។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ។

សេចក្តីសម្រេចរបស់សភារួមក្រុមអំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទអំពីច្បាប់ មានអំណាចបង្ខំឲ្យសភាទាំងអស់នៃតុលាការកំពូល និងតុលាការថ្នាក់ក្រោមគោរពតាម ។

កាលបើសភារួមក្រុមត្រូវបង្កើតឲ្យមានឡើង សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩ (ប្រាំបួន) រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ ។ សភារួមក្រុមស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ។

ប្រធានតុលាការកំពូលចេញដីកាសម្រេច ដោយអនុលោមតាមសេចក្តីសម្រេចរបស់សភារួមក្រុម ។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទអំពីច្បាប់ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

**មាត្រា ៦៤.-**

សភាព្រហ្មទណ្ឌនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ចំពោះសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៦៥.-**

សភារដ្ឋប្បវេណីនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ចំពោះសាលដីកា និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងរដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ព្រមទាំងលើបណ្តឹងសាទុក្ខចំពោះសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង និងរឿងក្តីផ្សេងទៀតដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

**មាត្រា ៦៦.-**

សភាពាណិជ្ជកម្មនៃតុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលដីកា និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងពាណិជ្ជកម្មរបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។

**មាត្រា ៦៧.-**

សភាការងារនៃតុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលដីកា និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងការងាររបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីការងារ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ផ្នែកទី ២
# មហាអយ្យការអមតុលាការកំពូល

## មាត្រា ៦៨.-

មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល ។

## មាត្រា ៦៩.-

មុខងាររបស់មហាអយ្យការអមតុលាការកំពូល ត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន ។

ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលស្ថិតក្នុងស្ថានភាពទំនេររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ ឲ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់មហាអយ្យការអមតុលាការកំពូល រហូតដល់មានការតែងតាំងអគ្គព្រះរាជអាជ្ញាជាផ្លូវការ ។

## មាត្រា ៧០.-

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទៅក្នុងការងារផ្សេងៗនៃមហាអយ្យការ និងក្នុងអង្គជំនុំជម្រះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយតំណាងមហាអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះ នៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលអាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ ។

ប៉ុន្តែ នៅពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរី តាមការដែលខ្លួនយល់ឃើញថាស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងមហាអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការ ខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

## ផ្នែកទី ៣
## អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

### មាត្រា ៧១.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល គឺជាសេនាធិការឲ្យតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលលើ៖

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការសម្រាប់ជាជំនួយការបច្ចេកទេសដល់កម្មវិធីការងាររបស់តុលាការ
- ការងាររៀបចំគម្រោងថវិកាជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលដើម្បីពិនិត្យ និងសម្រេច
- របាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- ការងារទំនាក់ទំនងសាធារណៈ
- ការងារបញ្ជូនសាលដីការបស់តុលាការកំពូលជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំ និងបញ្ជូនរបាយការណ៍ ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌

- ការងារផ្សេងទៀតដែលប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ប្រគល់ឲ្យ
- អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត ។

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលបែងចែកជានាយកដ្ឋាន ដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៧២.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ។

អគ្គលេខាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីលើកសំណើជូននាយករដ្ឋមន្ត្រី ។ អគ្គលេខាធិការត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ។

អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានថ្នាក់ក្រោមប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ អនុប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន និងអនុប្រធានការិយាល័យ ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានទាំងអស់ដោយរួមទាំងអគ្គលេខាធិការផង ត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។

## មាត្រា ៧៣.-

សន្និបាតរបស់តុលាការកំពូល ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីបូកសរុបលទ្ធផលការងារកន្លងមក និង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

កំណត់ទិសដៅការងាររដ្ឋបាលរបស់តុលាការកំពូលសម្រាប់ឆ្នាំបន្ទាប់ទៀត ។ របាយការណ៍សន្និបាតរបស់តុលាការកំពូល ត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌ ។

## ជំពូកទី ៥
## វិសមិតភាព

**មាត្រា ៧៤.-**

មុខងារធ្វើបណ្តឹងអាជ្ញា មុខងារស៊ើបសួរ និងមុខងារជំនុំជម្រះ ត្រូវបែងចែកដាច់ពីគ្នា ។ ចៅក្រមណាម្នាក់ដែលបានទទួលបន្ទុកចាត់ការរឿងក្តីណាមួយក្នុងឋានៈជាតំណាងអយ្យការ ឬជាចៅក្រមស៊ើបសួររួចហើយមិនអាចជំនុំជម្រះ ឬចូលរួមជំនុំជម្រះរឿងក្តីដែលខ្លួនបានទទួលចាត់ការនោះឡើយ បើពុំដូច្នោះទេ សាលក្រម ឬសាលដីកានឹងត្រូវទុកជាមោឃៈ ។

**មាត្រា ៧៥.-**

ចៅក្រមមិនអាចចូលរួមជំនុំជម្រះរឿងក្តីតែមួយជាមួយគ្នានឹងចៅក្រមម្នាក់ ឬច្រើននាក់ដែលជាសហព័ទ្ធ ឬញាតិលោហិត រហូតដល់ថ្នាក់ទី ៤ (បួន) រាប់ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផងទោះក្នុងឋានៈជាចៅក្រមជំនុំជម្រះក្តី ឬជាតំណាងអយ្យការក្តី ។ គោលការណ៍នេះត្រូវអនុវត្តដូចគ្នាផងដែរសម្រាប់ចៅក្រមនៅសាលាជម្រះក្តីជាន់ខ្ពស់ ចំពោះរឿងក្តីដែលត្រូវបានជំនុំជម្រះដោយចៅក្រមនៅសាលាជម្រះក្តីជាន់ទាបដែលជាសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី ៤ (បួន) រាប់ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ។

**មាត្រា ៧៦.-**

ចៅក្រមទាំងឡាយដែលមានសហព័ទ្ធ ឬញាតិលោហិត រហូតដល់ថ្នាក់ទី៤ (បួន) រាប់ ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ធ្វើជាមេធាវីឲ្យភាគីម្ខាងនៃរឿងក្តីណាមួយ មិនអាចចូលរួមជំនុំជម្រះរឿងក្តីនោះបានឡើយ ។

**មាត្រា ៧៧.-**

ចៅក្រមមិនអាចចូលរួមជំនុំជម្រះរឿងក្តីណាមួយ ដែលមានភាគីម្ខាងជាសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី ៦ (ប្រាំមួយ) រាប់ទាំងថ្នាក់ទី ៦ (ប្រាំមួយ) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

**មាត្រា ៧៨.-**

លើកលែងតែមានបទប្បញ្ញត្តិស្តីពីនីតិវិធីចែងផ្សេងពីនេះ ភាគីទាំងឡាយនៅក្នុងរឿងក្តី និងបុគ្គលដែលមានប្រយោជន៍ក្នុងរឿងក្តី ដោយរួមទាំងតំណាងអយ្យការផង អាចប្តឹងសុំមោឃកម្មចំពោះសាលក្រម ឬសាលដីការបស់តុលាការ ដោយហេតុបំពានវិធានស្តីពីវិសមិតភាពដូចមានចែងក្នុងមាត្រា ៧៤ មាត្រា ៧៥ មាត្រា ៧៦ និងមាត្រា ៧៧ ខាងលើ ។

បណ្តឹងសុំមោឃកម្មនេះ អាចធ្វើបានគ្រប់ពេលវេលា នៅចំពោះមុខតុលាការ នៅក្នុងនីតិវិធីឧបាស្រ័យដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។ បើទោះបីជាសាលក្រមឬសាលដីកានោះបានចូលស្ថាពរហើយក៏ដោយ ក៏បណ្តឹងសុំមោឃកម្ម នៅតែអាចធ្វើឡើងបានដដែលក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃបានដឹងអំពីមូលហេតុដូចមានចែងក្នុងមាត្រា ៧៤ មាត្រា ៧៥ មាត្រា ៧៦ និងមាត្រា ៧៧ ខាងលើក្រោយពេលសាលក្រម ឬសាលដីកាបានចូលជាស្ថាពរ ។ ក្នុងករណីចុងក្រោយនេះ បណ្តឹងសុំមោឃកម្ម ត្រូវដាក់នៅសាលាជម្រះក្តីដែលបានចេញសាលក្រម ឬសាលដីកាស្ថាពរ ប៉ុន្តែ ត្រូវមានសមាសភាពថៅក្រមជំនុំជម្រះផ្សេងដើម្បីពិនិត្យ និងសម្រេចអំពីមោឃកម្មនៃសាលក្រម ឬសាលដីកាស្ថាពរនោះ និងអនុវត្តនីតិវិធីបន្តស្របតាមបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ៦
## ថវិកាសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី

**មាត្រា ៧៩.-**

សាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ ។

ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ជាអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ការគ្រប់គ្រង និងការចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៨០.-**

សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ព្រមទាំងអង្គការអយ្យការនៅអមសាលាជម្រះក្តីទាំងនេះ ដែលត្រូវបានបង្កើតឡើង នៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តដំណើរការរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨១.-**

បទប្បញ្ញត្តិពីមុនពាក់ព័ន្ធនឹងតុលាការយោធា និងអយ្យការអមតុលាការយោធា ព្រមទាំងបទប្បញ្ញត្តិស្តីពីសមត្ថកិច្ច និងនីតិវិធី ដែលអនុវត្តសម្រាប់ដំណើរការរឿងក្តីបទល្មើសយោធា ត្រូវបន្តមានអានុភាពអនុវត្តក្រោយច្បាប់នេះចូលជាធរមាន រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស ។

**មាត្រា ៨២.-**

នៅពេលរង់ចាំការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍ផ្សេងទៀត សាលាឧទ្ធរណ៍បច្ចុប្បន្នដែលមានទីតាំងនៅរាជធានីភ្នំពេញ មានសមត្ថកិច្ចដែនដីលាតសន្ធឹងលើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨៣.-**

ការដាក់ឲ្យដំណើរការតុលាការជំនាញនានារបស់សាលាដំបូងដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៨៤.-**

ក្នុងករណីដែលសាលាដំបូងនៃខេត្តណាមួយមិនទាន់ត្រូវបានដាក់ឲ្យដំណើរការ ឬមិនអាចដាក់ឲ្យដំណើរការបាន សមត្ថកិច្ចជំនុំជម្រះរឿងក្តីទាំងឡាយនៅក្នុងខេត្តនោះ ត្រូវប្រគល់ទៅឲ្យសាលាដំបូងណាមួយដោយព្រះរាជក្រឹត្យ ។

**មាត្រា ៨៥.-**

កាលបើសភាពាណិជ្ជកម្ម និងសភាការងារនៃសាលាជម្រះក្តីជាន់ខ្ពស់ មិនអាចដំណើរការបានដោយមូលហេតុខ្វះចៅក្រម ការជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីការងារ គឺជាសមត្ថកិច្ចនៃសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់ ។ កិច្ចការទាំងនេះ ត្រូវចាត់ចែងដោយប្រធានសាលាជម្រះក្តីជាន់ខ្ពស់ ដែលសភាជំនាញនោះស្ថិតនៅ ។

កាលបើសភាជំនាញណាមួយខាងលើមានដំណើរការស្របតាមច្បាប់នេះ សភាជំនាញផ្សេងទៀតត្រូវផ្ទេររឿងក្តីដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ហើយមិនទាន់ចាត់ការ ទៅសភាជំនាញដែលមានសមត្ថកិច្ចវិញ ។

**មាត្រា ៨៦.-**

ក្នុងករណីដែលមិនទាន់មានចៅក្រមគ្រប់គ្រាន់ ចៅក្រមស៊ើបសួរអាចបំពេញមុខងារជាចៅក្រមជំនុំជម្រះក្តីបាន ប៉ុន្តែ មិនអាចជំនុំជម្រះរឿងក្តីដែលខ្លួនស៊ើបសួរបានឡើយ ។

**មាត្រា ៨៧.-**

ក្នុងករណីមិនទាន់មានសាលាជម្រះក្តីរដ្ឋបាល សមត្ថកិច្ចជំនុំជម្រះរឿងក្តីរដ្ឋបាលត្រូវប្រគល់ឲ្យតុលាការរដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ទាប និងសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់ ។

**មាត្រា ៨៨.-**

នៅពេលដែលមិនទាន់មានទីប្រឹក្សាពាណិជ្ជកម្ម ឬទីប្រឹក្សាការងារ សមាសភាពជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីការងារ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

**មាត្រា ៨៩.-**

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ការជំនុំជម្រះរឿងក្តីពាណិជ្ជកម្មត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីការងារការជំនុំជម្រះរឿងក្តីការងារ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋបាល ការជំនុំជម្រះរឿងក្តីរដ្ឋបាលត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

**មាត្រា ៩០.-**

ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំដំបូងបន្ទាប់ពីច្បាប់នេះចូលជាធរមាន ការតែងតាំងថ្នាក់ដឹកនាំនៃអង្គភាពរដ្ឋបាលរបស់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ អាចអនុវត្តបានយោងទៅតាមលក្ខខណ្ឌគុណវុឌ្ឍិជាក់ស្តែង ។

នាយកក្រឡាបញ្ជីនៃសាលាដំបូង អាចត្រូវបានតែងតាំងជាប្រធាន ឬអនុប្រធាននៃលេខាធិការដ្ឋានរដ្ឋបាលនៃសាលាដំបូងដែលខ្លួនកំពុងបំពេញការងារនោះបាន ។

នាយកក្រឡាបញ្ជីនៃសាលាជម្រះក្តីជាន់ខ្ពស់ អាចត្រូវបានតែងតាំងជាអគ្គលេខាធិការ ឬអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលនៃសាលាជម្រះក្តីជាន់ខ្ពស់ ដែលខ្លួនកំពុងបំពេញការងារនោះបាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៨
# អវសានប្បញ្ញត្តិ

**មាត្រា ៩១.-**

បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ និងច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជាដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៧១៤.០១៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខៈ ៩០៣ ស.ណ

**សំណៅចម្លងចេញពីច្បាប់ដើមសម្រាប់ការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

ជស/រកម/០៤៩៨/០៦

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត-០៨៩៧-១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស-រកម-១២៩៧-០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ និងសម្តេចនាយករដ្ឋមន្ត្រីទី ២ និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌

# ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៨ នាសម័យប្រជុំលើកទី ៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

## ជំពូកទី ១
## ការរៀបចំក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅបង្កើត និងកំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ពិនិត្យ និងសម្រេចអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ២.-**

ក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នឯករាជ្យ និងអព្យាក្រឹតក្នុងការបំពេញសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក ៩ រូប ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានអាណត្តិ ៩ ឆ្នាំ ។

**មាត្រា ៣.-**

សមាជិកទាំង ៩ រូប នៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជន ដែលមាន សញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច ៤៥ ឆ្នាំ មានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាឡើងទៅ ខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬ ខាងសេដ្ឋកិច្ច ហើយដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិច ១៥ ឆ្នាំ ។

សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ ៣ រូបត្រូវតែងតាំងដោយព្រះមហាក្សត្រ ៣ រូបត្រូវតែងតាំងដោយក្រុម-ប្រឹក្សានៃអង្គចៅក្រម ហើយ ៣ រូបទៀតត្រូវតែងតាំងដោយរដ្ឋសភា[១] តាមមតិភាគច្រើនដាច់ខាតនៃសមាជិកនៃរដ្ឋសភាទាំងមូល ។

ការជ្រើសតាំងដោយរដ្ឋសភាអាចធ្វើឡើងជាពីរលើកបាន ។

ក្នុងអាណត្តិទី ១ បើការបោះឆ្នោតលើកទី ១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី ២ ដោយយកអ្នកដែលបានទទួលសម្លេងច្រើនជាងគេចំនួនយ៉ាងច្រើន ៥ រូបមកបោះឆ្នោតឡើងវិញ។ ការបោះឆ្នោត លើកទី ២ នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។ អ្នកដែលទទួលបានសម្លេងច្រើនជាងគេ ត្រូវតែងតាំង

សម្រាប់ ៩ ឆ្នាំ អ្នកដែលទទួលបានសម្លេងបន្ទាប់ត្រូវតែងតាំង សម្រាប់ ៦ ឆ្នាំ និងអ្នកដែលទទួលបានសម្លេងបន្ទាប់មកទៀត ត្រូវតែងតាំង សម្រាប់ ៣ ឆ្នាំ ។

ក្នុងអាណត្តិបន្តបន្ទាប់ បើការបោះឆ្នោតលើកទី១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី ២ ដោយយកអ្នកដែលបានទទួលសម្លេងច្រើនជាងគេចំនួន ២ នាក់ មកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី ២ នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលបេក្ខជនទទួលបានសម្លេងស្មើគ្នានោះ ត្រូវយកអ្នកដែលមានអាយុច្រើនជាងគេ ។

បេក្ខជនម្នាក់ៗ ដែលនឹងត្រូវជ្រើសតាំងដោយរដ្ឋសភា ត្រូវមានហត្ថលេខាគាំទ្រជាមុន ពីសមាជិករដ្ឋសភាចំនួនមួយភាគដប់នៃសមាជិកទាំងមូល ។ សមាជិករដ្ឋសភា ១ រូប មានសិទ្ធិគាំទ្របានតែបេក្ខជន ១ រូបប៉ុណ្ណោះ ។

**មាត្រា ៤.-**

ក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តងសមាជិកចំនួន ៣ រូប ត្រូវផ្លាស់ប្តូរ និងតែងតាំងជាថ្មីគឺ ១ រូប តែងតាំងដោយព្រះមហាក្សត្រ ១ រូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ១ រូបទៀតជ្រើសតាំងដោយរដ្ឋសភា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានជ្រើសតាំងតាមការបោះឆ្នោត ដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញរៀងរាល់ ៣ ឆ្នាំម្តង តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ក្រោយពីសមាជិក ៣ រូប ចូលកាន់តំណែង ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាស់អាចត្រូវបានជ្រើសតាំងជាថ្មីបាន ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធានរដ្ឋសភា ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា ។

**មាត្រា ៥.-**

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយនឹងមុខងារ ជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា ប្រធាន អនុប្រធានគណបក្សនយោបាយ ប្រធាន អនុប្រធានសហជីព និងចៅក្រមក្នុងតំណែង ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវបំពេញមុខតំណែង និងមុខរបរផ្សេងទៀតនៅក្នុងអាណត្តិ របស់ខ្លួនឡើយ ។

អ្នកដែលបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ មុនចូលកាន់តំណែងត្រូវសុំលាឈប់ ជាបណ្តោះអាសន្នពីតំណែង ឬ មុខរបរទាំងអស់ ដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជូនដំណឹងជាលាយលក្ខអក្សរទៅសមាជិក ដែលនៅក្នុងមុខតំណែង និងមុខរបរ ខាងលើ ឱ្យសុំលាឈប់ពីមុខតំណែង ឬ មុខរបរនោះជាបន្ទាន់ ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសុំដកខ្លួនចេញពីរឿងទាំងឡាយណា ដែលផលប្រយោជន៍ផ្ទាល់ខ្លួនពាក់ព័ន្ធក្នុងរឿងនោះ ។ ការសុំដកខ្លួន ឬ ការតម្រូវឱ្យដកខ្លួន ត្រូវសម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។

**មាត្រា ៦.**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញនឹងត្រូវតែងតាំងជំនួសយ៉ាងយូរ ៣០ ថ្ងៃ មុនចប់អាណត្តិរបស់ សមាជិកដែលត្រូវចេញពីតំណែង ។

ក្នុងករណីដែលមានការសុំលាឈប់ ឬ ការដកចេញពីតំណែង ឬ មរណភាព សមាជិកថ្មីមកជំនួស ត្រូវបានតែងតាំងដូចមានចែងក្នុងមាត្រា ៤ ក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ ។

**មាត្រា ៧.**

មុនចូលកាន់តំណែង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើសច្ចាប្រណិធាន ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវរក្សាការសម្ងាត់ក្នុងការពិភាក្សា និងការបោះឆ្នោត ហើយមិនត្រូវបញ្ចេញយោបល់របស់ខ្លួនក្រៅអង្គប្រជុំទេ ។

**មាត្រា ៨.**

សមាជិកថ្មីនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវបានតែងតាំងជំនួសសមាជិក ដែលត្រូវចាកចេញពីមុខតំណែងមុនចប់អាណត្តិធម្មតារបស់ខ្លួន មានអាណត្តិត្រឹមថិរវេលាដែលនៅសល់ប៉ុណ្ណោះ ។

ប៉ុន្តែបើថិរវេលានេះតិចជាង ៣ ឆ្នាំ ឬ ស្មើនឹង ៣ ឆ្នាំ នៅពេលចប់ថិរវេលានេះ សមាជិកនោះ អាចត្រូវបានគេតែងតាំង ឬ ជ្រើសតាំង សម្រាប់អាណត្តិថ្មីមួយអាណត្តិទៀតបាន ។

**មាត្រា ៩.**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញម្នាក់ៗ អាចសុំលាឈប់ពីតំណែងបាន ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខ-អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ១០.**

ក្រុមប្រឹក្សាធម្មនុញ្ញអាចដកចេញពីតំណែងនូវសមាជិកណា ដែលបានរំលោភលើមាត្រា ៥ និង ៧ នៃច្បាប់នេះ ឬ ដែលមិនបានមកប្រជុំលើសពី ៣ដងផ្ទួនៗ គ្នាដោយឥតជូនដំណឹងជាមុន ឬ ដែលមិនអាចបំពេញមុខងារជារៀងរហូតបាន ដោយបាត់បង់សមត្ថភាពខាងបញ្ញា ឬ រូបកាយជាអចិន្ត្រៃយ៍ ។

ការសម្រេចដកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញណាមួយពីតំណែង តម្រូវឱ្យមានការយល់ព្រម ពីសមាជិកចំនួនពីរភាគបីនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញណា ដែលត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារពីបទមជ្ឈិម ឬ ឧក្រិដ្ឋ

ត្រូវដកចេញពីមុខតំណែងជាស្វ័យប្រវត្តិ ។

**មាត្រា ១១.-**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬ បទរដ្ឋប្បវេណីណា មួយចំពោះការសម្រេចដែលបានធ្វើនៅពេលដែលគេបំពេញភារកិច្ចជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញឡើយ ។

## ជំពូកទី ២
## ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
## ផ្នែកទី ១
## បទប្បញ្ញត្តិរួម

**មាត្រា ១២.-**

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

បទបញ្ជាផ្ទៃក្នុងត្រូវអនុម័តដោយមតិភាគច្រើនពីរភាគបី នៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ។

ក្រុមប្រឹក្សាធម្មនុញ្ញមានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាធម្មនុញ្ញមានថវិការបស់ខ្លួន ដែលផ្តល់ឱ្យដោយថវិកាជាតិ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាអាណាប័កដើមខ្សែ ។

**មាត្រា ១៤.-**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬ ដោយសមាជិកដែលមានអាយុច្រើនជាងគេ បើប្រធានមានធុរៈមិនអាចធ្វើបាន ។

កិច្ចប្រជុំនៃក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកចំនួន ៧ រូប ចូលរួមប្រជុំ ។

## ផ្នែកទី ២
## សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចំពោះធម្មនុញ្ញភាពនៃច្បាប់

**មាត្រា ១៥~**

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលអនុម័ត ដោយរដ្ឋសភា ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ។

**មាត្រា ១៦~**

ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងវិសោធនកម្មនៃច្បាប់រៀបចំអង្គការ និង បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ក្រោយរដ្ឋសភាបានអនុម័ត ត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់ទាំងនោះ ស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ ។

**មាត្រា ១៧~**

ព្រះមហាក្សត្រ ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ឬ តំណាងរាស្ត្រចំនួនមួយភាគដប់ អាចបញ្ជូនច្បាប់ផ្សេងទៀត ដែលរដ្ឋសភាបានអនុម័ត ទៅជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើ ។

**មាត្រា ១៨~**

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ឬ តំណាង-រាស្ត្រចំនួនមួយភាគដប់ ឬ តុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ នោះបាន ។

ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាពនៃច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញបាន តាមរយៈប្រធានរដ្ឋសភា ឬ តំណាងរាស្ត្រ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

**មាត្រា ១៩~**

បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះ អាចលើកអំពីអធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬ សេចក្តីសម្រេចរបស់ស្ថាប័ននានា ដែលគេអះអាងថា ប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន ។

បើយល់ឃើញថា ការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើកករណីនេះទៅតុលាការកំពូល ក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ ។

តុលាការកំពូលត្រូវចាត់ការពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយូរលើក-លែងតែតុលាការកំពូលយល់ឃើញថា ពាក្យប្តឹងតវ៉ានោះមិនអាចទទួលបាន ។

**មាត្រា ២០~**

បើក្រុមប្រឹក្សាធម្មនុញ្ញកំណត់ថា បទប្បញ្ញត្តិណាមួយនៃច្បាប់មិនស្របនឹងរដ្ឋធម្មនុញ្ញ :

ក-បើបទប្បញ្ញត្តិនោះមិនអាចបំបែកចេញពីអត្ថបទដែលនៅសល់បានទេ អត្ថបទច្បាប់ទាំងមូលមិនអាចយកទៅប្រកាសឱ្យប្រើ ឬ យកទៅអនុវត្តបានឡើយ ។

ខ-បើបទប្បញ្ញត្តិនោះអាចបំបែកចេញពីអត្ថបទដែលនៅសល់បាននោះ មានតែបទប្បញ្ញត្តិដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ដែលមិនអាចយកទៅប្រកាសឱ្យប្រើ ឬ យកទៅអនុវត្តបាន ។

**មាត្រា ២១.**

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិអញ្ជើញជនណាម្នាក់ ឬ ច្រើននាក់មកបំភ្លឺ ឬ ផ្តល់ឯកសារដែលពាក់ព័ន្ធបាន ។

បុគ្គលគ្រប់រូប ស្ថាប័នរដ្ឋ ឬ ឯកជនទាំងឡាយ ត្រូវគោរព និងប្រតិបត្តិតាមការអញ្ជើញ និងការស្នើសុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ២២.**

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចសេចក្តីជាលាយលក្ខអក្សរ លើគ្រប់ករណីដែលត្រូវបានដាក់ជូនក្នុងរយៈ-ពេល ៣០ ថ្ងៃ ។ ប្រសិនបើជាការប្រញាប់ រយៈពេលនេះត្រូវបន្ថយមកត្រឹម ៨ ថ្ងៃ ។

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិចារណាលើធម្មនុញ្ញភាព ដោយផ្អែកលើសេចក្តីរាយការណ៍របស់សមាជិក ដែលប្រធានបានប្រគល់ភារកិច្ចឱ្យពិនិត្យរាយការណ៍ ។

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្តី តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ ក្នុងករណីដែលបែកសម្លេងជាពីរស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាសម្លេងឧត្តមានុភាព ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបញ្ជាក់អំពីហេតុផល ។

**មាត្រា ២៣.**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ហើយមានអានុភាព អនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២៤.**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវផ្ញើថ្វាយព្រះមហាក្សត្រ ជូនប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រីនិងប្រធានតុលាការកំពូល និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

ប្រធានរដ្ឋសភាត្រូវជូនដំណឹងអំពីសេចក្តីសម្រេចនេះ ដល់សមាជិករដ្ឋសភាទាំងអស់ ។

នាយករដ្ឋមន្ត្រីត្រូវជូនដំណឹងទៅសមាជិករាជរដ្ឋាភិបាលទាំងអស់ ។

ប្រធានតុលាការកំពូលត្រូវជូនដំណឹងដល់តុលាការសាមី ។

## ផ្នែកទី ៣

## សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រា ២៥.**

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ២៦.**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេច :

១-លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយ ឬ របស់បេក្ខជន ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលសម្រេចបដិសេធលើការតវ៉ាពីបេក្ខភាព ឬ សម្រេចបដិសេធលើការតវ៉ាពីបញ្ជីរាយនាមបេក្ខជន ។ ការប្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរក្រោយពីបានទទួលលិខិតជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

២-លើបណ្តឹងតវ៉ារបស់បុគ្គល ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលសម្រេចបដិសេធការតវ៉ាសុំចុះឈ្មោះបោះឆ្នោត។ ការប្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ ថ្ងៃ យ៉ាងយូរក្រោយពីបានទទួលលិខិតជូនដំណឹងពី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

៣-លើបណ្តឹងតវ៉ារបស់បុគ្គល ឬ អ្នកតំណាង ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធអំពីការបាត់ឈ្មោះ ឬ អំពីការជំទាស់នឹងការចុះឈ្មោះ ឬ អំពីការរក្សាទុកឈ្មោះ ក្នុងបញ្ជីបោះឆ្នោតនូវបុគ្គលណាម្នាក់ ដែលគេយល់ឃើញថា មានលក្ខណៈមិនត្រឹមត្រូវតាម លក្ខខណ្ឌនៃច្បាប់បោះឆ្នោត ។ ការ ប្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរក្រោយពីបានទទួលលិខិត ជូនដំណឹងពីគណៈកម្មាធិការជាតិរៀបចំការបោះ ឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចករណីខាងលើ ក្នុងរយៈពេល ១០ថ្ងៃយ៉ាងយូរបន្ទាប់ពីបានទទួលពាក្យបណ្តឹង។

៤-លើបណ្តឹងតវ៉ារបស់គណបក្សនយោបាយ ពីការមិនព្រមចុះបញ្ជីគណបក្សនយោបាយ ។ បណ្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេច ករណីនេះក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹងរបស់សាមីគណបក្សនយោបាយ ។

**មាត្រា ២៧.**

ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ និងសម្រេច :

១-លើពាកពាក្យបណ្តឹងតវ៉ាដោយផ្ទាល់អំពីលទ្ធផលនៃការបោះឆ្នោត ដែលបុគ្គល ឬ គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត មិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត។ បណ្តឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៧២ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ន ។

២-លើបណ្តឹងតវ៉ារបស់បុគ្គល ឬ គណបក្សដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិ-

រៀបចំការបោះឆ្នោត ដែលសម្រេចបដិសេធការតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ។ ការប្តឹងតវ៉ានេះត្រូវធ្វើឡើង ក្នុងរយៈពេល ៤៨ ម៉ោងយ៉ាងយូរក្រោយពីបានទទួលលិខិតជូនដំណឹង ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ សម្រេចករណីខាងលើ ក្នុងរយៈពេល ២០ ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

**មាត្រា ២៨~**

បុគ្គលណា ឬ គណបក្សនយោបាយណាដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ មិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត ត្រូវធ្វើពាក្យបណ្តឹងជាលាយលក្ខអក្សរជូនទៅក្រុមប្រឹក្សា-ធម្មនុញ្ញ។ ពាក្យសុំនេះត្រូវបញ្ជាក់ :

១-ឈ្មោះបុគ្គល ឬ ឈ្មោះគណបក្សនយោបាយ ដែលជាអ្នកប្តឹងតវ៉ា

២-ឋានៈតាមផ្លូវច្បាប់របស់អ្នកប្តឹងតវ៉ា ( ជាអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬ ជាបេក្ខជន ឬ ជាតំណាងគណបក្សនយោបាយ )

៣-ឈ្មោះមណ្ឌលបោះឆ្នោត ដែលមានការប្តឹងតវ៉ា

៤-ឈ្មោះបុគ្គល ឬ គណបក្សនយោបាយ ដែលត្រូវបានគេប្រកាសថាជាប់ឆ្នោត ហើយដែលគេប្តឹងតវ៉ា

៥-គ្រប់ឯកសារ ឬ ភស្តុតាងសម្រាប់គាំទ្រការសុំបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញផ្អែកតាមឆន្ទានុសិទ្ធិរបស់ខ្លួន អាចទុកពេល ៥ ថ្ងៃឱ្យបុគ្គល ឬ គណបក្សនយោបាយដែលជាអ្នកប្តឹង ដើម្បីផ្តល់ភស្តុតាង ។

ក្រុមប្រឹក្សាធម្មនុញ្ញ អាចសម្រេចមិនធ្វើការស៊ើបអង្កេតលើបណ្តឹងណាមួយ បើបណ្តឹងនោះមិនបំពេញលក្ខ-ខណ្ឌកំណត់ក្នុងមាត្រានេះ ។

គ្រប់ករណីទាំងអស់ ដែលប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ មិនតម្រូវឱ្យបង់ប្រាក់ទេ ។

**មាត្រា ២៩~**

ពាក្យប្តឹងតវ៉ាគ្មានអានុភាពផ្អាកការអនុវត្តន៍ទេ។ ប៉ុន្តែក្នុងពេលរង់ចាំសេចក្តីសម្រេចស្ថាពរ ក្រុមប្រឹក្សា-ធម្មនុញ្ញ បើយល់ឃើញថាចាំបាច់ អាចចេញបញ្ជាជាបឋមមួយ ដើម្បីព្យួរជាបណ្តោះអាសន្ននូវ លទ្ធផលនៃការបោះឆ្នោតជ្រើស តាំងតំណាងរាស្ត្រណាម្នាក់ ឬ គណបក្សនយោបាយណាមួយ ដែលគេប្តឹងតវ៉ាបាន។ បញ្ជានេះនឹងត្រូវបញ្ចប់អានុភាពនៅពេល ដែលក្រុមប្រឹក្សាធម្មនុញ្ញ ចេញសេចក្តីសម្រេចជាស្ថាពរ ។

**មាត្រា ៣០~**

ដើម្បីស្រាវជ្រាវស៊ើបអង្កេត អំពីវិវាទកម្មទាក់ទងទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រុមប្រឹក្សា-ធម្មនុញ្ញចែកចេញជា ៣ក្រុម ។ ក្រុមនីមួយៗ មានសមាជិក ៣ រូប ដែល ០១ រូបជាសមាជិកតែងតាំងដោយព្រះមហាក្សត្រ

០១ រូបជាសមាជិកជ្រើសតាំងដោយរដ្ឋសភា និង ០១រូបទៀតជាសមាជិកតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ សមាជិក ក្នុងក្រុមទាំង ៣ នេះត្រូវជ្រើសរើសដោយវិធីចាប់ឆ្នោត ក្រោមអធិបតីភាពនៃប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៣១-**

ក្រោយពីបានទទួលពាក្យបណ្ដឹង ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវប្រគល់សិទ្ធិទៅឱ្យក្រុមណាមួយទទួលខុសត្រូវធ្វើការស៊ើបអង្កេត ។ ក្រុមនោះត្រូវជូនដំណឹងជាលាយលក្ខអក្សរជាបន្ទាន់ដល់អ្នកប្ដឹងតវ៉ា និងដល់ជន ឬ គណបក្សដែលត្រូវគេប្ដឹងតវ៉ាថា គេមានពេលយ៉ាងយូរ ១០ថ្ងៃ ដើម្បីពិនិត្យលើសេចក្ដីប្ដឹងតវ៉ា និងភស្ដុតាង ដែលភាគីបានផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ និងដើម្បីរៀបចំលិខិតឆ្លើយតបជាលាយលក្ខអក្សរ ។

**មាត្រា ៣២-**

ក្រោយពីបានទទួលលិខិតឆ្លើយតបខាងលើនេះ ឬ ក្រោយផុតកំណត់រយៈពេល ១០ ថ្ងៃ និង ក្រោយធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ហើយ ក្រុមដែលទទួលបន្ទុកត្រូវដាក់លទ្ធផលនៃការស៊ើបអង្កេត ព្រមទាំងយោបល់របស់ក្រុមនេះជូនក្រុមប្រឹក្សាធម្មនុញ្ញពេញអង្គ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចឱ្យធ្វើការស៊ើបអង្កេតបន្ថែមទៀត ហើយអាចស្ដាប់អ្នកប្ដឹងតវ៉ា និង អ្នកដែលត្រូវគេប្ដឹងតវ៉ាដោយផ្ទាល់បាន ។

**មាត្រា ៣៣-**

ក្នុងពេលធ្វើការស៊ើបអង្កេត ក្រុមប្រឹក្សាធម្មនុញ្ញ ឬ ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ អាចធ្វើការសាកសួរលើគ្រប់បញ្ហាទាំងអស់ ទារឯកសារ និងរបាយការណ៍ផ្សេងៗ និងកោះអញ្ជើញជនទាំងឡាយដែលពាក់ព័ន្ធក្នុងការបោះឆ្នោត។

ក្រុមប្រឹក្សាធម្មនុញ្ញ ឬ ក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ អាចចាត់តាំងបុគ្គលិករបស់ខ្លួន ឬ បុគ្គលផ្សេងទៀតឱ្យជួយក្នុងការស៊ើបអង្កេត ជាពិសេសនៅពេលទទួលចម្លើយរបស់សាក្សី ដែលបានធ្វើសច្ចាប្រណិធានហើយ ។ កំណត់ហេតុជាលាយលក្ខអក្សរ នៃចម្លើយរបស់សាក្សី ត្រូវតម្កល់ទុកសម្រាប់ភាគីទាំងអស់ ។ បើអ្នកស៊ើបអង្កេត ឬ សមាជិកក្នុងក្រុមណាម្នាក់ ដឹងថាសាក្សីមានការភ័យខ្លាចគេធ្វើបាប ឈ្មោះសាក្សីនោះត្រូវរក្សាទុកជាសម្ងាត់ មិនឱ្យនរណាដឹងទាំងអស់ក្រៅពីក្រុមប្រឹក្សាធម្មនុញ្ញ គឺឱ្យដឹងតែអំពីខ្លឹមសារនៃចម្លើយប៉ុណ្ណោះ ។

**មាត្រា ៣៤-**

ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចសេចក្ដី ក្នុងករណីដែលមានការតវ៉ា អំពីនីយតភាព នៃការបោះឆ្នោត អំពីភាពអាចជ្រើសតាំងបាននៃបេក្ខជនសម្រាប់បោះឆ្នោត និងភាពអាចជ្រើសតាំងបាននៃបេក្ខជន ដែលប្រកាសថា ជាប់ឆ្នោត ។

ក្រុមប្រឹក្សាធម្មនុញ្ញអាចយល់ស្រប ឬ មិនយល់ស្រប តាមសេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀប-ចំការបោះឆ្នោត អាចប្រកាសមោឃភាពនៃការបោះឆ្នោតដែលគេប្ដឹងតវ៉ា ឬ ប្រកាសថាបេក្ខជនជាប់ឆ្នោតដោយត្រឹមត្រូវ ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចសេចក្ដីតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបញ្ជាក់អំពីហេតុផល ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

សេចក្តីសម្រេចនេះត្រូវថ្វាយព្រះមហាក្សត្រ បញ្ជូនទៅរដ្ឋសភា និងរាជរដ្ឋាភិបាល ហើយត្រូវចុះក្នុងរាជកិច្ច។

**មាត្រា ៣៥.-**

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិបញ្ជូនបណ្តឹង ដែលមិនចូលក្នុងសមត្ថកិច្ចរបស់ខ្លួន ទៅអង្គការមានសមត្ថកិច្ច។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**មាត្រា ៣៦.-**

ជនណាដែលមានពិរុទ្ធបានធ្វើជាសាក្សីទុច្ចរិត ឬ ធ្វើការកៀបសង្កត់ទៅលើសាក្សី ក្នុងក្របខ័ណ្ឌនៃ ការអង្កេតស៊ើបសួររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬ ជនណាដែលមិនព្រមគោរពតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬ រារាំងដល់កិច្ចប្រតិបត្តិការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែដល់ ១ ឆ្នាំ និងត្រូវពិន័យជាប្រាក់ពីដប់ម៉ឺន (១០០.០០០) រៀល ដល់ហុកសិបម៉ឺន (៦០០.០០០) រៀល ឬ ផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរ ។

**មាត្រា ៣៧.-**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសខាងបទវិន័យ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។ បទវិន័យនេះត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៨.-**

ក្នុងអាណត្តិទី ១ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវមានសមាជិក ០៣ រូប តែងតាំងសម្រាប់រយៈពេល ៣ ឆ្នាំ ០៣ រូប តែងតាំងសម្រាប់រយៈពេល ៦ ឆ្នាំ និង ០៣ រូបទៀតតែងតាំងសម្រាប់រយៈពេល ៩ ឆ្នាំ ។

ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិក ០១រូបសម្រាប់ ៣ ឆ្នាំ ០១រូបសម្រាប់ ៦ឆ្នាំ និង ០១ រូបទៀតសម្រាប់ ៩ ឆ្នាំ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែងតាំងសមាជិក ០១ រូបសម្រាប់ ៣ឆ្នាំ ០១ រូបសម្រាប់ ៦ឆ្នាំ និង០១

រូបទៀតសម្រាប់ ៩ ឆ្នាំ ។

រដ្ឋសភាត្រូវជ្រើសតាំងសមាជិក ០១រូបសម្រាប់ ៣ឆ្នាំ ០១រូបសម្រាប់ ៦ឆ្នាំ និង ០១រូបទៀតសម្រាប់ ៩ឆ្នាំ។

**មាត្រា ៣៩~**

ការកោះប្រជុំលើកទី ១ របស់ក្រុមប្រឹក្សាធម្មនុញ្ញត្រូវធ្វើឡើងក្នុងរយៈពេល ៧ ថ្ងៃ យ៉ាងយូរបន្ទាប់ពីចេញព្រះរាជក្រឹត្យតែងតាំងសមាជិក ។ការកោះប្រជុំ និងការដឹកនាំអង្គប្រជុំលើកទី ១ នេះត្រូវធ្វើឡើងដោយសមាជិកដែលមានអាយុច្រើនជាងគេដែលមានវត្តមាន ដើម្បីជ្រើសតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ៤០~**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១~**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

**ប្រមុខរដ្ឋស្ដីទី**

ហត្ថលេខា

**ជា ស៊ីម**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

ហត្ថលេខា ហត្ថលេខា

**អ៊ឹង ហួត ហ៊ុន សែន**

បានជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ និងសម្ដេចនាយករដ្ឋមន្ត្រីទី ២

**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

ហត្ថលេខា

**ចែម ស្ងួន**

លេខ : ១០០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ហត្ថលេខា

**ណាឌី~តាន់**

(១) ពាក្យ " តែងតាំងដោយរដ្ឋសភា" មិនត្រឹមត្រូវទេ។ នៅក្នុងរដ្ឋធម្មនុញ្ញ គឺប្រើពាក្យ " ជ្រើសតាំងដោយរដ្ឋសភា"